

# សមិទ្ធផល

## យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន

## ២០២៣-២០២៤

# សមិទ្ធផលយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន
២០២៣-២០២៤



# សេចក្ដីផ្ដើម

«ការយល់ឃើញរបស់ពិភពលោកពីភាពវិជ្ជមាននៃវិស័យបរិស្ថានកម្ពុជា គឺជាបេសកកម្មដ៏ចម្បងរបស់ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន» ផ្អែកលើបេសកកម្មមួយនេះ យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានដែលរួមមាន ភាពស្អាត ភាពបៃតង និងចីរភាព គឺជាគន្លឹះ និងជាឧបករណ៍វាស់វែងលើការងារសុក្រឹតកម្មបរិស្ថានកិច្ច ដែលមានភាពប្រាកដនិយម ជាក់លាក់ ដើម្បីឈានឆ្ពោះក្លាយទៅជាប្រទេសអព្យាក្រឹត នៅឆ្នាំ២០៥០។

សៀវភៅសមិទ្ធផលយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាននេះ គឺជាការចង្អុលបង្ហាញអំពីសកម្មភាពការងារពីមួយជំហានទៅមួយជំហានរបស់ក្រសួងបរិស្ថាន និងជាភស្តុតាងជាក់ស្ដែងនៃការបំពេញការងារឈានឆ្ពោះទៅ «កម្ពុជាជាប្រទេសអព្យាក្រឹតកាបូន នៅឆ្នាំ២០៥០» ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា ក្រោមមគ្គុទ្ទេសក៍ដឹកនាំដ៏ឆ្នើមរបស់ សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សមិទ្ធផលនៃសកម្មភាពជាច្រើនរបស់ក្រសួងបរិស្ថាន បានស្ដែងចេញពី ភាពស្អាត ភាពបៃតង និងចីរភាព ក្នុងនោះក្រសួងបរិស្ថានទទួលបានការចូលរួមគាំទ្រ និងប្ដេជ្ញាចិត្តពីប្រជាពលរដ្ឋកម្ពុជា ៩.៥៣៨.៦០២ អង្គ/នាក់។ ជាការពិតត្រឹមតែតួលេខច្រើនជាងពាក់កណ្ដាលនៃចំនួនប្រជាពលរដ្ឋសរុបនៅទូទាំងប្រទេសកម្ពុជានេះ មិនមែនជាជោគជ័យ ឬជាសមិទ្ធផលទាំងមូលដែលក្រសួងបរិស្ថានទទួលបាននោះឡើយ វាគ្រាន់តែជាជោគជ័យ១ ក្នុងជំហានដំបូងប៉ុណ្ណោះ គឺនៅមានភាពជោគជ័យជាច្រើន និងជាបន្តបន្ទាប់ទៀត ដែលក្រសួងសម្រេចបាន ហើយបានដាក់បង្ហាញក្នុងសៀវភៅដែលលោកអ្នកអាន កំពុងកាន់នៅក្នុងដៃនេះ។

យើងខ្ញុំជឿជាក់យ៉ាងមុតមាំថា សៀវភៅ សមិទ្ធផលយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ដែលលោក អ្នកនាងកំពុងកាន់អាននេះ បាននាំលោក អ្នកអាន ទៅកាន់ការពិតមួយក្នុងចំណោមព័ត៌មានបំភ្លៃជាច្រើនស្ដីពី វិស័យបរិស្ថានរបស់កម្ពុជា ដែលអ្នកអានកន្លងមកបានជួបប្រទះ ដែលឃើញនៅលើបណ្ដាញសង្គម (Social Media)។ លើសពីការពិតសៀវភៅនេះក៏បានបង្ហាញពីការសាមគ្គីរបស់ក្រុមគ្រួសារខ្មែរចំពោះការពារ ការអភិរក្ស ការស្រឡាញ់បរិស្ថាន ដែលជាភស្តុតាង បានស្ដែងឱ្យលោក អ្នកអាន បានឃើញរួចទៅហើយថា មានពលរដ្ឋកម្ពុជា ៩.៥៣៨.៦០២អង្គ/នាក់ កំពុងរួមគ្នាធ្វើយ៉ាងសស្រាក់សស្រាំ និងដោយពេញចិត្ត ឥតមានការបង្ខិតបង្ខំឡើយ នេះហើយជាសំឡេងប្រជាធិបតេយ្យនៅក្នុងសង្គមប្រជាធិបតេយ្យ ដែលមនុស្សគ្រប់រូបតែងប្រាថ្នាចង់បាន។

យើងខ្ញុំសូមអនុញ្ញាតបញ្ចប់សេចក្ដីផ្ដើមនៃសៀវភៅសមិទ្ធផលយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ត្រឹមនេះ ទុកឱកាសជូនមិត្តអ្នកអានទាំងអស់ បានឈ្វេងយល់អំពីកិច្ចការងារសុក្រឹតកម្មបរិស្ថានកិច្ច ដែលមានបង្ហាញជូនតាមរយៈសន្លឹកជាបន្តបន្ទាប់នៅផ្នែកខាងក្រោមនេះ បន្ទាប់ពីមាតិកា ។

សូមអរគុណចំពោះការយកចិត្តទុកដាក់របស់មិត្តអ្នកអានគ្រប់រូប ដោយក្ដីគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំដែលជាក្រុមអ្នកចងក្រង និងរៀបចំសៀវភៅនេះឡើង៕

# មាតិកា


១.សមិទ្ធផលការងារអាទិភាព យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន .................................................................. ១៥
- E-Admin
- ភាពស្អាត
- ភាពបៃតង
- ចីរភាព

២.ការបណ្តុះធនធានមនុស្សជំនាន់ក្រោយឱ្យមានបេះដូងស្អាត ពេញដោយភាពបៃតងយូរអង្វែងតទៅ .............. ១៨៩
- បាវកថាយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន
- ការងារអាទិភាពរបស់ក្រសួងបរិស្ថានបានបណ្តុះស្មារតីអ្នកជំនាន់ក្រោយឱ្យមានភាពស្អាត មានភាពបៃតង ជានិរន្តរ៍
- ផ្តល់ឱកាសឱ្យអ្នកជំនាន់ក្រោយបានសិក្សាអំពីយុទ្ធសាស្ត្រក្រសួងបរិស្ថាន
- ដឹកនាំយុវជនឱ្យមានភាពស្អាត ភាពបៃតង ប្រកបដោយចីរភាព និងលើកទឹកចិត្តឱ្យយុវជន ចូលរួមក្នុងការងារផ្សព្វផ្សាយ (ជាតិ និងអន្តរជាតិ)

៣.កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងការទូត ឆ្លើយតបនឹងការងារអាទិភាព គឺភាពស្អាត ភាពបៃតង និងចីរភាព .................................................................. ២២៥
- ជំនួបសម្តែងការគួរសម និងពិភាក្សាការងារអាទិភាព ដើម្បីកៀរគរថវិកាឆ្លើយតបការប្រែប្រួលអាកាសធាតុ

៤.ការជូនជ្រំចាក់គ្រឹះសន្តិភាពនៅក្នុងសង្គមកម្ពុជា .................................................................. ២៦៥
- សុន្ទរកថា និងការសម្ពោធសមិទ្ធផលនានារបស់រាជរដ្ឋាភិបាលនីតិកាលទី៧

៥.ឯកសារយោង .................................................................. ២៩៥

៦.សារថ្លែងអំណរគុណរបស់ឯកឧត្តមរដ្ឋមន្ត្រី .................................................................. ៣០៩

# សាររបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន



ដើម្បីធានាឱ្យបាននូវចីរភាពបរិស្ថាននិងសុក្រឹតកម្មបរិស្ថានកិច្ច ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់សេដ្ឋកិច្ចបៃតង សម្រេចនូវគោលដៅយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គឺកម្ពុជាជាប្រទេសអាព្យាក្រឹតកាបូននៅឆ្នាំ២០៥០ តាមរយៈ **ភាពស្អាត ភាពបៃតង និងចីរភាព** នៃយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន២០២៣-២០២៨ ក្រោមមគ្គុទ្ទេសក៍ដឹកនាំដ៏ឆ្នើមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងបរិស្ថាននៅក្នុងអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភានេះ បានកំណត់ទិសដៅការងារជាអាទិភាពគឺ **ភាពស្អាត ភាពបៃតង និងចីរភាព** ដែលមានភាពសាមញ្ញ ងាយស្រួលយល់ និងអាចយកទៅអនុវត្តបានក្នុងជីវិតប្រចាំថ្ងៃដោយងាយស្រួល ជាពិសេសជំហាននីមួយៗនៃយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានមានភាពប្រាកដនិយម និងជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្ត និងពង្រីកសកម្មភាព សមិទ្ធផលរបស់ខ្លួនឱ្យកាន់តែមានវិសាលភាពធំធេង ដើម្បីបម្រើឱ្យផលប្រយោជន៍ប្រជាជាតិកម្ពុជាទាំងមូល ហើយក៏ជាមរតកសម្រាប់មនុស្សជំនាន់ក្រោយ។ សៀវភៅ **សមិទ្ធផលយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន** នេះ គឺជាការឆ្លុះបញ្ចាំងនូវភាពជោគជ័យរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី** ដែល **សម្តេច** បានផ្តួចផ្តើមឱ្យមានយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ធ្វើជាផែនទីបង្ហាញផ្លូវ ដែលមានភាពសាមញ្ញ ងាយយល់ ងាយអនុវត្តនិងជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តបន្តទៅមុខទៀត។

ក្នុងនាមក្រសួងបរិស្ថាន និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម និងជាបិតាសន្តិភាពសម្រាប់កម្ពុជា ដោយមានសុខសន្តិភាពនេះហើយ បានធ្វើឱ្យកម្ពុជាសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈទាំងនេះឡើង។ ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសសមានចិត្តដ៏ស្រស់ស្អាតរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប និងសិស្សានុសិស្សដែលបានរួមចំណែកធ្វើឱ្យកម្ពុជាយើង មានភាពស្អាត ភាពបៃតង រក្សានៅជានិច្ចនិរន្តរ៍ ដែលនេះហើយគឺជាចីរភាព ជាមរតកធនធានធម្មជាតិទុកនៅដល់កូនចៅជំនាន់ក្រោយ។

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# ផ្នែកទី១

## សមិទ្ធផលការងារអាទិភាពយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន



# រដ្ឋបាលឌីជីថល E-Admin

រដ្ឋបាលប្រៀបដូចជាមេផ្ទះ ហើយជាមេផ្ទះល្អ គឺប៉ិនប្រសព្វគ្រប់គ្រងផ្ទះឱ្យមានរបៀបរៀបរយ មានសណ្ដាប់ធ្នាប់ មានវិន័យ មានច្បាប់ទំលាប់ត្រឹមត្រូវ ជាពិសេសគឺភាពច្បាស់លាស់លើការគ្រប់គ្រងទ្រព្យសម្បត្តិគ្រួសារ ជាមួយគ្នានេះ មេផ្ទះក្នុងសម័យឌីជីថលចាំបាច់ត្រូវលឿន និងរហ័សរហួន។





ភាពលឿន និងរហ័សរហួននៃរដ្ឋបាលឌីជីថល (E-Admin) នេះហើយ ដែលបានជួយសម្រួល និងពន្លឿនការងារថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួងបរិស្ថាន ឱ្យលំហូរការងារប្រព្រឹត្តិទៅបានលឿនទាន់ពេលវេលា និងកាត់បន្ថយនូវកត្តារាំងស្ទះទាំងឡាយកន្លងមកដូចជា ថ្នាក់ដឹកនាំជាប់បេសកកម្មមិនបានឆ្លើយតបភ្លាមៗ ត្រូវបញ្ជូន និងរត់ឯកសារជា(Hard)ទៅមកចុះឡើង និងត្រូវចំណាយពេលរង់ចាំដំណើរឯកសារយូរជាដើម។

(សូមអានរូបគំនូសបំព្រួញដំណើរការនៃលំហូការងាររដ្ឋបាល E-Admin)



រដ្ឋបាល Digital របស់ក្រសួងបរិស្ថានបានផ្តើមដំណើរការសាកល្បងហើយ នៅក្នុងចំណោមថ្នាក់ដឹកនាំរបស់ក្រសួង ដើម្បីជំរុញឱ្យប្រព័ន្ធការងាររដ្ឋបាលមានដំណើរការបានល្អ លឿនរហ័ស ចំណេញពេលវេលាជាងមុន និងទទួលបានព័ត៌មានជាក់លាក់អំពីសកម្មភាពនានារបស់ថ្នាក់ដឹកនាំ។ នៅក្នុងដំណាក់កាលទី១ នៃការដាក់ឱ្យប្រើសាកល្បងនេះ ក្រសួងបរិស្ថានទទួលបានភាពជោគជ័យឆ្លើយតបទៅនឹងដំណើរការការងារប្រចាំថ្ងៃរបស់ថ្នាក់ដឹកនាំ និងជាជំហានបន្ទាប់ក្រសួងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅក្នុងចំណោមមន្ត្រីរាជការទាំងអស់ និងជាពិសេសមន្ត្រីឧទ្យានុរក្ស ។

ការប្រកាសនេះ ថ្លែងក្នុងសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន នាព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣។ ជាមួយគ្នានេះ ដើម្បីជំរុញឱ្យនាវាបរិស្ថានសម្រេចបានស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុង





ដំណាក់កាលទី១នេះ ក្រសួងបរិស្ថានមានយុទ្ធសាស្ត្រចក្រា ដែលជាត្រីវិស័យចង្អុលផ្លូវ និងជួយឱ្យសុក្រឹតកម្មបរិស្ថានកិច្ច សម្រេចបាន តាមរយៈបន្ទះកងវិលផ្នែកខាងក្នុងចំនួន បីគឺ គោលនយោបាយ រដ្ឋបាល និងផ្សព្វផ្សាយ ដែលកងវិល ទាំងនេះ រុញឱ្យមានចលនាទៅលើកង៣ នៅផ្នែកខាងក្រៅ គឺ ភាពស្អាត ភាពបៃតង និងចីរភាព ហើយមុំទាំងបីនេះ បានធ្វើ ឱ្យក្រសួងសម្រេចបាននូវលទ្ធផលជាច្រើន ដែលក្នុងនោះ មានការគាំទ្រ និងប្តេជ្ញាចិត្តពីប្រជាពលរដ្ឋ និងសិស្សានុសិស្ស







ជាង ៣លាននាក់ នឹងបានបន្តឥតដាច់នូវចរន្តនៃការគាំទ្រ ហើយកាន់តែធំឡើងៗជាលំដាប់ និងល្បីរន្ទឺនៅលើឆាកអន្តរ-ជាតិ។

ដំណើរការនៃការសាកល្បងប្រើប្រាស់រដ្ឋបាលឌីជីថល នៅក្នុងចំណោមថ្នាក់ដឹកនាំរបស់ក្រសួង ដើម្បីជំរុញឱ្យប្រព័ន្ធការងាររដ្ឋបាលមានដំណើរការបានល្អ លឿនរហ័ស ចំណេញពេលវេលាជាងមុន និងទទួលបានព័ត៌មានជាក់លាក់ អំពីសកម្មភាពនានារបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅក្នុង ស្ថាប័ន។

សូមបញ្ជាក់ថា ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ជំហានទី២ សំដៅដល់មន្ត្រីជំនាញរាប់ចាប់ពីអនុប្រធាននាយកដ្ឋាន ប្រធាននាយកដ្ឋាន និងអគ្គនាយករង ដើម្បីពន្លឿនដំណើរការការងារវិស័យបរិស្ថានឱ្យកាន់តែមាន សុក្រឹតភាព តម្លាភាព ប្រកបដោយការទទួលខុសត្រូវខ្ពស់ នៅក្នុងចំណោមមន្ត្រីរាជការទាំងអស់។





## លទ្ធផលសម្រេចបាន

| សកម្មភាព | លទ្ធផលសម្រេចបាន |
|---|---|
| បានប្រកាសដាក់ឱ្យដំណើរការ (ប្រកាសលេខ ២៥៤៨/០៥២៤ ប្រក.បស្ត/អរហ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤) | អនុវត្តប្រព័ន្ធឌីជីថលសម្រាប់គ្រប់គ្រងកាលវិភាគការងារ និងឬវត្តមានមន្ត្រីរាជការរបស់ក្រសួង តាមប្រព័ន្ធ App (MOE Activity, MOE E-admin and TV) បង្ហាញពីសកម្មភាពប្រចាំថ្ងៃរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់ក្រសួង។ |
| បានបណ្តុះបណ្តាលមន្ត្រីរាជការក្រសួង ចេះប្រើប្រាស់ប្រព័ន្ធ App (MOE Activity and MOE E-admin) និងចំណេះដឹងបន្ថែមស្តីពី «ឌីជីថលចាំបាច់» នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល | មន្ត្រីចំនួន ១១៨រូប ក្នុងនោះស្ត្រី ៤២រូប ទទួលបានចំណេះដឹងបន្ថែមស្តីពី «ឌីជីថលចាំបាច់» |

| | |
|---|---|
| បានអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងចំណូល( NRMIS/E-payment ) | សម្រេចបានការទូទាត់ចំណាយគ្រប់មុខចំណាយទាំងស្រុង មុខងារលទ្ធកម្មពេញលេញ និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាតាមប្រព័ន្ធ ( FMIS ) ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ( SARMIS )។ |
| បានរៀបចំពិនិត្យឡើងវិញ វិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួង។ | ពិនិត្យឡើងវិញ វិភាគ និងបញ្ចូលព័ត៌មាន ទិន្នន័យក្នុងទម្រង់ថ្មីដែលណែនាំដោយក្រសួងមុខងារ ក្នុងនោះមានទាំងឯកសាររឹង និងឯកសារទន់ និងបានរាយការណ៍ជូនតាមវេលាកំណត់។ |
| បានពង្រឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលក្រសួងតាមប្រព័ន្ធឌីជីថល តាមរយៈការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការសាធារណៈក្រសួង ការបំពេញប្រវត្តិរូប និងបញ្ចូលទិន្នន័យមន្ត្រីរាជការក្នុងប្រព័ន្ធ HRMIS របស់ក្រសួងមុខងារឡើងវិញ។ | លទ្ធផល មន្ត្រីសរុបមានចំនួន ២ ៩៦៦នាក់ និងបញ្ចូលក្នុងប្រព័ន្ធបាន៩៦% ( គិតត្រឹមថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤ )។ |



| | |
|---|---|
| បានបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ត្រីបម្រើក្នុងក្រសួង មន្ត្រីនៃមន្ទីរបរិស្ថានរាជធានី ខេត្ត និងមន្ត្រីឧទ្យានុរក្សលើការងារគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រងធនធានធម្មជាតិ ។ | មន្ត្រីរាជការចំនួន ៧៥នាក់បានបណ្ដុះបណ្ដាលពង្រឹងសមត្ថភាព តាមរយៈការសិក្សាដោយផ្ទាល់ក្នុងថ្នាក់ និងតាមរយៈអនឡាញ ដែលក្នុងនោះរួមមាន៖<br>១. វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិចំនួន ២៥នាក់<br>២. សាលានាយទាហានសកម្មមានចំនួន ២៥នាក់<br>៣. សាលាភូមិន្ទរដ្ឋបាលចំនួន ២៥នាក់<br>លើសពីនេះបានផ្គត់ផ្គង់ឯកសណ្ឋានចំនួន ២លើក ស្មើនឹង ៤ ៥៤៣កំប្លេរ ជូនមន្ត្រីឧទ្យានុរក្ស។ |
| បានផ្ដល់ការលើកទឹកចិត្តដល់មន្ត្រីរាជការ និងអង្គភាពចំណុះដែលបំពេញការងារបានល្អ។ | ផ្ដល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការចំនួន ២៦៥នាក់ បណ្ណសរសើរចំនួន ៦១៥នាក់ និងដំឡើងឋានន្តរសក្តិ និងថ្នាក់ចំនួន ៩៣៤នាក់។ |

## ដំណើរការនៃលំហូរការងាររដ្ឋបាល (E-Admin):






# ភាពស្អាតក្នុងដែនអាកាស

យុទ្ធនាការ «ផ្ទៃមេឃពណ៌ខៀវ» នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយបានចាត់វិធានការក្នុងការត្រួតពិនិត្យគុណភាពខ្យល់ ការដុតសំរាមប្លាស្ទិកតាមរោងចក្រ សហគ្រាស អាជីវកម្មផ្សេងៗ និងប្រភពអាចបង្កការបំពុលផ្សេងៗទៀតនៅទូទាំងប្រទេស។




## យុទ្ធនាការ «ផ្ទៃមេឃពណ៌ខៀវ»

យុទ្ធនាការ «ផ្ទៃមេឃពណ៌ខៀវ» ដែលក្រសួងបរិស្ថានបានដាក់ចេញនៅថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២៤ គឺជាយុទ្ធនាការមួយ ក្នុងចំណោមយុទ្ធនាការជាច្រើនទៀត ដែលក្រសួងបរិស្ថានបានដាក់ចេញ ឆ្ពោះទៅកាន់ការងារអាទិភាពវិស័យបរិស្ថាន ដើម្បីភាពស្អាត ភាពបៃតង និងចីរភាព។ តាមរយៈយុទ្ធនាការនេះ ក្រសួងបរិស្ថានបានជម្រាបជូនដល់សាធារណជន អំពីគុណភាពខ្យល់របស់កម្ពុជា ដែលមានភាពស្អាត គ្មានការបំពុលដូចជាការផ្សព្វផ្សាយបំភ្លើសនោះឡើយ ជាក់ស្តែងក្រសួងបរិស្ថានបានបង្ហាញនូវរបាយការណ៍ជាប្រចាំស្តីពី លទ្ធផលនៃការគ្រប់គ្រងគុណភាពខ្យល់ប្រចាំថ្ងៃនៅលើគេហទំព័រ និងផេកផ្លូវការរបស់ ក្រសួងបរិស្ថាននៅទូទាំង២៥រាជធានី-ខេត្ត។

ជាមួយគ្នានេះ ប្រជាពលរដ្ឋកម្ពុជាមានការសាទរយ៉ាងខ្លាំងចំពោះលទ្ធផលទាំងនេះ ហើយពួកគេបានបន្តគាំទ្រលើកិច្ចការងាររបស់ក្រសួងបរិស្ថាន តាមរយៈការចូលរួមចំណែកក្នុងការទប់ស្កាត់នូវការដុតសំរាមប្លាស្ទិកនៅតាមរោងចក្រ សហគ្រាស និងអាជីវកម្មផ្សេងៗ ដែលជាប្រភពបង្កការបំពុលដល់សុខមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។

លើសពីការគាំទ្ររបស់ប្រជាពលរដ្ឋកម្ពុជា សូម្បីអង្គការដៃគូអភិវឌ្ឍន៍ក៏បានរួមចំណែកយ៉ាងសកម្មជាមួយក្រសួងបរិស្ថានដែរ នៅក្នុងការប្តេជ្ញាចិត្តកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យនៅឆ្នាំ២០៥០ខាងមុខនេះ ដែលក្នុងនោះមានវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) និងអង្គការអុកស្វាម (OXFAM)។

(Footnote «ជំហរកម្ពុជាចំពោះយុទ្ធនាការផ្ទៃមេឃពណ៌ខៀវ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ ២០៥០នៅកម្ពុជា)


ល្អណាស់
ល្អ
មធ្យម
០-៥០
៥១-១០០
១០១-១៥០
១៥១-២០០
២០១-៣០០
៣០១-៥០០




CO = 0 ppm
NO2 = 0.009 ppm
NOx = 0.007 ppm
O3 = 0.034 ppm
SO2 = 0 ppm
វិស្ណុ ត្រួតពិនិត្យគុណភាពខ្យល់
Vishnu Air Quality Monitoring


LAS-1
LAS-1
LAS-1


REPUBLIC OF KOREA
KOICA


LAS-1

## ភាពស្អាតក្នុងដែនគោក

ក្រសួងបរិស្ថានបានដាក់ចេញនូវផែនការជាជំហានដែលរួមមាន៖

១. យុទ្ធនាការ

២. ចលនា

៣. ទំលាប់

## ជំហានទី១៖ យុទ្ធនាការ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ មានអ្នកចូលរួមសរុបចំនួន ១៨ ០០០អង្គ-នាក់ (នៅស្រុកអូររាំងឪ)។ ចេញពីស្រុកអូររាំងឪ យុទ្ធនាការនេះបានរីកសាយភាយទៅទូទាំងប្រទេស ជាលទ្ធផលរហូតដល់ខែសីហា ឆ្នាំ២០២៤ មានសិស្សានុសិស្ស ព្រះសង្ឃ ដូនជី អាចារ្យ មន្ត្រីរាជការ កម្មករ និងប្រជាពលរដ្ឋ រៀបចំនៅតាមសាលារៀន វត្តអារាម តាមរោងចក្រ ភូមិ ឃុំ ស្រុក ខេត្ត ទូទាំងប្រទេសបានចូលរួមគាំទ្រ និងប្តេជ្ញាចិត្តកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ដែលមានអ្នកចូលរួមសរុបចំនួន ៩ ៥៣៨ ៦០២អង្គ/នាក់ (ក្នុងនោះ សាលាចំនួន ១២ ១៩៩សាលា លោកគ្រូ អ្នកគ្រូ ១០៧ ៤៩៥នាក់ និងសិស្សានុសិស្សចំនួន ៣ ៦៦១ ៧៥២នាក់ បានចូលរួមអនុវត្ត ១០០% ហើយនៅមានវត្តអារាមចំនួន ២០០វត្ត ព្រះសង្ឃ ៨ ៤៨៩អង្គ មន្ត្រីរាជការចំនួន ៨៥ ៣៧១នាក់ ប្រជាពលរដ្ឋ/និយោជិតចំនួន ៥ ៦៧៥ ៤៩៥នាក់ ក៏បានចូលរួមយ៉ាងសកម្មផងដែរ។























## FAO និង UNDP បានប្តេជ្ញាចិត្ត និងចុះហត្ថលេខាក្នុងភាពជាដៃគូគ្មានប្លាស្ទិកជាមួយក្រសួងបរិស្ថាន

អង្គការអន្តជាតិធំៗចំនួន២ គឺអង្គការស្បៀងអាហារ និងកសិកម្ម FAO និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP បានប្តេជ្ញាចិត្ត និងចុះហត្ថលេខាចូលរួមការងារអាទិភាពរបស់ក្រសួងបរិស្ថាន ក្នុងយុទ្ធនាការកាត់បន្ថយថង់ប្លាស្ទិក «ថ្ងៃនេះខ្ញុំមិនប្រើប្រាស់ថង់ប្លាស្ទិកទេ» នៅក្នុងពិធីចុះហត្ថលេខាស្តីពីភាពជាដៃគូគ្មានប្លាស្ទិក នាថ្ងៃទី ០៣ វិច្ឆិកា ឆ្នាំ២០២៣ នៅខេត្តសៀមរាប ។



ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថានបានថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ធំៗទាំង២ ដែលបានរួមចំណែកក្នុងការងារអាទិភាពរបស់ក្រសួងបរិស្ថាន ឱ្យសម្រេចបានទិសដៅរួមជាមួយគ្នាក្នុងការកាត់បន្ថយសំណល់ប្លាស្ទិក ដែលជាក្តីកង្វល់ជាសកលរបស់យើងទាំងអស់គ្នា ។



ជាមួយនឹងក្តីកង្វល់នេះ FAO UNDP និងក្រសួងបរិស្ថាន បានចាប់ដៃគ្នា ឆ្លើយតបនឹងការគំរាមគំហែងពីសំណល់ប្លាស្ទិក ដោយយើងមានសិស្សានុសិស្សជាង ២លាននាក់ចូលរួមជាមួយរួចទៅ នឹងបន្តទៅកម្មករ កម្មការិនី ព្រះសង្ឃ និងប្រជាពលរដ្ឋអ្នកស្រឡាញ់ភាពស្អាត ហើយភាពស្អាតគឺផ្តើមចេញពីយើងទាំងអស់គ្នា ។ លើសពីនេះ ចលនាស្អាតក៏ទទួលការគាំទ្រពីកាកកបាទក្រហមកម្ពុជា ដែលជាកម្លាំងចិត្តសម្រាប់ក្រុមអ្នកស្រឡាញ់ភាពស្អាតបន្តកិច្ចការងារនេះ ដោយបេះដូងឱ្យទទួលបានភាពជោគជ័យ ។



គួររម្លឹកជូនថា ក្រសួងបរិស្ថានបាននិងកំពុងរៀបចំយុទ្ធសាស្ត្រចក្រាបរិស្ថាន ឆ្នាំ២០២៣-២០២៨ នឹងគ្រោងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ខាងមុខក្នុងគោលបំណងតម្រង់ទិសដើម្បីអនុវត្តការងារអាទិភាពក្នុងមុំអាទិភាពចំនួនបីគឺ៖ ស្អាត បៃតង និងចីរភាព ឆ្ពោះទៅរកការសម្រេចបាននូវអព្យាក្រឹតកាបូន ៕

រយៈពេលជាង ២ ខែ
នៃយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ

## «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»

មានខេត្តចំនួន ១៣ និងស្ថាប័នចំនួន ៥ បានចុះអនុស្សរណៈយោគយល់ជាមួយក្រសួងបរិស្ថានដោយមានអ្នកចូលរួមក្នុងយុទ្ធនាការផ្ទាល់ប្រមាណ ៣លាននាក់ ខណៈយុទ្ធនាការនេះនឹងបន្តធ្វើទូទាំងប្រទេស។



យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ត្រូវបានផ្តួចផ្តើមឡើងដោយ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងចាប់ផ្តើមអនុវត្តឡើងកាលពីថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២៣ ដោយគិតត្រឹមថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មានរយៈពេលជាង ២ ខែមកហើយដោយមានខេត្តចំនួន១៣ អង្គការចំនួន២ សមាគមចំនួន ២ ព្រមទាំងកាកបាទក្រហមកម្ពុជាបានចុះអនុស្សរណៈយោគយល់ (MoU) ជាមួយក្រសួងបរិស្ថាន។

សម្រាប់ខេត្តចំនួន១៣ ដែលបានចុះ MoU ជាមួយក្រសួងបរិស្ថានរួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ ក្រចេះ កណ្តាល ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី កំពត កែប ព្រះសីហនុ កោះកុង កំពង់ស្ពឺ និងខេត្តតាកែវ ជាដើម។

ចំណែកអង្គការ សមាគមដែលចុះ MoU រួមមាន កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) សមាគមកាយឫទ្ធិនារីកម្ពុជា និងសហភាពសហព័ន្ធយុវជនកម្ពុជា។





ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានលើកឡើងនៅក្នុងពិធីចុះ MoU រវាងក្រសួងបរិស្ថាន និងរដ្ឋបាលខេត្តចំនួន៦ រួមនឹងសមាគមកាយឫទ្ធីនារីកម្ពុជា និងសហភាពសហព័ន្ធយុវជនកម្ពុជា កាលពីថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ ថា ក្រសួងបរិស្ថានសូមវាយតម្លៃខ្ពស់ចំពោះយុទ្ធនាការនេះ ដែលបានបញ្ជ្រាបទៅដល់ពលរដ្ឋទូទាំងប្រទេសតាមរយៈ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ទៅដល់សហគមន៍ និងមូលដ្ឋានរស់នៅរបស់ប្រជាពលរដ្ឋ។

ឯកឧត្តមថ្លែងបន្តថា៖ «យុទ្ធនាការនេះបាននិងកំពុងដោះស្រាយបញ្ហាប្លាស្ទិកយ៉ាងសំខាន់នៅកម្ពុជា ហើយនឹងជួយឱ្យកម្ពុជាស្អាត នាពេលដ៏ខ្លីខាងមុខ» ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រីក៏បានបង្ហាញសុទិដ្ឋិនិយមយ៉ាងមុតមាំថា ស្មារតីនៃយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក នឹងនៅចងចាំជានិច្ច ចំពោះការចូលរួមពីសំណាក់បងប្អូនប្រជាពលរដ្ឋនាពេលនេះ ហើយសូមបន្តការផ្សព្វផ្សាយទៅមិត្តភក្តិ បងប្អូន ក្រុមគ្រួសារពីការមិនប្រើប្រាស់ថង់ប្លាស្ទិកយ៉ាងតិច ១ ថ្ងៃ និងពង្រីកទៅ ២ថ្ងៃ ៣ថ្ងៃ ឬ ៤ថ្ងៃ ក្នុង ១សប្តាហ៍ ដើម្បីឱ្យសាលារៀន លំនៅស្ថាន និងភូមិ-ឃុំ គ្មានសំរាមប្លាស្ទិក សំដៅធានាបានការរស់នៅស្អាត បរិស្ថានបៃតង និងការអភិវឌ្ឍដោយចីរភាព ឈានឆ្ពោះកម្ពុជាទៅជាប្រទេសអព្យាក្រឹត្យកាបូន។

អភិបាលរងខេត្តព្រះសីហនុលោក ឡុង ឌីម៉ង់ បានថ្លែងនៅថ្ងៃទី ១៩ ខែវិច្ឆិកាថា សម្រាប់ខេត្តព្រះសីហនុមានឆន្ទៈពិតប្រាកដក្នុងការអនុវត្តគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថានជាពិសេសក្នុងកិច្ចការងាររួមគ្នាកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។ លោកបានបន្ថែមថា៖ «យើងដឹងថាការប្រើប្រាស់ថង់ឬផលិតផលប្លាស្ទិកមិនអាចចៀសផុតបានទេក្នុងពេលបច្ចុប្បន្ននេះ ប៉ុន្តែដើម្បីការពារបរិស្ថាន យើងចាំបាច់រួមគ្នាកាត់បន្ថយប្លាស្ទិកដែលអាចធ្វើទៅបាន»។

លោកថ្លែងឡើងទៀតថា ក្នុងចំណោមខេត្តផ្សេងៗទៀតនៅជាប់សមុទ្រ ខេត្តព្រះសីហនុយកចិត្តទុកដាក់ខ្ពស់ចំពោះការកាត់បន្ថយការបំពុលដោយសំណល់ថង់ប្លាស្ទិកនៅក្នុងសមុទ្រ។ យន្តការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកនេះ គឺដើម្បីថែរក្សាបរិស្ថាន សុខុមាលភាពរបស់មនុស្សជាតិក៏ដូចជាសត្វសមុទ្រ ហើយយើងនឹងផ្សព្វផ្សាយអប់រំទៅដល់














ក្រុមគោលដៅដូចជាយុវជន សិស្សានុសិស្ស អាជីវករក៏ដូចជាសហគមន៍មូលដ្ឋាន ឱ្យបានយល់ដឹងពីផលប៉ះពាល់នៃសំណល់ប្លាស្ទិក។

ជាក់ស្តែងគិតត្រឹមថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣មានអ្នកស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការនេះសរុបចំនួនជិត ៣លានអង្គ/នាក់ ដែលក្នុងនោះ លោកគ្រូ អ្នកគ្រូ មានចំនួន ជាង ១១ម៉ឺននាក់ សិស្សានុសិស្ស សរុបជាង ២,៨ លាននាក់នៃសាលារៀនចំនួន ៦ ៦១៩ សាលា និងកម្មករនិយោជកព្រះសង្ឃនិងប្រជាពលរដ្ឋនៅតាមបណ្តារោងចក្រសហគ្រាស វត្តអារាម និងសហគមន៍នានា។

ស្របគ្នានេះអភិបាលខេត្តកំពង់ស្ពឺ លោក វ៉ី សំណាង ក៏បានថ្លែងឱ្យដឹងដែរថា តាមរយៈការអនុវត្តយុទ្ធនាការកាត់បន្ថយប្លាស្ទិកនេះ អាជ្ញាធរខេត្តបានផ្សព្វផ្សាយទៅដល់ប្រជា-ពលរដ្ឋនៅតាមគោលដៅបានជាង ៣ម៉ឺននាក់ហើយ និងកំពុងធ្វើជាបន្តបន្ទាប់ទៀត។ លោកបន្តថា៖«គោលដៅរបស់យើងផ្សព្វផ្សាយទៅកាន់ប្រជាពលរដ្ឋ អ្នកពាក់ព័ន្ធ រោងចក្រ








សហគ្រាសទាំងអស់ ធ្វើយ៉ាងណាឱ្យគាត់ចូលរួមកាត់បន្ថយប្រើប្រាស់ថង់ប្លាស្ទិកឱ្យបានជាអតិបរមា»។

សូមបញ្ជាក់ថា ការប្រើប្រាស់សម្ភារប្លាស្ទិកនៅលើពិភពលោក បាននិងកំពុងបង្កជាបញ្ហាដល់បរិស្ថាន និងសុខុមាលភាព មនុស្ស សត្វលើភពផែនដី។ មកទល់ឆ្នាំ ២០២២ នៅទូទាំងពិភពលោកបានផលិត និងប្រើប្រាស់សម្ភារប្លាស្ទិកជាង ៩,៥ ពាន់លានតោន ក្នុងអត្រាកំណើន ៣ភាគរយ ជារៀងរាល់ឆ្នាំ។ ( ប្រភពពី OECD´s Global Plastics Outlook )

ក្រោយពីការប្រើប្រាស់សំណល់ប្លាស្ទិកប្រមាណ ៩ភាគរយ នៃបរិមាណសំណល់ប្លាស្ទិកសរុប ដែលបានយកមកកែច្នៃផលិតឡើងវិញ រីឯសំណល់ប្លាស្ទិក៩១ភាគរយទៀតត្រូវបានយកទៅទីលានទុកដាក់សំរាម ឬដុតចោល និងចោលរាយប៉ាយតាមទីវាល រួចបន្តធ្លាក់ចូលទៅក្នុងប្រភពទឹកហូរចាក់ចូលទៅក្នុងសមុទ្រប្រមាណជាង៨លានតោនក្នុង១ឆ្នាំ។

ដោយឡែកនៅកម្ពុជា កត្តារីកចម្រើននៃសេដ្ឋកិច្ចជាតិ កំណើនជីវភាពរបស់ប្រជាពលរដ្ឋ គួបផ្សំនឹងភាពស៊ីវិល័យ














របស់សង្គមនិងការរស់នៅបានធ្វើឱ្យការប្រើប្រាស់សម្ភារប្លាស្ទិក មានការកើនឡើងក្នុងកម្រិតខ្ពស់ ពិសេសថង់ប្លាស្ទិក ដោយប្រជាជនកម្ពុជាម្នាក់ប្រើថង់ប្លាស្ទិកជាមធ្យម៤ថង់ក្នុង ១ថ្ងៃ គឺប្រមាណជា៥៥លានថង់ប្លាសិកប្រើប្រាស់ក្នុង១ថ្ងៃនៅកម្ពុជា៕




យើងរួមកម្លាំងគ្នា ការពារបរិស្ថានកម្ពុជា






ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ











## ជាក់ស្តែងសមិទ្ធផលនៃកម្លាំងសាមគ្គីដ៏ផុសផុល ពីសំណាក់ប្រជាពលរដ្ឋកម្ពុជាជិត ១០លាននាក់ បាន ធ្វើឱ្យចំនួននៃការនាំចូលថង់ប្លាស្ទិកថយចុះជាលំដាប់ (សូមអានតួលេខខាងក្រោម)

«ការនាំចូលថង់ប្លាស្ទិកមានការថយចុះប្រមាណ៥០%នៅចុងឆ្នាំ២០២៣ និងថយចុះប្រមាណ ៨០% ក្នុងរយៈពេលដូចគ្នានៅខែមករា ឆ្នាំ២០២៤ ធៀបនឹង ឆ្នាំ២០២៣» នេះជាតួលេខមួយ ដែលឆ្លុះបញ្ចាំងពីឥទ្ធិពលនៃការផ្សព្វផ្សាយបញ្ជ្រាប ចំណេះដឹងសាធារណៈ ជំរុញការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថជាវិជ្ជមានចំពោះបរិស្ថាន។








## វប្បធម៌ស្អាតផ្ដើមចេញពីបេះដូងប្រជាពលរដ្ឋកម្ពុជា កំពុងទទួលបានលទ្ធផលគួរជាពេញចិត្ត

លទ្ធផលដែលកើតចេញពីការប្ដេជ្ញាចិត្តកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិករបស់សិស្សានុសិស្ស រួមនឹងប្រជាពលរដ្ឋប្រមាណជាង ៤លាននាក់ ទទួលបានលទ្ធផលជាផ្លែផ្កា ហើយ តាមរយៈការថយចុះនៃការនាំចូលថង់ប្លាស្ទិកជាង ៣២ពាន់គីឡូក្រាមស្មើនឹង៤៩% នៅក្នុងត្រីមាសទី៣ និងទី៤ឆ្នាំ២០២៣។ នេះបើយោងតាមទិន្នន័យនាំចូលថង់ប្លាស្ទិករបស់នាយកដ្ឋានគ្រប់គ្រងសំណល់រឹងនៃ ក្រសួងបរិស្ថាននៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤។

ជាមួយគ្នានេះ ការប្រៀបធៀបលើទិន្នន័យនាំចូលរបស់ក្រុមហ៊ុនឯកជនដែលបាននាំចូលប្លាស្ទិកក្នុងគោលដៅសម្រាប់បម្រើសេវាវេចខ្ចប់ទំនិញក្នុងសង្វាក់ផលិតកម្មរបស់ខ្លួន សម្រាប់ប្រកសំរាម និងវេចខ្ចប់អាហារ នៅដើមត្រីមាសទី១ឆ្នាំ២០២៣ មានការនាំចូលថង់ប្លាស្ទិករហូតដល់ទៅជាង ៦២ពាន់គីឡូក្រាម តែមកដល់ត្រីមាសទី១ឆ្នាំ២០២៤ បែរជា









ធ្លាក់ចុះមកត្រឹមតែចំនួនជាង ១២ពាន់គីឡូក្រាមប៉ុណ្ណោះ ហើយដែលចំនួននេះមានការធ្លាក់ចុះចំនួនថង់ប្លាស្ទិកជាង ៥០ពាន់គីឡូក្រាម ស្មើនឹង៨០%។

យោងតាមប្រភពដដែលនេះបានបង្ហាញថា ការថយចុះនៃការនាំចូលថង់ប្លាស្ទិក គឺមាននិន្នាការថយចុះរហូតរាប់ចាប់ពីក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ កន្លងទៅ។









## យុទ្ធនាការ "ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ"

### តួលេខចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់បច្ចុប្បន្ន

| ពិពណ៌នា | ចំនួនការចូលរួម | សន្ទុះនៃការចូលរួម | កម្រិតកើន |
|---|---|---|---|
| សាលារៀនចំនួន ១២ ១៩៩ សាលាបានចូលរួម | ១២ ១៩៩ | ១00% | កើន |
| លោកគ្រូ អ្នកគ្រូបានចូលរួម | ១៥0 ៧៤៩ | ១00% | កើន |
| សិស្សានុសិស្សបានចូលរួម និងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ១ថ្ងៃ (៤ថង់) | ៣ ៦៦១ ៧៥២ | ១00% | កើន |
| ចំនួនវត្តអារាម ៤១៩វត្ត | ៤១៩ | ១00% | កើន |
| សង្ឃចំនួន ១០ ៣៩២អង្គ | ១0 ៣៩២ | ១00% | កើន |
| មន្ត្រីរាជការ ៨៥ ៣៧១នាក់ | ៨៥ ៣៧១ | ១00% | កើន |
| ចំនួនប្រជាពលរដ្ឋ/និយោជិត ៥ ៦៧៥ ៤៩៥នាក់ | ៥ ៦៧៥ ៤៩៥ | ១00% | កើន |
| សរុបចំនួនអ្នកចូលរួមប្តេជ្ញាចិត្តកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក | ៩ ៥៩៦ ៣៧៧ | ១00% | កើន |


ថ្ងៃ
នេះ
ខ្ញុំ
មិន
ប្រើ
ថង់
ប្លា
ស្ទិក
ទេ

## ព័ត៌មានដែលបានផ្សព្វផ្សាយ
## ភាពស្អាតដែលសាយភាយចេញពីបេះដូងប្រជាពលរដ្ឋខ្មែរ បានធ្វើឱ្យរមណីយដ្ឋានអង្គរកាន់តែល្បីរន្ទឺឡើង

ភាពវិជ្ជមាននៃកំណើនកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក បានលេចឡើងជាបន្តបន្ទាប់រាប់ចាប់ពីសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ អាជ្ញាធរមូលដ្ឋាន ប្រជាសហគមន៍ ព្រះសង្ឃ ប្រជាពលរដ្ឋ និង កម្មករកម្មការិនី ហើយឥឡូវនេះបានបន្តដល់អាជ្ញាធរជាតិអប្សរាហើយ ដោយថ្មីៗនេះ អាជ្ញាធរជាតិអប្សរាបានប្រកាសព្យាយាមកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក តាមរយៈការប្រើរបងឫស្សីហ៊ុមព័ទ្ធតាមការដ្ឋានជួសជុល ជំនួសឱ្យការប្រើប្លាស្ទិកគ្រប។

បន្ទាប់ពីបានឃើញការចេញផ្សាយអត្ថបទអមដោយរូបភាពរបស់អាជ្ញាធរជាតិអប្សរានេះ ប្រជាពលរដ្ឋអ្នកស្រឡាញ់បរិស្ថានបានគាំទ្រយ៉ាងខ្លាំងចំពោះការអនុវត្តបែបនេះរបស់អាជ្ញាធរជាតិអប្សរា ហើយពួកគាត់យល់ឃើញថា ការផ្ដើមជាគំរូស្អាតចេញពីតំបន់រមណីយដ្ឋានអង្គរ នឹងធ្វើឱ្យកេរ្តិ៍ឈ្មោះ













ប្រាសាទអង្គរវត្តខ្មែរកាន់តែល្បីរន្ទឺឡើង ល្បីត្រង់ថាអង្គរជាបេតិកភ័ណ្ឌល្អឯកតែមួយគ្មានពីរហើយ នៅជុំវិញបរិវេណជុំអង្គរក៏ស្អាត មិនមានការបំពុលដោយសំណល់ប្លាស្ទិចទៀត ហើយចំណែកឯការតម្រៀបឫស្សីធ្វើជារបងហ៊ុមព័ទ្ធតាមការដ្ឋានជួសជុលអង្គរនេះទៀតសោត គឺបានផ្តល់សម្រស់ល្អមួយបែបផង និងជួយបង្កើនចំណូលដល់ប្រជាសហគមន៍អ្នកដាំឫស្សីផង។

គួរជម្រាបជូនថា ការប្រើប្រាស់វត្ថុធាតុដើមធម្មជាតិដូចជាដើមឫស្សីជំនួសប្លាស្ទិចនេះ នឹងផ្តល់ការងារកាន់តែច្រើនដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ធ្វើឱ្យបរិស្ថាននៅតាមការដ្ឋានក្នុងឧទ្យានអង្គរកាន់តែប្រសើរឡើង។ នេះបើយោងតាមការចុះផ្សាយលើគេហទំព័រផ្លូវការ របស់អាជ្ញាធរជាតិអប្សរានៅថ្ងៃទី០៨ កុម្ភៈ ឆ្នាំ២០២៤៕

## ជំហានទី២ ៖ «កម្ពុជាស្អាត ខ្មែរធ្វើបាន»

បានចាប់ផ្ដើមនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ មានអ្នកចូលរួមចំនួន ៤០០នាក់ និងនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ មានអ្នកចូលរួម ១.៥៧៣នាក់ (នៅស្រុកអូររាំងឪ) ដើម្បីបំផុសចលនាប្រមូលមហាជនធ្វើការប្ដេជ្ញាចិត្តចូលរួមគាំទ្រយុទ្ធនាការនេះឱ្យបាន១ដងក្នុងមួយសប្ដាហ៍ ហើយក្នុងមួយដងមានរយៈពេល១៥នាទី។

អ្នកដែលបានចូលរួមក្នុងយុទ្ធនាការជំហានទី១ បាន និងកំពុងបន្តចូលរួមអនុវត្តក្នុងយុទ្ធនាការ «កម្ពុជាស្អាត ខ្មែរធ្វើបាន» ដោយបានចូលរួមសំអាតសំរាម ថង់ប្លាស្ទិកតាមទីសាធារណៈ តាមដងផ្លូវ និងជុំវិញលំនៅដ្ឋាន កន្លែងធ្វើការ រោងចក្រ សហគ្រាស។ ជាលទ្ធផល មានអ្នកចូលរួមសរុបទូទាំងប្រទេសចំនួន ២.៣៩២.២៧១អង្គ/នាក់។ ក្រសួងបរិស្ថានកំពុងតែខិតខំដឹកនាំយុទ្ធនាការនៅទូទាំងប្រទេស ដើម្បីជំរុញសម្រេចឱ្យបានទៅជាចលនាជាតិ និងបន្តរហូតឱ្យ




ក្លាយទៅជាទម្លាប់ដើម្បីផ្លាស់ប្ដូរផ្នត់គំនិតចូលរួមអនុវត្តជាប្រចាំ។

ជាលទ្ធផល រហូតដល់ពេលនេះឃើញថា សំរាម ថង់ប្លាស្ទិកដែលចោលរាយប៉ាយតាមដងផ្លូវកន្លងមកត្រូវបានកាត់បន្ថយប្រមាណ ៨០% បើធៀបទិដ្ឋភាពជាក់ស្ដែងតាមដងផ្លូវកាលពីជាងមួយឆ្នាំមុននេះ។ មួយទៀតបច្ចុប្បន្ននេះ ចលនានៃការអនុវត្ត «កម្ពុជាស្អាត ខ្មែរធ្វើបាន» ត្រូវបានដឹកនាំអនុវត្តតាមសាលារៀន វត្តអារាម រោងចក្រ និងតាមភូមិ ឃុំ ស្រុក ខេត្ត រាជធានី ដោយខ្លួនឯងជាប្រចាំ ហើយសង្ឃឹមថានៅក្នុងឆ្នាំ ២០២៥ នឹងមិនមានសំរាមប្លាស្ទិកចោលរាយប៉ាយតាមដងផ្លូវទូទាំងប្រទេសទៀតនោះទេ។

ត្រឹមតែរយៈពេលជាង ៥ខែ ប៉ុណ្ណោះ ចលនាស្អាតដែលកើតចេញពីវប្បធម៌ស្អាត របស់ប្រជាពលរដ្ឋកម្ពុជាជាង ២លានអង្គ/នាក់ បានកំពុងរីកសាយភាយចលនានៃការសំអាតនៅតាមក្រុង/ស្រុក/ខណ្ឌចំនួន ១៥៤នៃចំនួនក្រុង/ស្រុក/ខណ្ឌសរុប ២០៦ នៅទូទាំងប្រទេសកម្ពុជា ហើយចំនួននេះបានទាក់ទាញការចាប់អារម្មណ៍ពីសំណាក់អ្នកសារព័ត៌មានជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ឱ្យមកចូលរួមជាមួយគ្នា ដើម្បីប្រយុទ្ធប្រឆាំងការបំពុលដោយប្លាស្ទិកនេះ៕





យុទ្ធនាការ
«កម្ពុជាស្អាត ខ្មែរធ្វើបាន»

បានដាក់ចេញបន្ទាប់ពីកម្ពុជាយើងបានទប់ស្កាត់
ការពារការប្រើប្រាស់និងបោះចោលថង់ប្លាស្ទិក
បានច្រើនជាងការបោះចោល ទៅក្នុងទីសាធារណៈ
ទទួលបានជោគជ័យរួចមកហើយ









ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត៖ យុទ្ធនាការ «កម្ពុជាស្អាត ខ្មែរធ្វើបាន» ដែលបានដាក់ចេញកាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ គឺជាយុទ្ធនាការជំហានបន្ទាប់ពីកម្ពុជាទទួលបានជោគជ័យក្នុងការកាត់បន្ថយការប្រើប្រាស់ និងការបោះចោលថង់ប្លាស្ទិកពីសំណាក់សិស្សានុសិស្ស និងប្រជាពលរដ្ឋជាងពាក់កណ្តាលនៃចំនួនប្រជាពលរដ្ឋកម្ពុជាសរុប។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្តទៀតថា យុទ្ធនាការ «កម្ពុជាស្អាត ខ្មែរធ្វើបាន» នេះបានបង្ហាញយ៉ាងច្បាស់ពីការតាំងចិត្តចូលរួមពីខ្មែរទូទាំងប្រទេស ទន្ទឹមគ្នាជាមួយនឹងយុទ្ធនាការ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» ដែលបានដាក់ចេញកាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ រហូតមកដល់ពេលនេះ ទទួលបានការចូលរួម និងប្តេជ្ញាចិត្តកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកពីសំណាក់សិស្សានុសិស្ស និងប្រជាជនចំនួនជាង ៨លានអង្គ/នាក់នៅទូទាំងប្រទេសកម្ពុជា។

សូមបញ្ជាក់ជូនថា យុទ្ធនាការ «កម្ពុជាស្អាត ខ្មែរធ្វើបាន» គឺជាយុទ្ធនាការជំហានទី២ ដែលបន្ទាប់ពីប្តេជ្ញាចិត្តរួច ឈានដល់អនុវត្តផ្ទាល់ គឺស្នើសុំឱ្យសិស្ស បងប្អូនប្រជាពលរដ្ឋមួយភូមិ ឬមួយឃុំ ឬមួយស្រុក ឬមួយខេត្ត ចេញមកទាំងអស់គ្នារើសសំរាមជុំវិញបរិវេណផ្ទះ សាលារៀន វត្តអារាម និងតាមទីសាធារណៈ ចំនួន១៥នាទី រៀងរាល់ថ្ងៃសៅរ៍ ដោយប្រមូលទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។

ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានថ្លែងថា ភាពស្អាត និងសុខភាពប្រជាពលរដ្ឋជាការងារអាទិភាព ដែលរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងអាណត្តិទី៧ បាននឹងកំពុងយកចិត្តទុកដាក់។ ការសម្អាតអនាម័យបរិស្ថាននៅតាមមូលដ្ឋាន ប្រមូលទុកដាក់សំរាម រួមទាំងការកាត់បន្ថយសំណល់ប្លាស្ទិក ដែលឈានទៅបញ្ឈប់ការប្រើប្រាស់ប្លាស្ទិក ក្នុងចំណោមយុវជនជំនាន់ក្រោយ ធានាការគ្រប់គ្រងសំរាម ថែរក្សាអនាម័យបរិស្ថាន និង សុខុមាលភាពប្រជាពលរដ្ឋ បានល្អប្រសើរ ស្របនឹងភាពស្អាត ដែលជាមុំយុទ្ធសាស្ត្រអាទិភាពទី១ ចែងក្នុងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន៕











### យុទ្ធនាការ “កម្ពុជាស្អាត_ខ្មែរធ្វើបាន”
### (ទិន្នន័យមិនទាន់គ្រប់មន្ទីររាជធានី-ខេត្ត)
គួលេខចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ រហូតបច្ចុប្បន្ន

| ពិពណ៌នា | ការចូលរួម | សន្ទុះនៃការចូលរួម | កម្រិតកើន |
|---|---|---|---|
| ចំនួនសាលារៀន ៣ ៩៥៣សាលា | ៣ ៩៥៣ | ២៤.៣៣% | **កើន** |
| ចំនួនលោកគ្រូអ្នកគ្រូ ៥១ ៦៨៥នាក់ | ៥១ ៦៨៥ | | |
| សិស្សានុសិស្សចំនួន ២ ១៣៧ ៧៩៨នាក់ | ២ ១៣៧ ៧៩៨ | ៦៤.៥៣% | **កើន** |
| ចំនួនវត្តអារាម ៤៦៤វត្ត | ៤៦៤ | | |
| ព្រះសង្ឃចំនួន ៨ ០៥៣អង្គ | ៨ ០៥៣ | | |
| មន្ត្រីរាជការចំនួន ៤២ ៦១៦នាក់ | ៤២ ៦១៦ | | |
| ប្រជាពលរដ្ឋ/និយោជិតចំនួន ២៣៧ ៥១៤នាក់ | ២៣៧ ៥១៤ | | |
| អ្នកចូលរួមសរុបចំនួន: ២ ៤៧៧ ៦៦៦ អង្គ/នាក់ | ២ ៤៧៧ ៦៦៦ | ២ ៤៧៧ ៦៦៦ | **កើន** |
| ឃុំ/សង្កាត់ចំនួន ១ ៦៤៩ នៅទូទាំងរាជធានីខេត្ត | ៨៨៤ | ៨៨៤ | **កើន** |
| ក្រុង/ស្រុក/ខណ្ឌ ២០៦ នៅទូទាំងរាជធានីខេត្ត | ១៥៤ | ១៥៤ | **កើន** |

## ជំហានទី៣៖ ការដាក់ចេញនូវយុទ្ធនាការ “ទុកដាក់សំរាម និង ការញែកសំរាម”

ក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធនាការបន្ត តាមរយៈការចែកធុងសំរាមតាមសាលារៀន វត្តអារាម មណ្ឌលសុខភាព ទីសាធារណៈដើម្បី៖

- សិស្សានុសិស្ស និងប្រជាពលរដ្ឋទុកដាក់ប្លាស្ទិកក្នុងធុងសំរាម
- ជំរុញការអនុវត្តគោលការណ៍ធនាគារសំរាម
- ជំរុញការអនុវត្តគោលការណ៍ 4R

ដើម្បីឆ្លើយតបការគ្រប់គ្រងគុណភាពបរិស្ថានប្រកបដោយប្រសិទ្ធភាព ជាពិសេសហេដ្ឋារចនាសម្ព័ន្ធទីលានទុកដាក់សំរាម ប្រកបដោយគុណភាព ជៀសវាងការខ្វះខ្វាយថវិការដ្ឋ ថវិកាកម្ចី និងពេលវេលា ព្រមទាំងការប៉ះពាល់ដល់កិត្តិយសស្ថាប័ន និងថ្នាក់ដឹកនាំទទួលបន្ទុក អគ្គគាំពារ អគ្គសហគ្រាសគ្រប់គ្រងស្ថានីយ៍ផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង (សទស) រួមទាំងអង្គភាពពាក់ព័ន្ធ។

ការតាមដាន វាយការណ៍ និងលើកយោបល់អំពីវិធានបច្ចេកទេសដូចជា៖

- ០ ប្រតិបត្តិការទីលានចាក់សំរាម
- ០ គុណភាពទីលានចាក់សំរាម
- ០ ការរៀបចំទីលានទុកដាក់សំរាម










កម្ពុជាស្អាត ខ្មែរធ្វើបាន






DEPOT TELA
យុទ្ធនាការ «កម្ពុជាស្អាត ខ្មែរធ្វើបាន» ឃុំចក






oppo
កម្ពុជាស្អាត ខ្មែរធ្វើបាន

# យុទ្ធនាការចែកធុងសំរាម ការគ្រប់គ្រងសំរាម ការញែកសំរាម និងការទុកដាក់សំរាម

ក្រសួងបរិស្ថានផ្តល់ធុងសំរាមដល់រដ្ឋបាលឃុំ សាលារៀន មណ្ឌលសុខភាព និងវត្តអារាមនៅខេត្តត្បូងឃ្មុំ ដើម្បីជំរុញភាពស្អាតរបស់កម្ពុជា

ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានប្រគល់ធុងសំរាម ចំនួន ៤០៤ធុងបន្ថែមទៀត ជូនដល់រដ្ឋបាលស្រុកពញាក្រែក សម្រាប់ចែកជូនដល់រដ្ឋបាលឃុំ សាលារៀន មណ្ឌលសុខភាព និងវត្តអារាម ដើម្បីពង្រឹងភាពស្អាតនៅតាមមូលដ្ឋាន ជាពិសេសចូលរួមជំរុញចលនាយុទ្ធនាការគ្មានប្លាស្ទិកនៅតាមផ្លូវនៅឆ្នាំ២០២៥ខាងមុខនេះ។

ពិធីប្រគល់ និងទទួលធុងសំរាម បានរៀបចំឡើងក្រោមអធិបតីភាពឯកឧត្តម ខ្វៃ អាទិត្យា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ខេត្តត្បូងឃ្មុំ និងមានការអញ្ជើញចូលរួមដោយ



ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងបរិស្ថាន រួមទាំងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន និងក្រុមការងារគណបក្ស ចុះមូលដ្ឋានស្រុកពញាក្រែក តំណាងគណៈអភិបាលខេត្តត្បូងឃ្មុំ អាជ្ញាធរគ្រប់លំដាប់ថ្នាក់នៃស្រុកពញាក្រែក កងកម្លាំងប្រដាប់អាវុធ សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ និងប្រជាពលរដ្ឋជាច្រើននាក់ កាលពីថ្ងៃអាទិត្យ ទី២៧ ខែតុលា ឆ្នាំ២០២៤ ក្នុងសាលា បឋមសិក្សាក្រែកក្នុងឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

សូមជម្រាបថា ការផ្តល់ជូនធុងទុកដាក់សំរាមនេះ គឺជាការថ្លែងអំណរគុណចំពោះសិស្សានុសិស្ស និងប្រជាពលរដ្ឋ ហើយក្រោមកិច្ចសហការទាំងនេះ ក៏មានការរួមចំណែកពីស្ថាប័នរដ្ឋ វិស័យឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ដែលបានចូលរួមក្នុងយុទ្ធនាការ កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកជាមួយក្រសួងបរិស្ថាន រហូតសម្រេចបាននូវផែនការសកម្មភាពនៃយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន អនុលោមតាមសសរស្តម្ភ ៣គឺ «ភាពស្អាត ភាពបៃតង និងចីរភាព» និងដើម្បីគាំទ្រដល់ក្រុង ស្រុក ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ឯកឧត្តមរដ្ឋមន្ត្រី






ក្រសួងបរិស្ថាន បានរៀបចំធុងសំរាម ផ្តល់ជូនដល់រដ្ឋបាលក្រុង ស្រុក សម្រាប់ចែកជូនដល់គ្រប់គ្រឹះស្ថានសិក្សា មូលដ្ឋានសុខាភិបាល វត្តអារាម រដ្ឋបាលឃុំ-សង្កាត់ទូទាំងខេត្តត្បូងឃ្មុំ និងជាបន្តបន្ទាប់ទៅកាន់មូលដ្ឋានស្រុក ក្រុង នៃខេត្តនានាទូទាំងប្រទេស។



# សមិទ្ធផលដែលសំរេចបាននៅជំហានទី៣ នៃភាពស្អាតលើដែនគោក




ក្រសួងបរិស្ថានផ្តល់ជូនធុងសំរាមនៅតាមសាលារៀន មណ្ឌលសុខភាព វត្តអារាម និងទីសាធារណៈនានានៅក្នុងខេត្តត្បូងឃ្មុំសរុបចំនួន ១ ០០០ធុង។ ផែនការបន្ទាប់ក្រោយពីប្រកាសបើកយុទ្ធនាការជំហានទី ៣រួច នឹងបន្តចែកជូនទូទាំងប្រទេស។ ការពន្យល់ណែនាំដល់ប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់ធុងសំរាមតាមទីតាំងដែលបានចែកជូនពីរបៀបញែកសំរាម និងទុកដាក់សំរាមក្នុងធុងឱ្យបានត្រឹមត្រូវទៅតាម ប្រភេទធុងសំរាម ដែលបានចែកជូនក្នុងមួយទីតាំងចំនួន២ មួយសម្រាប់សំណល់រឹង និងប្លាស្ទិក ហើយមួយទៀតសម្រាប់សំណល់ផ្ទះបាយ

• ការផ្ទេរមុខងារទទួលខុសត្រូវ៖ បច្ចុប្បន្ន ក្រសួងបរិស្ថានបានផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុករួចហើយ។ ជាក់ស្តែងនៅរាជធានីភ្នំពេញមានក្រុមហ៊ុនឯកជនទទួលខុសត្រូវប្រមូលដឹកជញ្ជូន ទុកដាក់ ញែកសំរាមនៅតាមទីលានទុកដាក់សំរាមចំនួន០៣ក្រុមហ៊ុន ហើយនៅតាមខេត្ត ក្រុង ទីប្រជុំជននានាទូទាំង២៤ ខេត្ត ក៏មានក្រុមហ៊ុនទទួលខុសត្រូវដោយឡែកៗផងដែរ

• បង្កើតទីលានទុកដាក់សំរាម៖ បានបិទបញ្ចប់ទីតាំងទុកដាក់សំរាមចាស់ចំនួន១ទីតាំងនៅសង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ

• ទីលានកំពុងដំណើរការមាន៩ទីតាំង ( កំពត កំពង់ឆ្នាំង ពោធិ៍-សាត់ បាត់ដំបង កំពង់ធំ ក្រចេះ កែប ព្រះសីហនុ និងស្វាយរៀង )

• បានបញ្ចប់សាងសង់ទីលានទុកដាក់សំរាមកម្រិតខេត្ត បានចំនួន ១ទីតាំង (ស្ទឹងត្រែង) និងកំពុងសាងសង់ចំនួន២ទីតាំង (កំពង់ចាម និងបន្ទាយមានជ័យ)។ កំពុងដំណើរការគម្រោង ៣ទីតាំង (កណ្តាល កំពង់ស្ពឺ និងសៀមរាប) និងកំពុងសិក្សាមាន២ទីតាំង (នៅស្វាយរៀង និងត្បូងឃ្មុំ)

• បាន និងកំពុងសាងសង់ទីលានទុកដាក់សំរាម សំណល់រឹងកម្រិតតំបន់ប្រកបដោយអនាម័យសម្រាប់រាជធានីភ្នំពេញ ១ទីតាំង (រយៈពេលប្រើប្រាស់២៥ឆ្នាំ)

• បានប្រមូលចងក្រងទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង ( ឆ្នាំ២០២៣ )

• ទិន្នន័យបរិមាណសំរាម សំណល់រឹងទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុកទូទាំងប្រទេស មានសរុបចំនួន ២ ៦៧៥ ៦២៨ តោន

• ទិន្នន័យសំណល់អាចកែច្នៃនៅទូទាំងប្រទេសមានចំនួន ២៥៩ ៩៩១ តោន

• បានចុះពិនិត្យការផ្ដល់សេវាប្រមូលសំរាមសំណល់រឹង ទីប្រជុំជន និងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដើម្បីផ្ដល់ការគាំទ្របច្ចេកទេសនៅខេត្តចំនួន១០ (ខេត្តកំពង់-ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន កំពង់ធំ សៀមរាប ត្បូងឃ្មុំ ស្វាយរៀង និងខេត្តកោះកុង) និងគាំទ្របង្កើតឱ្យមានការផ្ដល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន សំរាម សំណល់រឹងទីប្រជុំជននៅក្រុងស្រុកចំនួន ៤ (ស្រុកវាលវែង ខេត្តពោធិ៍សាត់ ស្រុកគិរីវង់ខេត្តតាកែវ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ)

• បានកាត់បន្ថយការនាំចូលថង់ប្លាស្ទិចក្នុងរយៈពេល៧ខែដើមឆ្នាំ២០២៤នេះរហូតដល់៨៨% ដោយការនាំចូលមានត្រឹម ៣១ ៥៤៨,១៦គីឡូក្រាម (មានការថយចុះចំនួន







២៣៥.២០៥,៦២គីឡូក្រាម) ធៀបនឹងការនាំចូលក្នុងឆ្នាំ ២០២៣ ដែលមានរហូតដល់ចំនួន ២៦៦ ៧៥៣,៧៨ គីឡូក្រាម។



# ភាពស្អាតក្នុងទឹក

## យុទ្ធនាការ «ភាពស្អាតក្នុងទឹក»



ក្រសួងបរិស្ថានផ្ដើមយុទ្ធនាការសម្អាតទន្លេ
នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣







ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថានបានថ្លែងថា «គ្មានអ្វីមានតម្លៃជាងអាយុជីវិត និងសុខភាពរបស់បងប្អូនប្រជាពលរដ្ឋនោះឡើយ ហើយដើម្បីការពារអាយុ ជីវិត និងសុខភាព យើងត្រូវរួមគ្នាការពារបរិស្ថានក្នុងនោះត្រូវទប់ស្កាត់ឱ្យបានចំពោះការបង្ហូរទឹកកខ្វក់ចេញពីរោងចក្រ សហគ្រាស ចូលទៅក្នុងបឹង ស្ទឹង ទន្លេ និងសមុទ្រ»

តាមរយៈយុទ្ធនាការបំពាក់ឧបករណ៍តាមដានស្វ័យប្រវត្តិ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅតាមរោងចក្រ សហគ្រាសគឺជាយន្តការដែលមានប្រសិទ្ធភាព ឆ្លើយតបនឹងការគ្រប់គ្រងគុណភាពទឹករបស់នាយកដ្ឋានគ្រប់គ្រងគុណភាពទឹកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន។ ការបំពាក់ឧបករណ៍តាមដានស្វ័យប្រវត្តិ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅតាមរោងចក្រ សហគ្រាសចំពោះការបង្ហូរសំណល់រាវចេញនេះ រៀបចំឡើងក្នុងគោលដៅទប់ស្កាត់ការបំពុលទៅក្នុងផ្ទៃទឹក ដើម្បីការពារគុណភាពទឹក ការពារសុខភាពប្រជាពលរដ្ឋជាអ្នកប្រើប្រាស់ទឹក ការពារដល់ជីវចម្រុះ ដែលមានជីវិតក្នុងទឹកដូចជាត្រីរុក្ខជាតិ និងធនធានធម្មជាតិនៅក្នុងទឹក។






PLASTIC ODYSSEY








ទីតាំងបំពាក់ឧបករណ៍តាមដានស្វ័យប្រវត្តិ
និង
ប្រព័ន្ធគ្រប់គ្រងទិន្នន័យការបញ្ចេញសំណល់រាវ

## រោងចក្រសហគ្រាស ១៣កន្លែង បានបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យ

**គិតមកត្រឹមថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ រោងចក្រ សហគ្រាស និងតំបន់សេដ្ឋកិច្ចពិសេស ចំនួន១៣ កន្លែង បានរៀបចំបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យ ការបញ្ចេញសំណល់រាវ និងការបង្ហូរទឹកកខ្វក់ ដែលស្របទៅតាមច្បាប់នៃកម្ពុជា។**

ក្នុងរយៈពេលដូចគ្នានេះដែរ ក្រុមអ្នកជំនាញក៏បានបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យរួចរាល់នៅរោងចក្រសហគ្រាសចំនួន ៣ទីតាំងធំៗមុនគេរួមមានក្នុងខេត្តស្វាយ-រៀង និងខេត្តបាត់ដំបង ខណៈរោងចក្រសហគ្រាសចំនួន ៣ទីតាំងផ្សេងទៀត បានចុះកិច្ចសន្យាជាមួយក្រុមអ្នកជំនាញតម្លើង។ កន្លងមកនេះ រោងចក្រសហគ្រាសចំនួនជាង ១០០ទីតាំង ក៏បានស្នើសុំបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យតាមដានការបញ្ចេញសំណល់រាវ និងការបង្ហូរទឹកកខ្វក់ចេញពីរោងចក្រ ដើម្បីធានាថាសំណល់រាវបញ្ចេញពីមូលដ្ឋានរោងចក្រសហគ្រាសរបស់ខ្លួន មិនមានជាតិពុល មិនប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ និងកម្មករកម្មការិនី ដែលរស់នៅ និងកំពុងបំពេញការងារនៅតាមមូលដ្ឋានអាជីវកម្មរបស់ខ្លួន មុននឹងការបង្ហូរចេញទៅតាមប្រឡាយប្រភពទឹកនានា។

គួរបញ្ជាក់ថា ការបំពាក់ឧបករណ៍នេះគឺដើម្បីបញ្ចៀសការលេចជ្រាប ឬការលួចបង្ហូរសំណល់រាវ ដែលមានសារធាតុពុលចេញពីរោងចក្រសហគ្រាស ចូលទៅក្នុងប្រភពទឹក។ ក្រសួងបរិស្ថានតម្រូវឱ្យរោងចក្រ សហគ្រាស បំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យការបញ្ចេញសំណល់រាវ និងការបង្ហូរទឹកកខ្វក់ ដែលស្របទៅតាមច្បាប់នៃកម្ពុជា (ប្រភេទប្រភពបំពុលសក្តានុពល) ត្រូវអនុវត្តការបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យការបញ្ចេញសំណល់រាវ ស្របតាមយុទ្ធនាការរបស់ក្រសួងបរិស្ថាន ដើម្បីការពារបរិស្ថានកម្ពុជា លើកកម្ពស់ភាពស្អាត មានអនាម័យ សោភ័ណភាព និងសុខភាពសាធារណៈ គ្មានការបំពុលដោយសំរាមប្លាស្ទិច និងទឹកកខ្វក់៕

















### ពលរដ្ឋរស់នៅក្បែរតំបន់រោងចក្រសហគ្រាសគាំទ្រឱ្យរោងចក្រសហគ្រាស បំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យការបញ្ចេញសំណល់រាវ និងការបង្ហូរទឹកកខ្វក់







ប្រជាពលរដ្ឋរស់នៅនិងបំពេញការងារនៅតាមមូលដ្ឋានតំបន់រោងចក្រសហគ្រាស បានសម្តែងការសាទរ និងគាំទ្រចំពោះការតម្រូវឱ្យរោងចក្រសហគ្រាសឧស្សាហកម្ម ដែលបញ្ចេញសំណល់រាវចាំបាច់ត្រូវគោរពច្បាប់ តាមរយៈការបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យ តាមដានការបញ្ចេញសំណល់រាវ និងការបង្ហូរទឹកកខ្វក់ចេញពីរោងចក្រសហគ្រាស ដើម្បីតាមដានត្រួតពិនិត្យ ការបំពុលបរិស្ថានពីចម្ងាយ ដើម្បីធានាសុខភាពប្រជាពលរដ្ឋ និងបរិស្ថាន។

អ្នកស្រី ម៉េច សិរីរ័ត្ន អ្នកប្រកបរបរលក់ដូរ រស់នៅជាប់នឹងតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន ក្នុងសង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង បានសម្តែងការបារម្ភប្រសិនបើមានរោងចក្រឬសហគ្រាសណាបានបញ្ចេញទឹកពុលមកក្នុងប្រភពទឹក នឹងអាចប៉ះពាល់ដល់សុខភាព និងជីវិតរបស់ប្រជាពលរដ្ឋ។ « ដូច្នេះបើមានការដាក់ឧបករណ៍ ស្វ័យត្រួតពិនិត្យតាមដានជាតិពុល គឺជាការល្អណាស់!» អ្នកស្រី សិរីរ័ត្ន បានបន្ថែម។

ស្របគ្នានេះ ម្ចាស់ផ្ទះជួល អ្នកស្រី ចាន់ លីដា នៅក្នុងក្រុងបាវិត ខេត្តស្វាយរៀង បានសម្តែងមតិថា ប្រជា ពលរដ្ឋបាននិងកំពុងប្រើប្រាស់ទឹក និងធ្វើនេសាទលក្ខណៈគ្រួសារក្នុងព្រែកមួយ ឈ្មោះថា «ព្រែកល្ពៅ» ក្បែរតំបន់រោងចក្រ។ អ្នកស្រីចង់ឱ្យម្ចាស់រោងចក្រសហគ្រាស មានអាងប្រព្រឹត្តកម្មទឹកកខ្វក់ និងបំពាក់នូវឧបករណ៍ស្វ័យត្រួតពិនិត្យ តាមដានការបញ្ចេញសំណល់រាវ និងការបង្ហូរទឹកកខ្វក់ចេញពីរោងចក្រដើម្បីចៀសវាង ការបំពុលដល់មនុស្ស សត្វ ដែលកំពុងរស់នៅជាមួយទឹកនៃព្រែកជីកក្នុងមូលដ្ឋាន។

ដោយឡែក លោក លីជុន សាវ (Lijun shao) ជំនួយការអ្នកគ្រប់គ្រងទូទៅនៃតំបន់សេដ្ឋកិច្ចពិសេស មេន-ហាតធេន នៅទីក្រុងបាវិត បានឱ្យដឹងថា ក្រុមហ៊ុនអភិវឌ្ឍត្រូវតែគិតគូរដល់សុខភាពប្រជាជន បរិស្ថាន ធម្មជាតិ និងភាពបៃតង»។ ហេតុនេះទើបក្រុមហ៊ុនបានបំពាក់នូវឧបករណ៍ស្វ័យត្រួតពិនិត្យ តាមដានការបញ្ចេញសំណល់រាវ និងការបង្ហូរទឹកកខ្វក់ចេញពីរោងចក្រសហគ្រាស មុននឹងការបង្ហូរចេញទៅតាមប្រឡាយសាធារណៈគឺគ្មានសារធាតុពុលលោក











ថ្លែងបញ្ជាក់បន្ថែម។

ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានគូសបញ្ជាក់បន្ថែមថា ការបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យនៅតាមរោងចក្រសហគ្រាស ជាកត្តាដ៏សំខាន់ ដើម្បីធានាការលើកកម្ពស់សុវត្ថិភាព និងសុខភាពការងាររបស់ប្រជាពលរដ្ឋ កម្មករ កម្មការិនី និងនិយោជិតទាំងអស់ដែលរស់នៅក្បែរប្រភពទឹក និងបំពេញការងារនៅតាមរោងចក្រសហគ្រាសទាំងនោះ។ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា








ក្រសួងបរិស្ថាន មានបំណងជំរុញឱ្យសុខភាពកម្មករកម្មការិនីល្អ សុខភាពប្រជាពលរដ្ឋល្អ និងសុខភាពបរិស្ថានល្អ សំដៅឈានឆ្ពោះទៅភាពជោគជ័យនៃការវិនិយោគដោយចីរភាព ការគ្រប់គ្រងបរិស្ថានល្អ និងប្រជាពលរដ្ឋមានសុខភាពល្អ។

សូមបញ្ជាក់ថា ច្បាប់របស់កម្ពុជា ក្នុងនោះក្រមបរិស្ថាន និងធនធានធម្មជាតិត្រង់មាត្រា២៨៧ និងប្រកាសរបស់ក្រសួងបរិស្ថានលេខ៣០២ ប្រកប.ស្ថ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការអនុវត្តវិធានស្វ័យត្រួតពិនិត្យការបំពុល បរិស្ថាននៅប្រភពបំពុលសក្តានុពល បានតម្រូវឱ្យរោងចក្រសហគ្រាសឧស្សាហកម្ម ដែលបញ្ចេញសំណល់គ្រប់ប្រភេទគឺជាប្រភពបំពុល ត្រូវបំពាក់ជាចាំបាច់នូវឧបករណ៍ស្វ័យត្រួតពិនិត្យ តាម ដានការបញ្ចេញសំណល់រាវ និងការបង្ហូរទឹកកខ្វក់ ចេញពីរោងចក្រសហគ្រាស។

ឧបករណ៍ស្វ័យត្រួតពិនិត្យនេះ គឺជាមធ្យោបាយដ៏មានសារៈសំខាន់ក្នុងការជួយបង្កលក្ខណៈងាយស្រួលដល់ក្រសួងបរិស្ថាន នៅក្នុងការតាមដាននិងការត្រួតពិនិត្យទប់ស្កាត់ និងចាត់វិធានការបានទាន់ពេលវេលានៅពេលមានករណី





លេចជ្រាប ឬការលួចបង្ហូរទឹកកខ្វក់ ឬក៏សារធាតុរាវពុល ចេញពីរោងចក្រណាមួយ ដែលបានបំពាក់នូវឧបករណ៍នេះរួច ដោយមិនចាំបាច់មានមន្ត្រីជំនាញចុះត្រួតពិនិត្យដោយផ្ទាល់នោះទេ។ ពោលគឺ រាល់ទិន្នន័យទាំងអស់ នឹងត្រូវបញ្ជូនដោយស្វ័យប្រវត្តិទៅកាន់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួង ហើយទិន្នន័យទាំងនោះ ទោះក្នុងករណីអសកម្មពីបច្ចេកទេសណាមួយ ក៏ឧបករណ៍នេះបញ្ជូន និងផ្តល់សញ្ញាទៅក្រសួងបរិស្ថានបានភ្លាមៗ៕



# ភាគ៦ បៃតង

## ការការពារ ថែរក្សា និងអភិរក្សធនធានធម្មជាតិ

## ភាពបៃតង

សុខភាពបរិស្ថាន គឺជាដើមចមនៃភាពសុខដុមនីយកម្មជីវិត និងធម្មជាតិ ហើយដើម្បីធានាបាននូវសុខភាពបរិស្ថានល្អ ចាំបាច់ត្រូវមានការការពារ ថែរក្សា និងអភិរក្សធនធានធម្មជាតិ ជាមួយគ្នានេះក្រសួងបរិស្ថានបានដាក់ចេញនូវវិធានការ ៣ បូក ១ ដែលរួមមាន៖

១.វិធានការទប់ស្កាត់បទល្មើសធនធានធម្មជាតិតាមរយៈការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលមានជា ធរមានឱ្យបាន១០០% ហើយចំពោះការអនុវត្តទាំងឡាយណា ដែលមានការចន្លោះប្រហោង ក្រសួងបរិស្ថានមានក្រុមអ្នកច្បាប់ជួយប្រឹក្សាយោបល់ និងដោះស្រាយតាមនីតិវិធីច្បាប់។

២.កិច្ចសហការជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន

៣.សហការជាមួយបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស កងទ័ពជើងគោក និងអង្គភាពប្រឆាំងអំពើពុករលួយ



ក្នុងការចុះអន្តរាគមន៍បង្ក្រាបបទល្មើសធនធានធម្មជាតិ

៤.ការដាំដើមឈើឱ្យច្រើនជាងការកាប់។

ជាក់ស្តែងដើម្បីឈានឆ្ពោះទៅសម្រេចឱ្យបានជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០ ក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធនាការ «ពន្លកបៃតង» ដោយបានរៀបចំពិព័រណ៍ចែកកូនឈើក្រោមមូលបទ «ពន្លកបៃតង» និងទិវាកេសរកូលលើកទី៤ នៅមុខទីស្តីការក្រសួងបរិស្ថាន កាលពីថ្ងៃទី១០ ដល់១២ ខែកក្កដា ឆ្នាំ២០២៤ ក្រោមអធិបតីភាពរបស់ ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដែលមានអ្នកចូលរួមប្រមាណជិត ៤០០នាក់។

ទន្ទឹមគ្នានេះ ពិព័រណ៍ចែកកូនឈើក្រោមមូលបទ «ពន្លកបៃតង» និងទិវាកេសរកូលលើកទី៤ ក៏ទទួលបានការគាំទ្រ និងចូលរួមទស្សនាពីមហាជនសរុបប្រមាណជាង ៣ម៉ឺននាក់។ ស្របជាមួយគ្នានេះ ក្រសួងបានចែកជូនកូនឈើសរុបជាង១លាន ៣សែនដើម ក្នុងនោះប្រភេទកូនឈើព្រៃមានប្រមាណជិត ៩០ម៉ឺនដើម ឈើហូបផ្លែជាង៩៤ពាន់ដើម និងកូនត្នោត ៣៥ម៉ឺនដើម។ ការផ្តល់ជូនកូនឈើដល់មហាជន



ដោយឥតគិតថ្លៃនេះ ក្រសួងបរិស្ថាននៅបន្តផ្តល់ជូនកូនឈើដល់មហាជនដែលបានស្នើសុំតាមបណ្តារាជធានី-ខេត្ត សរុបចំនួនជាង ៤២ពាន់ដើម ក្នុងនោះមានប្រភេទឈើព្រៃជិត ១៨ពាន់ដើម ឈើហូបផ្លែជាង ៤ពាន់ដើម និងកូនត្នោតចំនួនជិត ២០ពាន់ដើម។ លើសពីនេះ ក្រសួងក៏បានបន្តបណ្តុះកូនឈើបានចំនួនជាង ២១៨ពាន់ដើម ឈើព្រៃជាង ៩២ពាន់ដើម ឈើហូបផ្លែជាង ៧ពាន់ដើម និងកូនត្នោតជាង ១១៨ពាន់ដើម នេះបើគិតត្រឹមថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤។

















# ការបណ្ដុះកូនឈើ









ក្រសួងបរិស្ថានបានដាក់ចេញនូវការដាំស្តារព្រៃឡើងវិញ តាមរយៈការបណ្ដុះកូនឈើដោយរួមមាន៖

១- បញ្ឈប់ការទិញកូនឈើ

មន្ត្រីនៃក្រសួងបរិស្ថានចេះបណ្ដុះកូនឈើ របៀបដាំថែទាំ ការពារកូនឈើបានដាំ និងមិនមានទិញកូនឈើចែកជូនប្រជាពលរដ្ឋទៀតទេ ព្រមទាំងអនុវត្តការចែកកូនឈើដោយឥតគិតថ្លៃដល់ប្រជាពលរដ្ឋដាំដុះ។

២- ច្បារបណ្ដុះកូនឈើ

បានរៀបចំច្បារបណ្ដុះកូនឈើតាមរាជធានី-ខេត្តដែលមានទំហំថ្នាលនីមួយៗមានទំហំចន្លោះពី ២០០ម៉ែត្រការ៉េ ទៅ៧០០ម៉ែត្រការ៉េ ទៅតាមលទ្ធភាព។ បណ្ដុះកូនឈើសរុបចំនួន ១ ១៦៨ ៨២៦ដើម។ ជំហានទី១ បណ្ដុះបាន ៩៥ ០០០០ដើម មាន៣ប្រភេទ ឈើព្រៃ ឈើហូបផ្លែ និងត្នោត (គិតត្រឹមថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤)។ ជំហានទី២ បណ្ដុះកូនឈើបានចំនួន ២១៨ ៨២៦ដើម ឈើព្រៃចំនួន ៩២ ៤៦៩ដើម ឈើហូបផ្លែចំនួន ៧ ៤៧៤ដើម និងកូនត្នោតចំនួន ១១៨ ៨៨៣ដើម (គិតចាប់ពីថ្ងៃទី១៧









ខែកក្កដា រហូតដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤) កំពុងដំណើរការរៀបចំស្ថានីយ៍បណ្ដុះកូនឈើថ្នាក់តំបន់ចំនួន ៥ស្ថានីយ៍រួមមាន ខេត្តត្បូងឃ្មុំ ទំហំ ៣ហិកតា ខេត្តមណ្ឌលគិរី ទំហំ ១០ហិកតា ខេត្តសៀមរាបទំហំ ១០ហិកតា ខេត្តកំពង់ស្ពឺ ទំហំ ២០ហិកតា និងខេត្តកោះកុងទំហំ ៣ហិកតា។

## ការដាំដើមឈើឱ្យបានច្រើនជាងការកាប់

បន្តគាំទ្រមន្ទីរបរិស្ថានខេត្តក្នុងការបង្កើតថ្នាលបណ្ដុះកូនឈើតាមខេត្តសាមី និងជំរុញការរៀបចំ ថ្នាលបណ្ដុះកូនឈើខ្នាតតំបន់ នៅក្នុងខេត្តត្បូងឃ្មុំ កំពង់ស្ពឺ កោះកុង សៀមរាប និងមណ្ឌលគិរី និងដើម្បីបណ្ដុះកូនឈើចែកជូនដល់សាធារណជនដោយឥតគិតថ្លៃ សម្រាប់យកទៅដាំនៅតាមលំនៅដ្ឋាន ទីសាធារណៈ តំបន់សហគមន៍ និងតំបន់រេចរឹលក្នុងតំបន់ការពារធម្មជាតិ

រៀបចំពិព័រណ៍ចែកកូនឈើថ្នាក់ជាតិ ចំនួន៣ឆ្នាំដំបូង ធ្វើជាគំរូ ហើយបន្ទាប់មក ជំរុញ និងគាំទ្រមន្ទីរបរិស្ថានឱ្យរៀបចំពិព័រណ៍ចែកកូនឈើថ្នាក់តាមក្រោមជាតិជារៀងរាល់ឆ្នាំ សម្រាប់ចែកជូនសាធារណជន ដោយឥតគិតថ្លៃ

បន្តពង្រឹង និងពង្រីកយុទ្ធនាការ «ពន្លកបៃតង» (ឆ្នាំទី១ ដាំបានជាង១,៣លានដើម) ដើម្បីបង្កើនការដាំដើមឈើរួមទាំងដើមត្នោត ឱ្យបានច្រើនជាងការកាប់ជារៀងរាល់ឆ្នាំ សំដៅសម្រេចបានគម្របព្រៃឈើ ៦០% នៃផ្ទៃប្រទេស នៅត្រឹមឆ្នាំ២០៥០ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។

- រៀបចំយុទ្ធនាការដាំដើមឈើ
- រៀបចំយុទ្ធនាការប្រកួតប្រជែងដាំដើមឈើ និងថែទាំដើមឈើ
- រៀបចំទិវាបរិស្ថានជាតិ ។



## ការគ្រប់គ្រងតំបន់ការពារធម្មជាតិ

បន្តអនុវត្តច្បាប់១០០%៖

(១)ពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលនៅមានជាធរមាន ដោយមិនលើកលែង និងត្រូវបញ្ឈប់វប្បធម៌ចុះកិច្ចសន្យាដោះលែងជនល្មើស

- ការរៀបចំរបាយការណ៍ត្រូវស្មោះត្រង់បំផុត
- ការរៀបចំសំណុំរឿងត្រូវមានភាពច្បាស់លាស់ និងទៀងត្រង់
- ការតាមដានសំណុំរឿង

(២)សហការជាមួយគណៈមេធាវី ដើម្បីទទួលបានសេវាគាំទ្រពីក្រុមអ្នកច្បាប់អំពីដំណើរការនៃនីតិវិធីច្បាប់ទាំងផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌ

- មេធាវីតាមដានសំណុំរឿង ត្រៀមផ្ទេរជូននាយកដ្ឋាននីតិកម្មនៅពេលបង្កើតហើយ និង

(៣)សហការជាមួយក្រសួងយុត្តិធម៌ ដើម្បីទទួលបាននូវសេវាគាំទ្រពីមន្ត្រីជំនាញផ្នែកច្បាប់

បន្តសហការជាមួយអាជ្ញាធរដែនដី៖

(១)គាំទ្រការងារផ្ទេរមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងផ្នែកបច្ចេកទេស និងមធ្យោបាយ

(២)ផ្តល់ផែនទីកំណត់តំបន់ការពារធម្មជាតិគ្រប់គ្រាន់ និងផែនទីផ្កាយរណបជាប្រចាំ ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្រុក ខេត្ត និងមន្ទីរបរិស្ថាន










Mission to Tonle Sap of Delegation from
Ministry of Environment and European Union
WCSCambodia


Igor DRIESMANS

























(៣)ផ្តល់ជូនដល់មន្ទីរបរិស្ថាន ដើម្បីប្រើប្រាស់ក្នុងតំបន់ការពារធម្មជាតិ បន្តសហការជាមួយអង្គភាពប្រឆាំងនឹងអំពើពុករលួយ និងកងរាជអាវុធហត្ថ៖

(១)ផ្តល់ផែនទីកំណត់តំបន់ការពារធម្មជាតិគ្រប់គ្រាន់ ជូនដល់អង្គភាពប្រឆាំងអំពើពុករលួយ និងកងរាជអាវុធហត្ថ

(២)ផ្តល់ផែនទីផ្កាយរណប ជាប្រចាំ ជូនដល់អង្គភាពប្រឆាំងអំពើពុករលួយ និងកងរាជអាវុធហត្ថ និង

(៣)គាំទ្រអង្គភាពប្រឆាំងអំពើពុករលួយ និងកងរាជអាវុធហត្ថ ចំពោះការផ្តល់មធ្យោបាយក្នុងករណីចាំបាច់និងតាមលទ្ធភាព។

រៀបចំការងារឱ្យទៅជាប្រព័ន្ធ (ការងារបន្ត)

- តាមដានការអនុវត្តរបស់មន្ទីរ វាយតម្លៃ និងដាក់វិធានការ
    - ការចាត់វិធានការតាមផែនទីផ្កាយរណប
- រៀបចំផែនការថែរក្សា និងប្រើប្រាស់ដីដែលដកហូតមកវិញ
- រៀបចំយុទ្ធសាស្ត្ររយៈពេលវែងដើម្បីទទួលបានគម្របព្រៃឈើ ៦០%។





# ក្រសួងបរិស្ថាន៖ ការផ្ទេរអំណាចឱ្យថ្នាក់ក្រោមជាតិ គឺជាការជំរុញឱ្យការទប់ស្កាត់បទល្មើសធនធានធម្មជាតិកាន់តែមានប្រសិទ្ធភាព




ផែនទីបង្ហាញតំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថានចំនួន ៧៣តំបន់ ដែលគ្របដណ្តប់លើផ្ទៃដីទំហំប្រមាណជាង ៧លានហិកតា ស្ថិតក្នុងខេត្តចំនួន២១ និងក្រុង/ស្រុកចំនួន១១១ បានចែកជូនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ២១ផ្ទាំងធំៗ នៅក្នុងពិធីប្រគល់ផែនទីតំបន់ការពារធម្មជាតិ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ នៅទីស្តីការក្រសួងបរិស្ថាន នាថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២៤។



ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថានបានថ្លែងនៅក្នុងពិធីនេះថា ការផ្ទេរអំណាចឱ្យថ្នាក់ក្រោមជាតិ គឺជាការជំរុញឱ្យការទប់ស្កាត់បទល្មើសធនធានធម្មជាតិកាន់តែមានប្រសិទ្ធភាព ស្របតាមវិធានការទាំង៤ចំណុច ដែលរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភាបានដាក់ចេញនៅក្នុងដំណាក់កាលទី១ នោះគឺ៖

ទី១. ជំរុញការអនុវត្តច្បាប់១០០% ដោយមិនមានការលើកលែងជាដាច់ខាតចំពោះបទល្មើសធនធានធម្មជាតិ។

ទី២. សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត នោះគឺអាជ្ញាធរមូលដ្ឋានរាជធានី ខេត្ត ដែលមានតួនាទី ភារកិច្ចគ្រប់គ្រងធនធានធម្មជាតិឱ្យបានស្អិតរមួត ដែលបានកំពុងអនុវត្ត និងធ្វើឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្តល់ផែនទី ទីតាំងតំបន់ការពារធម្មជាតិ ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកាត់បន្ថយទំនាស់លើការប្រើប្រាស់ដីធ្លី និងធានាការប្រើប្រាស់ដីក្នុងតំបន់ការពារធម្មជាតិ ឱ្យមានសុវត្ថិភាពទាំងដីសាធារណរបស់រដ្ឋ (តំបន់ស្នូលនិងតំបន់



អភិរក្ស) ដីឯកជនរបស់រដ្ឋ (តំបន់ប្រើប្រាស់ដោយចីរភាព) និងដីកម្មសិទ្ធិឯកជន (តំបន់សហគមន៍)។

ទី៣. សហការជាមួយគណៈបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអង្គភាពប្រឆាំងអំពើពុករលួយ បន្ថែមលើកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ដែលបានអនុវត្តកន្លងមក

និងទី៤. ជំរុញ ការដាំស្តាព្រៃឈើ សំដៅឱ្យមានការដាំដើមឈើឱ្យច្រើនជាងការកាប់ ដើម្បីបង្កើនការដាំដុះគម្របព្រៃឈើឱ្យបាន៦០% នៅឆ្នាំ២០៥០។

ទន្ទឹមគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានគូសបញ្ជាក់ថា ដើម្បីឆ្លើយតបនឹងការទប់ស្កាត់បទល្មើសធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ដែលលោកបានយកចិត្តទុកដាក់យ៉ាងខ្លាំង និងបានចេញបញ្ជារដោយផ្ទាល់ផងថា ត្រូវតែទប់ស្កាត់ និងបញ្ឈប់រាល់បទល្មើសធនធានធម្មជាតិ និងព្រៃឈើ ដែលជាមរតកបៃតងរបស់យើង ឱ្យខានតែបាននិងមានប្រសិទ្ធភាពបំផុតនោះ គឺ











ការរួមសហការគ្នាយ៉ាងជិតស្និត ការផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកជាទៀងទាត់ និងម្យ៉ាងយើងក៏មានផែនទីជាគោលចម្បងក្នុងការគ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិរបស់យើងទុកជាមរតកឱ្យអ្នកជំនាន់ក្រោយ។

គួររម្លឹកជូនដែរថា រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ២១ រាជធានី/ខេត្តរួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ព្រះវិហារ កំពង់ធំ ឧត្តរមានជ័យ ក្រចេះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង តាកែវ កំពង់ស្ពឺ កំពត កែប ព្រះសីហនុ កោះកុង ព្រៃវែង និងត្បូងឃ្មុំ ដែលតំបន់ការពារធម្មជាតិចំនួន ៧៣តំបន់ បានចែកចេញជា៧ប្រភេទដោយក្នុងនោះរួមមាន៖ ឧទ្យានជាតិចំនួន៩ ឧទ្យានជាតិសមុទ្រចំនួន២ ដែនជម្រក សត្វព្រៃចំនួន១៨ តំបន់ការពារទេសភាពចំនួន១៤តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន១១ តំបន់រាមសារចំនួន៥ និងតំបន់បេតិកភណ្ឌធម្មជាតិចំនួន១៤៕

## ផ្តល់ជូនដ្រូន (Drone) ដល់មន្ទីររាជធានីខេត្តចំនួន ២៥ ធ្វើជាឧបករណ៍ជំនួយដល់ការងារចុះល្បាតរបស់មន្ត្រីឧទ្យានុរក្ស

ការផ្តល់ជូនដ្រូន (Drone) សម្រាប់ជាឧបករណ៍ជំនួយបន្ថែមដល់ការងារល្បាត និងអភិរក្សធនធានធម្មជាតិ គឺជាការគិតគូរ និងយកចិត្តទុកដាក់ ចំពោះមន្ត្រីក្រោមឱវាទ ជាពិសេសមន្ត្រីឧទ្យានុរក្សនៅតាមតំបន់ការពារធនធានធម្មជាតិ ពីសំណាក់ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ហើយក៏ជាការពង្រឹងការគ្រប់គ្រង ការអភិរក្ស ការការពារ និងការអភិវឌ្ឍប្រកបដោយ សុខដុមនីយកម្ម និងចីរភាពនូវប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ របស់កម្ពុជា តាមរយៈការបន្តគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃដោយរក្សាគម្របព្រៃឈើឱ្យបាន៦០% នៅឆ្នាំ២០៥០អនុលោមតាមមុំទី២នៃយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ក្នុងដំណាក់កាលទី១។












































លើសពីនេះ ដ្រូន(Drone) ក៏ជាឧបករណ៍ដែលអាចផ្តិតនូវរូបភាពបទល្មើសធនធានធម្មជាតិ និងអាចមើលឃើញទុកជាមុនបាន នៅតាមកន្លែងកំបាំងនានា ដែលឈ្មួញប្រព្រឹត្តបទល្មើសលួចលាក់បំបាំងពីភ្នែករបស់ក្រុមការងារល្បាត និងងាយស្រួលសម្រាប់ក្រុមការងារផ្តិតយកនូវរូបភាពទុកធ្វើជារបាយការណ៍បទល្មើស ដើម្បីរាយការជូនមន្ត្រីអនុវត្ត ច្បាប់ទុកធ្វើជាវត្ថុតាងជាដើម។

សូមជម្រាបការ ផ្តល់ជូនដ្រូន (Drone) សម្រាប់ជាឧបករណ៍ជំនួយបន្ថែមដល់ការងារល្បាត និងអភិរក្សធនធានធម្មជាតិនេះ បានធ្វើឡើងនៅក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំផ្សព្វផ្សាយបរិស្ថាន និងធនធានធម្មជាតិ នារសៀលថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងបរិស្ថាន។

## ក្រសួងបរិស្ថានដាក់ឱ្យប្រើប្រាស់ក្រមបរិស្ថាននិង ធនធានធម្មជាតិ







ក្រមបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ហើយ នារសៀលថ្ងៃសុក្រ ទី២៨ ខែមិថុនា ឆ្នាំ ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ សមាជិក ព្រឹទ្ធសភា រដ្ឋសភា ថ្នាក់ដឹកនាំ មន្ត្រីរាជការ មកពីក្រសួង ស្ថាប័ននានា កងកម្លាំងប្រដាប់អាវុធ អង្គភាពប្រឆាំងអំពើពុករលួយ ឯកអគ្គរដ្ឋទូត តំណាងស្ថានទូត អង្គការ ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សា ស្រាវជ្រាវ រដ្ឋបាលរាជធានីខេត្ត សិស្ស និស្សិត យុវជន និងតំណាងសហគមន៍ ជាច្រើននាក់។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានវាយតម្លៃខ្ពស់ចំពោះការប្រកាសឱ្យប្រើប្រាស់ ក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលនឹងយកទៅប្រើប្រាស់ក្នុង បុព្វហេតុការពារបរិស្ថាននិងធនធានធម្មជាតិ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម និងការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ។ ឯកឧត្តមរដ្ឋមន្ត្រី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាអតីតរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន ដែលមានគំនិតផ្តួចផ្តើម ឱ្យមានការរៀបចំក្រមបរិស្ថាន និងធនធានធម្មជាតិនេះឡើង និងអរគុណចំពោះ ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ នៃក្រសួងបរិស្ថាន បណ្ដាក្រសួងស្ថាប័ន របស់រាជរដ្ឋាភិបាល ដៃគូពាក់ព័ន្ធទាំងអស់ ដែលបានដឹកនាំ និងរួមចំណែក ក្នុងការរៀបចំឯកសារនេះឱ្យចេញជារូបរាងឡើង។

សូមបញ្ជាក់ថា ក្រសួងបរិស្ថានបានដាក់ចេញនូវ យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨ ដែលត្រូវបានរៀបចំឡើង ដោយអនុលោមតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីតម្រង់ទិស និងចង្អុលបង្ហាញអំពីអាទិភាពការងារ ក្នុងការលើកកម្ពស់ កិច្ចគាំពារបរិស្ថាន ការការពារធនធានធម្មជាតិ និង ការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងមុំចំនួនបី គឺ «ភាពស្អាត» «ភាពបៃតង»និង «ចីរភាព» សំដៅឆ្ពោះ ទៅ សម្រេចការអភិវឌ្ឍប្រកបដោយអព្យាក្រឹត្យកាបូននៅឆ្នាំ២០៥០។

ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានថ្លែងបន្ថែមថា ក្រសួងបរិស្ថាននឹងប្រើប្រាស់ក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ជាឧបករណ៍ដើម្បីគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ក្រមបរិស្ថាននិងធនធានធម្មជាតិ បានប្រើប្រាស់ពេលវេលាប្រមាណ៨ឆ្នាំ ដើម្បីចងក្រងបង្កើតឡើង និងបានដាក់ឱ្យប្រើប្រាស់នាពេលនេះ។ ក្រមបរិស្ថាននិង ធនធានធម្មជាតិ ត្រូវបានចែកជា១២កន្ថី និងមានមាត្រាសរុប៨៦៥ ហើយបានបញ្ជាក់អំពីតម្រូវការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធចំនួន១៣១ ដើម្បីគាំទ្រការអនុវត្តឱ្យបានពេញលេញ។ ដើម្បីផ្សព្វផ្សាយឱ្យទូលំទូលាយ ក្នុងក្របខណ្ឌជាតិ និងសកល និងជំរុញ និងបង្កើនប្រសិទ្ធភាព នៃការចូលរួម អនុវត្តក្រមបរិស្ថាន និងធនធានធម្មជាតិ ដើម្បីសម្រេចបាននូវ ភាពស្អាត ភាពបៃតង និងចីរភាព ក្រសួងបរិស្ថានបានធ្វើការបោះពុម្ពក្រមបរិស្ថាន និងធនធានធម្មជាតិ ដើម្បីចែកជូនដល់បណ្ដាភាគីពាក់ព័ន្ធទាំងអស់។ ទន្ទឹមនោះ ភាគីពាក់ព័ន្ធក៏អាចធ្វើការទាញ យកឯកសារក្រមនេះ (Download) ទាំងជាភាសាខ្មែរ និងអង់គ្លេស ពី ប្រព័ន្ធ QR-Code ដែលមានដាក់ជូនជាសាធារណៈ។










ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រមបរិស្ថាននិងធនធានធម្មជាតិ
ក្រសួងបរិស្ថាន


ពិធី







# ចីរភាព

## គោលដៅលំហែបៃតងក្នុងតំបន់ការពារធម្មជាតិ ការការពារផលប្រយោជន៍ និងផ្តល់ភាពជាម្ចាស់ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន



ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅរសៀលថ្ងៃទី០៥ កុម្ភៈ ឆ្នាំ២០២៤នេះ នៅក្នុងកិច្ចប្រជុំដំបូងនៃក្រុមការងារគ្រប់គ្រង និងអភិវឌ្ឍគោលដៅលំហែរបៃតង ក្នុងតំបន់ការពារធម្មជាតិ នៅទីស្តីការក្រសួងបរិស្ថាន បានដាក់ចេញនូវគោលការណ៍៣ចម្បង ដើម្បីបម្រើឱ្យផលប្រយោជន៍ប្រជាសហគមន៍ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ប្រកបដោយនិរន្តភាព។ គោលការណ៍ចម្បងទាំងនោះ គឺទី១. គ្រប់គម្រោងអភិវឌ្ឍន៍របស់សហគមន៍មូលដ្ឋាន ចាំបាច់ត្រូវបម្រើឱ្យផល ប្រយោជន៍ និងលើកកម្ពស់ជីវភាពសហគមន៍ មានន័យថា រាល់ការអភិវឌ្ឍទាំងឡាយត្រូវមានការយល់ព្រមពីប្រជាសហគមន៍ ដោយមានភាពសុខដុមរមនា រវាងគម្រោងនិងសហគមន៍ ហើយត្រូវបង្រៀន















ប្រជាសហគមន៍ ឱ្យមានឯករាជ្យភាព គឺមានភាពជាម្ចាស់ដោយខ្លួនឯង។ ទី២. គ្រប់គម្រោងអភិវឌ្ឍន៍ទាំងអស់ ត្រូវជួយការពារតំបន់ការពារធម្មជាតិ និងសហគមន៍មូលដ្ឋាន ក្នុងនោះម្ចាស់គម្រោង ត្រូវចូលរួមការងារជាមួយសហគមន៍ការពារទប់ស្កាត់ការទន្ទ្រានយកដីតំបន់ការពារធម្មជាតិ ឱ្យបានជាដាច់ខាត ជាពិសេសការពារឱ្យបាននូវការកាប់ឈើខុសច្បាប់ និងបទល្មើសធនធានធម្មជាតិ រួមទាំងហានិភ័យនានា ដែលបង្កឱ្យមានភ្លើងឆេះព្រៃជាដើម។ ទី៣. អនុវត្តនូវភាពស្អាតភាពបៃតងនៅក្នុងតំបន់ការពារ តាមរយៈការថែរក្សានូវភាពស្អាតក្នុងខ្យល់ លើដី និងក្នុងទឹក ជាពិសេសគឺភាពស្អាតដែលកើតចេញពីសមានចិត្ត របស់ប្រជាសហគមន៍មូលដ្ឋាន ហើយភាពស្អាតនេះនឹងចែករំលែកទៅដល់បរិស្ថានជុំវិញ ដែលរួមមានភ្ញៀវទេសចរ មកកម្សាន្តនៅតំបន់ការពារធម្មជាតិផងដែរ។

ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រី បានថ្លែងបន្ថែមថា ការថែរក្សានូវភាពបៃតងនៅជុំវិញតំបន់ការពារ តាម រយៈការលើកទឹកចិត្តឱ្យមានការចូលរួមដាំដើមឈើពីអ្នកទេសចរ គឺជាការផ្សព្វផ្សាយចរណៃភាពបៃតងឱ្យដក់ជាប់នៅក្នុងចិត្តស្អាតរបស់ទេសចរជាតិ-អន្តរជាតិ។ លើសពីនេះ ការលើកស្ទួយ និងបង្ហាញពីជាតិនិយមរបស់ខ្មែរ តាមរយៈមិនចម្លងវប្បធម៌ដទៃ តែផ្តួចផ្តើមនិងបង្កើតនូវគំនិតថ្មីៗ ដែលមានលក្ខណៈជាខ្មែរ គឺជាភាពកម្រជំរុញឱ្យមានការទាក់ទាញពីទេសចរក្រៅប្រទេសឱ្យមកកម្សាន្ត និងទស្សនាតំបន់ការពារធម្មជាតិដ៏សម្បូរបែបរបស់ខ្មែរ។





















## ក្រសួងបរិស្ថាន រៀបចំរបៀងគោលដៅលំហែបៃតង នៅក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»





ក្រសួងបរិស្ថាន បានទទួលការគាំទ្រ និងសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់ជីវភាពសហគមន៍តំបន់ការពារធម្មជាតិនៅក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ឱ្យក្លាយជាពាណិជ្ជករខ្នាតតូច តាមរយៈការបង្កើតជារបៀងគោលដៅលំហែបៃតង ដែលជាជម្រើសមុខរបរសមស្រប នៅក្នុងតំបន់ដែលកាត់បន្ថយការដាក់សម្ពាធលើធនធានធម្មជាតិ។

នៅក្នុងឱកាសដឹកនាំកិច្ចប្រជុំស្តីពីការអភិវឌ្ឍគោលដៅលំហែបៃតង នៅទីស្តីការក្រសួងបរិស្ថាន កាលពីរសៀលថ្ងៃព្រហស្បតិ៍ ទី១៨ ខែមេសា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថានបានមានប្រសាសន៍ថា របៀងគោលដៅលំហែបៃតង ផ្តោតលើការរៀបចំសម្បទា







ទេសចរណ៍ ដូចជាការសាងសង់កន្លែងបោះតង់ស្នាក់នៅតាមរចនាបទខ្មែរ ការរៀបចំផ្លូវគោលដៅដើរកម្សាន្ត ភ្ជាប់ពីសហគមន៍មួយទៅសហគមន៍មួយទៀត ដោយថ្មើរជើង ឬអាចជិះកង់កម្សាន្ត ហើយសហគមន៍នីមួយៗ អាចផ្តល់សេវាកម្មទេសចរណ៍ (ការដឹកជញ្ជូន ម្ហូបអាហារ មគ្គុទេសក៍សហគមន៍)។ល។ ប្លែកពីគ្នាការកែច្នៃអនុផលព្រៃឈើ បង្កើតការងារនៅមូលដ្ឋាន និងសកម្មភាពសេដ្ឋកិច្ច ដែលមានមេត្រីភាពជាមួយនឹងបរិស្ថាន។

ជាមួយគ្នានេះ ឯកឧត្តម អ៊ាង សុផល្លែត បានជំរុញឱ្យមន្ត្រីជំនាញក្រសួងបរិស្ថាន បានរៀបចំកម្មវិធីចុះសិក្សាស្វែងយល់ព័ត៌មាន ជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍របៀងគោលដៅលំហែបៃតង នៅក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» សំដៅលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន ការអភិរក្សប្រព័ន្ធជីវៈចម្រុះ និងវប្បធម៌ប្រពៃណី ដើម្បីជាឧត្តមប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់។















សូមបញ្ជាក់ថា អនុលោមតាម «យុទ្ធសាស្ត្របញ្ចកោណ» ដំណាក់កាលទី១ និងឈរលើមូលដ្ឋានគ្រឹះនៃ «យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន» ឆ្នាំ២០២៣-២០២៨ និងការចង្អុលបង្ហាញដោយផ្ទាល់ពី **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានណែនាំកំណត់យកឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ជាគោលដៅទេសចរណ៍ធម្មជាតិ។

ការរៀបចំគោលដៅលំហែបៃតង សំដៅលើតំបន់សក្តានុពលទេសចរណ៍ធម្មជាតិ ដែលមាននៅក្នុងតំបន់ការពារធម្មជាតិដែលត្រូវបានសិក្សា ដោយរក្សាបាននូវគោលការណ៍ចំនួន៣ គឺ៖ ភាពស្អាត ភាពបៃតង និងចីរភាព ដើម្បីធានាបានការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការលើកកម្ពស់ជីវភាពសហគមន៍ប្រកបដោយនិរន្តភាព ការរក្សា និងបង្កើនគម្របព្រៃឈើជាអតិបរិមា និងឈានទៅសម្រេចបាននូវសហគមន៍អព្យាក្រឹត្យកាបូននៅឆ្នាំ២០៥០។ នៅក្នុងឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» មានទឹកជ្រោះ ប្រាសាទបុរាណ បុរាណស្ថាន និងពើងធម្មជាតិដែលមានភាពទាក់ទាញទេសចរមកកម្សាន្ត សរុបចំនួន៨៥កន្លែង ព្រមទាំងមានប្រជាពលរដ្ឋរស់សរុបចំនួន ១ ២៤៦ គ្រួសារ ប្រជាជនសរុបចំនួន ៥ ០៣៦នាក់ ក្នុងនោះស្ត្រី ២ ៤៤៦នាក់ ស្ថិតក្នុងឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប។ ជាមួយគ្នានោះ នៅឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន ក្រសួងបរិស្ថានបានរៀបចំជាសហគមន៍តំបន់ការពារធម្មជាតិ សរុបចំនួន៥ រួមមាន៖

១. សហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ធំ
២. សហគមន៍តំបន់ការពារធម្មជាតិព្រៃធំពពេល
៣. សហគមន៍តំបន់ការពារធម្មជាតិព្រៃភ្នំក្តួច
៤. សហគមន៍តំបន់ការពារធម្មជាតិព្រៃភ្នំម្នាស់
៥. សហគមន៍តំបន់ការពារធម្មជាតិជប់តាសុខ»៕

# ការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន

- បន្តអភិវឌ្ឍន៍ទីតាំងទេសចរណ៍ ជាពិសេស «គោលដៅលំហែបៃតង» (ឆ្នាំទី១ បានធ្វើនៅគិរីរម្យ និងភ្នំគូលែន)
- ពង្រីករបៀងទេសចរណ៍ ដោយផ្សារភ្ជាប់ពី គោលដៅលំហែបៃតងមួយ ទៅកាន់គោលដៅលំហែបៃតងផ្សេងទៀត ឬទៅកាន់ទីរមណីយដ្ឋានផ្សេងទៀត
- បន្តលើកកម្ពស់ជីវភាពសហគមន៍តំបន់ការពារ តាមរយៈការបង្កើតឱ្យមាន «ការងារបៃតង» មានដូចជា សេវាកម្មទេសចរណ៍ ការដាំដំណាំ ការចិញ្ចឹមសត្វ ការកែច្នៃម្ហូបអាហារ និងវត្ថុអនុស្សាវរីយ៍ជាដើម ដើម្បីបង្កើនប្រាក់ចំណូលដល់ប្រជាសហគមន៍ សំដៅពង្រឹងការការពារធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ
- រៀបចំរបៀងលំហែបៃតង
    - រៀបចំរបៀងលំហែបៃតងនៅខេត្តកំពង់ស្ពឺ កោះកុង កំពង់សោម កំពត និងកែប
    - រៀបចំរបៀងលំហែបៃតងនៅតំបន់អភិវឌ្ឍន៍ត្រីកោណ CLV-TDA
    - រៀបចំរបៀងលំហែបៃតងនៅកំពង់ធំ សៀមរាប ប៉ៃលិន ព្រះវិហារ និងឧត្តរមានជ័យ ។













## ក្រសួងបរិស្ថានបង្កើតថ្នាលបណ្ដុះកូនឈើថ្នាក់តំបន់ទី១ ក្នុងខេត្តត្បូងឃ្មុំ បំពាក់ដោយប្រព័ន្ធស្រោចស្រពដោយថាមពលពន្លឺព្រះអាទិត្យ

ក្រសួងបរិស្ថាន នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៤ បានសម្ពោធបើកការដ្ឋានសាងសង់ថ្នាលបណ្ដុះកូនឈើថ្នាក់តំបន់លើទំហំដីជាង៣ហិកតាក្នុងខេត្តត្បូងឃ្មុំ ដែលមានសមត្ថភាពបណ្ដុះកូនឈើបានជាង១លានដើម ក្នុងមួយឆ្នាំ ដើម្បីជំរុញការដាំដុះដើមឈើឱ្យបានច្រើនពោលគឺបង្កើនគម្របព្រៃឈើតាមផែនការរបស់រាជរដ្ឋាភិបាលចំនួន ៦០ ភាគរយ នៃផ្ទៃដីប្រទេសកម្ពុជា នៅត្រឹមឆ្នាំ២០៥០ ។

ថ្នាលបណ្ដុះកូនឈើទី១នេះ សាងសង់ឡើងស្ថិតក្នុងភូមិ៤៤ ឃុំព្រះធាតុ ស្រុកអូរាំងឪ ដោយមានការចូលរួមថវិកាពីកម្មវិធីអភិវឌ្ឍន៍សហប្រជា-ជាតិ (UNDP) និងក្រុមហ៊ុនកូកា-កូឡាកម្ពុជា។

ឯកឧត្តមរដ្ឋមន្ត្រី មានប្រសាសន៍ថា «ការដាំដើមឈើ ក៏ជាការដាក់ទុនមួយផងដែរ នៅក្នុងការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ និងការជំរុញការលើកកម្ពស់អព្យាក្រឹតកាបូន»។

ឯកឧត្តមបានលើកឡើងបន្ថែមថា ថ្នាលបណ្ដុះកូនឈើនេះ



រួមចំណែកដល់ការចូលរួមចំណែកដាំដើមឈើឡើងវិញឱ្យបានច្រើនសំដៅ កាត់បន្ថយការប្រែប្រួលអាកាសធាតុ និងធ្វើឱ្យកម្ពុជាមានភាពបៃតងស្រស់ស្អាត។

ឯកឧត្តមបណ្ឌិតអ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានថ្លែងថា ថ្នាលបណ្ដុះកូនឈើទី១នេះ ជាការបោះជំហានមួយពោរពេញដោយថាមពល បន្ទាប់ពីមានការចូលរួមពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន រួមទាំងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋដែលនឹងបន្តបោះជំហានទៅកាន់ខេត្តចំនួន៤ទៀត គឺមណ្ឌលគិរី សៀមរាប កំពង់ស្ពឺ និងកោះកុង។

ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រីក៏បានអំពាវនាវដល់ប្រជាពលរដ្ឋរួមគ្នាដាំដើមឈើដាំឱ្យបានច្រើន ក៏ដូចជាជួយថែរក្សា និងកុំកាប់ដើមឈើ ដើម្បីទុកជាម្លប់ និងខ្យល់សម្រាប់ដកដង្ហើម។

លោកស្រី Alissar Chaker តំណាងនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) នៅកម្ពុជា បានថ្លែងថា UNDP គាំទ្រកិច្ចខិតខំប្រឹងប្រែងដែលកំពុងតែអនុវត្តក្រោមយុទ្ធសាស្ត្រស្តារព្រៃឈើជាតិឡើងវិញ ដែលមានគោលបំណងដាំដើមឈើចំនួន១លាន ដើម ក៏ដូចជាអនុសាសន៍ក្នុងគោលនយោបាយការចូលរួមចំណែក ដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាស-











ធាតុ (NDC) និងគោលដៅអព្យាក្រឹតកាបូន។ កន្លងមក UNDP បានគាំទ្ររាជរដ្ឋាភិបាល និងក្រសួងបរិស្ថាន ក្នុងការបង្កើតគោលនយោបាយ និងក្របខណ្ឌសំខាន់ៗ ដូចដែលបានរៀបរាប់ខាងលើ សម្រាប់ការអនុវត្តរបៀបវារៈអាកាសធាតុរបស់ជាតិ និងបន្តការរួម ចំណែកចំពោះមហិច្ឆតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការសម្រេចបានគម្របព្រៃឈើចំនួន៦០ភាគរយ នៅឆ្នាំ២០៥០។

កញ្ញា សម្បត្តិ មុនីវរលក្ខណ៍ នាយកផ្នែកទំនាក់ទំនងកិច្ចការសាធារណៈនៃក្រុមហ៊ុនកូកា-កូឡាកម្ពុជា បានបញ្ជាក់ថា ការចូលរួមចំណែកជាផ្នែកមួយនៃគម្រោងនេះ តាមរយៈការផ្តល់ជូនប្រព័ន្ធស្រោចស្រពប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យបំពាក់នៅទីតាំងថ្នាលបណ្តុះកូនឈើ ពោលគឺប្រើប្រាស់ថាមពលកកើតឡើងវិញ ដែលកាត់បន្ថយការបំពុលបរិស្ថាន ដើម្បីបណ្តុះកូនឈើ ស្របតាមយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានរបស់ក្រសួងបរិស្ថានទាំងភាពស្អាត ភាពបៃតង និងចីរភាព។ កញ្ញា បានថ្លែងថា ការរៀបចំនាថ្ងៃនេះ ក៏ជាសក្ខីភាពនៃភាពជាដៃគូដ៏រឹងមាំរវាងក្រសួងបរិស្ថាន ភ្នាក់ងារ UNDP និងវិស័យឯកជន។ លើសពី ភាពជាដៃគូ ស្ថានីយ៍នេះសបញ្ជាក់ពី កិច្ចខិតខំប្រឹងប្រែងរួមគ្នាសម្រាប់អនាគតបៃតង និងប្រកបដោយចីរភាពសម្រាប់កម្ពុជាផងដែរ៕

# ផ្នែកទី២
## ការបណ្ដុះធនធានមនុស្សជំនាន់ក្រោយឱ្យមានបេះដូងស្អាត ពេញដោយភាពបៃតងយូរអង្វែងតទៅ

## ភាពស្អាតក្នុងផ្នត់គំនិតរបស់យុវជនខ្មែរ

ការផ្សព្វផ្សាយ ការបញ្ជ្រាបនូវយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន និងការងារអាទិភាពសំខាន់ៗ របស់ក្រសួងបរិស្ថានក្នុងចំណោមយុវជនខ្មែរ គឺជាការបណ្តុះនូវភាពស្អាត ភាពបៃតង ប្រកបដោយចីរភាព នៅក្នុងផ្នត់គំនិតយុវជនជំនាន់ក្រោយដែលជាអ្នកបន្តវេនដ៏មានសក្តានុពល។ ល្គឹកណាអ្នកជំនាន់ក្រោយចេះស្រឡាញ់ភាពស្អាត ស្រឡាញ់ភាពបៃតង និងចេះដាំដើមឈើហើយនោះ ពួកគេនឹងបន្តទំលាប់វិជ្ជមាននេះ ទៅដល់កូនចៅរបស់ពួកគេ ធ្វើឱ្យអ្នកជំនាន់ក្រោយពួកគេចេះស្រឡាញ់ និងការពារបរិស្ថានដែរ។ នេះហើយគឺជាចីរភាពនៃការងារបរិស្ថាន ដែលយើងគ្រប់គ្នាចង់បាន ចង់ឃើញ និងទុកជាមរតកសម្រាប់អ្នកជំនាន់ក្រោយរបស់យើង។

គោលគំនិតសំខាន់នៃការបណ្តុះផ្នត់គំនិតស្អាត បៃតង ដោយចីរភាព របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន គឺជាមូលដ្ឋានគ្រឹះឈានឆ្ពោះទៅកាន់ឆាកអន្តរជាតិតាមរយៈភាពស្អាត គ្មានសំណល់ប្លាស្ទិកនៅតាមដងផ្លូវ នៅសាលារៀន នៅតាមវត្ត នៅតាមមណ្ឌលសុខភាព និងនៅតាមផ្ទះរបស់ពួកគេ។ កាលណាកម្ពុជាមានភាពស្អាតគ្រប់ទីកន្លែង កម្ពុជានឹងក្លាយជាប្រទេសគំរូ ក្នុងការប្រយុទ្ធប្រឆាំងនឹងសំណល់ប្លាស្ទិក ដែលជាក្តីកង្វល់រួមរបស់ពិភពលោកទាំងមូល ជាមួយគ្នានេះកម្ពុជាក៏បានរួមចំណែកក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការទប់ស្កាត់មិនឱ្យមានការកើនកម្តៅភពផែនដីលើសពី២ ឬត្រឹម១,៥អង្សាសេ អនុលោមតាមវិធានប្រតិបត្តិសម្រាប់មាត្រា៦នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

នៅក្នុងឆ្នាំទី១នៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៧នេះ ក្រសួងបរិស្ថាន បានខិតខំ ធ្វើការងារផ្សព្វផ្សាយ ការចែករំលែក និងការចុះអនុវត្តផ្ទាល់ ដើម្បីបើកបង្ហាញបេះដូងអ្នកស្រឡាញ់បរិស្ថានគ្រប់រូបឱ្យហ៊ានក្រោកឡើងបញ្ចេញនូវសកម្មភាពស្អាតរបស់ខ្លួនប្រយុទ្ធប្រឆាំងនឹងចំនួនប្លាស្ទិក ដែលនៅគររាយប៉ាយតាមទីសាធារណៈ លើសពីនេះ ឯកឧត្តមរដ្ឋមន្ត្រីផ្ទាល់ក៏បានឡើងធ្វើបាឋកថាដោយផ្ទាល់ជាមួយសិស្សនិស្សិតនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសកលវិទ្យាល័យភូមិន្ទរដ្ឋបាល ដើម្បីបណ្តុះនូវផ្នត់គំនិតស្អាត ការពារសុខុមាលភាពពលរដ្ឋ និងផ្តល់នូវផាសុខភាពដល់បរិស្ថានកម្ពុជា។

## រដ្ឋមន្ត្រីក្រសួងបរិស្ថានបានផ្តល់ឱកាសឱ្យក្មេងស្រីជនជាតិដើមភាគតិច បាន សិក្សាស្វែងយល់អំពីតួនាទីរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងរយៈពេល១ថ្ងៃ

នៅថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានអនុញ្ញាតឱ្យក្មេងស្រីជនជាតិដើមភាគតិចចារាយ ឈ្មោះបុប្ផា ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ឱ្យបានសិក្សាស្វែងយល់អំពីការងាររបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងរយៈពេល១ថ្ងៃ។ ជាមួយគ្នានេះ ការផ្តល់ឱកាស និងការបង្ករភាពងាយស្រួល ដល់យុវជនកម្ពុជា ឱ្យស្វែងយល់អំពីតួនាទីការងារ គឺជាផ្នែកមួយនៃការបណ្តុះគំនិត ស្មារតីក្នុងភាពជាអ្នកដឹកនាំនាពេលអនាគត ជា ពិសេសកុមារី ក្មេងស្រីដែលងាយរងគ្រោះមកពីតំបន់ដាច់ស្រយាល និងក្រីក្រ ដើម្បីជួយបណ្តុះស្មារតី និងភាពអង់អាចរបស់ពួកគេ។

នេះជាលើកដំបូងហើយ ដែលក្រសួងបរិស្ថានក្រោមការដឹកនាំរបស់ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានអនុញ្ញាតឱ្យមានការសិក្សាស្វែងយល់ និងចង់ឱ្យមានការរួមចំណែកជាគំនិត ជាយោបល់ និងជាយុទ្ធសាស្ត្រនានាពីក្មេងស្រីជនជាតិដើមភាគតិចចារាយ ដើម្បីឱ្យពួកគេបានរួមចំណែកក្នុងវិស័យបរិស្ថានកម្ពុជា និងសិក្សាបន្ថែមអំពីយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ក៏ដូចជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភាផងដែរ។











# រដ្ឋមន្ត្រីក្រសួងបរិស្ថានចែករំលែកការអនុវត្តយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ជាមួយកម្មសិក្សាការី ឆ្នាំ២០២៤ នៃសាលាភូមិន្ទរដ្ឋបាល



អនុលោមតាម «យុទ្ធសាស្ត្របញ្ចកោណ» ដំណាក់កាលទី១ និងឈរលើមូលដ្ឋាននៃគោលនយោបាយ និងយុទ្ធសាស្ត្រជាតិដែលមានជាធរមាន ព្រមទាំងក្របខណ្ឌអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ក្រសួងបរិស្ថានបានរៀបចំយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានឆ្នាំ២០២៣-២០២៨ ក្នុងគោល-បំណង តម្រង់ទិស និងចង្អុលបង្ហាញការងារជាអាទិភាពដើម្បីធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ចឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់សេដ្ឋកិច្ចបៃតង សំដៅសម្រេចគោលដៅយុទ្ធសាស្ត្របញ្ចកោណ គឺ «ជាប្រទេសអព្យាក្រឹតកាបូន និងមានគម្រប











ព្រៃឈើ៦០ភាគរយ នៅឆ្នាំ២០៥០»។ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួង បរិស្ថាន បានលើកឡើងដូចខាងលើ ក្នុងបាឋកថាស្តីពី «យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន» ដល់គណៈគ្រប់គ្រង គ្រូឧទ្ទេស មន្ត្រីរាជការ កម្មសិក្សាការីឆ្នាំ២០២៤ នៃសាលាភូមិន្ទរដ្ឋបាល រៀបចំឡើងនៅព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤។ ឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងបញ្ជាក់ថា យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន បានរចនាឡើងជារូបរង្វង់ ដោយមានយុទ្ធសាស្ត្រស្នូលផ្តោតលើមុំចំនួន៣ មានជាអាទិ៍គឺ ការពង្រឹងគោលនយោបាយ ការកសាងរដ្ឋបាលឌីជីថល និងពង្រីកការផ្សព្វផ្សាយ ដែលមុំទាំងបីនេះ ជាកម្លាំងចលករដ៏សំខាន់ក្នុងការរុញបង្វិលយុទ្ធសាស្ត្រចំនួន៣សំខាន់ គឺភាពស្អាត, ភាពបៃតង និងចីរភាពឱ្យបានជោគជ័យ។

យុទ្ធសាស្ត្រទី១ ភាពស្អាត ដែលផ្តោតលើមុំអាទិភាព៣គឺ ការត្រួតពិនិត្យការបំពុល ការធ្វើទំនើបកម្មប្រព័ន្ធវិនិច្ឆ័យការបំពុល និងការលើកកម្ពស់ការវាយតម្លៃហេតុប៉ះពាល់



បរិស្ថាន។ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានថ្លែងថា ភាពស្អាត និងសុខភាពប្រជាពលរដ្ឋជាការងារអាទិភាព ដែលរាជរដ្ឋាភិបាលកម្ពុជានៅក្នុងអាណត្តិទី៧ បាននឹងកំពុងយកចិត្តទុកដាក់។ ការសម្អាតអនាម័យបរិស្ថាននៅតាមមូលដ្ឋានប្រមូលទុកដាក់ សំរាម រួមទាំងការកាត់បន្ថយសំណល់ប្លាស្ទិកដែលឈានទៅបញ្ឈប់ការប្រើប្រាស់ប្លាស្ទិក ក្នុងចំណោមយុវជនជំនាន់ក្រោយ ធានាការគ្រប់គ្រងសំរាម ថែរក្សាអនាម័យបរិស្ថាន និង សុខុមាលភាពប្រជាពលរដ្ឋបានល្អប្រសើរ។

យុទ្ធសាស្ត្រទី២ ភាពបៃតង ផ្តោតលើមុំ ការពង្រីកចលនាដាំដើមឈើការជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការលើកកម្ពស់ជីវភាព សហគមន៍មូលដ្ឋាន និងយុទ្ធសាស្ត្រទី៣ ចីរភាព ផ្តោតលើមុំ ការអនុវត្តអនុលោមភាព ការពង្រីកកិច្ចសហប្រតិបត្តិការ និងការពង្រឹងការសម្របសម្រួល។

ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល បានបញ្ជាក់ថាការរៀបចំបាឋកថា មានគោលបំណងសំខាន់ៗ



រួមមានទី១៖ ដើម្បីផ្តល់ឱកាសដល់កម្មសិក្សាការី បានជួបប្រាស្រ័យ និងទទួលការណែនាំពីថ្នាក់ដឹកនាំដោយផ្ទាល់។ ទី២៖ ជាឱកាសដ៏មានតម្លៃសម្រាប់កម្មសិក្សាការី ដើម្បីទទួលបាននូវការចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ការងារនៅក្នុងវិស័យបរិស្ថាន។

សូមបញ្ជាក់ថា កម្មសិក្សាការីវគ្គមន្ត្រីជាន់ខ្ពស់ មន្ត្រី



គ្រប់គ្រងរដ្ឋបាល មន្ត្រីមធ្យម( ថ្នាក់គុណធម៌ ) និងមន្ត្រីក្រមការ ចំនួន ២៣៣អង្គ/នាក់( ស្រី៤៧នាក់, ព្រះសង្ឃ១១អង្គ )នៃសាលាភូមិន្ទរដ្ឋបាល បានចូលរួមដោយផ្ទាល់ ក្នុងកម្មវិធីបាឋកថារបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ លើសពីនេះមានការចូលរួមតាមប្រព័ន្ធអនឡាញ( Microsoft Teams ) ពីកម្មសិក្សាការីវគ្គមន្ត្រីមធ្យម( ថ្នាក់នវានុវត្តន៍ និងថ្នាក់គុណភាព ) ចំនួន១៥៧នាក់( ស្រី៣៨នាក់ )៕

# រដ្ឋមន្ត្រីក្រសួងបរិស្ថានបង្រៀនឱ្យយុវជនតបគុណឪពុកម្តាយ តាមរយៈការចេះរកលុយជាជាងសុំលុយពីឪពុកម្តាយ















ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានថ្លែងថា «ក្នុងនាមជាកូនម្នាក់ យើងមិនគួរណាសុំលុយពីឪពុកម្ដាយនោះទេ» ក្នុងឃ្លាដែលជាន័យប្រៀបធៀបនេះ គឺឯកឧត្តមរដ្ឋមន្ត្រីចង់បង្រៀនឱ្យយុវជនខ្មែរ ដែលមានចំណេះ ជំនាញ និងសមត្ថភាព ចូលរួមចំណែកក្នុងកិច្ចការពារបរិស្ថាន ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលជាបញ្ហាសកល តាមរយៈការរៀបចំឱ្យមានគម្រោងអភិវឌ្ឍន៍នានា ដើម្បីកៀរគរថវិកាពីអន្តរជាតិមកជួយអភិវឌ្ឍ និងលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋខ្មែរ ជាជាងនៅរង់ចាំតែសុំលុយរដ្ឋយកទៅប្រើប្រាស់។

ចំពោះក្រសួងបរិស្ថានវិញ នឹងគាំទ្រយ៉ាងពេញទំហឹងលើគម្រោងអភិវឌ្ឍន៍ និងគម្រោងវិនិយោគទាំងឡាយណាដែល ឆ្លើយតបនឹងបញ្ហាបរិស្ថាន ហើយជាគម្រោងដែលច្នៃប្រឌិតចេញពីគំនិតរបស់យុវជនខ្មែរ។ ការថ្លែងឡើងរបស់ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងបរិស្ថាននេះ គឺធ្វើឡើងនៅចំពោះមុខសិស្សនិស្សិតនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញប្រមាណជាង ២ ០០០នាក់ នៅក្នុងពិធីផ្ដល់ បាឋកថាស្ដីពី យុទ្ធសាស្ត្រ

















ចក្រាវិស័យបរិស្ថាន នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤។

ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានលើកយកឧទាហរណ៍ជាក់ស្តែង ដែលយុវជនខ្មែរមួយក្រុមជាសិស្សនិស្សិតចេះឆ្នៃកាកអំពៅយកទៅធ្វើជាចានក្រដាសប្រើប្រាស់ជំនួសឱ្យប្លាស្ទិកបាន។ នេះហើយជាគំនិតច្នៃប្រឌិតរបស់កូនខ្មែរ ដែលអាចស្រូបទាញការវិនិយោគ គម្រោងអភិវឌ្ឍន៍នានាពីអន្តរជាតិ មកជួយដល់ប្រជាពលរដ្ឋខ្មែរនៅតាមសហគមន៍ជនបទជាពិសេសប្រជាសហគមន៍នៅតាមតំបន់ការពារធម្មជាតិ ដែលនេះជាទង្វើ និងជាបទពិសោធន៍ល្អរបស់ប្រទេសអភិវឌ្ឍន៍ ដែលមានប្រជាពលរដ្ឋចេះជួយរកប្រាក់ចំណូលជូនប្រទេស ហើយមិនរង់ចាំតែការជួយពីរដ្ឋនោះឡើយ។



## «ភាពស្មោះត្រង់ គឺជាគន្លឹះតែមួយគត់ ដែលនាំឱ្យរដ្ឋមន្ត្រីក្រសួងបរិស្ថាន ទទួលបានភាពជោគជ័យ ទាំងក្នុងអាជីពការងារ និងជីវិតគ្រួសារ»

រដ្ឋមន្ត្រីក្រសួងបរិស្ថានប្រាប់ពីគន្លឹះជោគជ័យដល់សិស្ស និស្សិតអាហារូបករណ៍ «ភាពស្មោះត្រង់ គឺជាគន្លឹះតែមួយគត់ ដែលនាំឱ្យរដ្ឋមន្ត្រីក្រសួងបរិស្ថាន ទទួលបានភាពជោគជ័យទាំងក្នុងអាជីពការងារ និងជីវិតគ្រួសារ»។ សារលើកទឹកចិត្តពោរពេញដោយបទពិសោធន៍ជីវិតរបស់ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានផ្ញើជូនដោយចំពោះសិស្សនិស្សិតអាហារូបករណ៍ចំនួន៦៦រូប ដែលបានចូលជួបសម្តែងការគួរសម និងសុំមតិណែនាំដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រី នារសៀលថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងបរិស្ថាន។






















ជាមួយនឹងពាក្យគន្លឹះ រួមនិងការណែនាំនូវបទពិសោធន៍ជាក់ស្តែងក្នុងការសិក្សានៅក្រៅប្រទេសរបស់ ឯកឧត្តម រដ្ឋមន្ត្រី សិស្សនិស្សិតបានប្តេជ្ញាចិត្តយ៉ាងមុតមាំ នឹងនាំមកនូវលទ្ធផលជោគជ័យនៃការសិក្សាមកជូនប្រទេសកម្ពុជាវិញ ទន្ទឹមនឹងនេះដែរ និស្សិតអាហារូបករណ៍នឹងរួមចំណែកផ្សព្វផ្សាយអំពីប្រទេសកម្ពុជាឱ្យបរទេសបានដឹង បានស្គាល់តាមរយៈភាពភាពស្អាត ភាពបៃតង ដែលក្រសួងបរិស្ថានបានកំពុងអនុវត្តយ៉ាងសកម្ម ស្របតាមយុទ្ធសាស្ត្រចបញ្ចកោណ ដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧។

សូមជម្រាបជូនថា និស្សិតអាហារូបករណ៍ចំនួន ៦៦រូប (ស្រី១៨រូប) ជានិស្សិតអាហារូបករណ៍ Erasmus+ AFD ប្រទេសបារាំង JDS ប្រទេសជប៉ុន និស្សិតអាហារូបករណ៍ប្រទេសកូរ៉េ ប្រទេសចិន និង និស្សិតអាហារូបករណ៍ប្រទេសហុងគ្រី៕

# កិត្តិនាមកម្ពុជាស្អាត លើឆាកអន្តរជាតិ គឺអាស្រ័យលើសំឡេងរបស់ក្រុមយុវជនអ្នកស្រឡាញ់បរិស្ថាន

នៅក្នុងជំនួបសំណេះសំណាល ជាមួយក្រុមយុវជនអ្នកស្រឡាញ់បរិស្ថាន សកម្មជនបរិស្ថាន យុវជនសំរាម និងនិស្សិតប្លាស្ទិក នារសៀលថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានលើកឡើងថា កិត្តិនាមកម្ពុជាស្អាតលើឆាកអន្តរជាតិ គឺអាស្រ័យលើសំឡេងរបស់ក្រុមយុវជនអ្នកស្រឡាញ់បរិស្ថាន។

ឯកឧត្តមបណ្ឌិតអ៊ាង សុផល្លែត បានថ្លែងអំណរគុណ និងគាំទ្រ ចំពោះក្រុមយុវជនអ្នកស្រឡាញ់បរិស្ថាន ដែលបានរួមចំណែកធ្វើឱ្យកម្ពុជាស្អាត តាមរយៈការចូលរួមសំអាតអនាម័យបរិស្ថាន រើសសំរាម សំណល់ប្លាស្ទិកពីក្នុងលូប្រឡាយ នៅមុខរោងចក្រ និងនៅតាមទីសាធារណៈនានា ដើម្បីប្រមូលទុកដាក់ឱ្យបានត្រឹមត្រូវ។

ឯកឧត្តមរដ្ឋមន្ត្រីបានបន្ថែមថា ដើម្បីកម្ពុជាស្អាត ចាំបាច់ត្រូវមានការចូលរួមពីយុវជន និងភាគីពាក់ព័ន្ធទាំងអស់ធ្វើការរួមគ្នា ហើយក្នុងនោះយើងបានចាប់ផ្តើមពីចំណុចដំបូងគេ គឺធ្វើឱ្យប្រជាពលរដ្ឋ និងសិស្សានុសិស្ស បានបង្កើតផ្នត់គំនិតស្អាត ហើយភាពស្អាតដែលផុសចេញពីចិត្តស្អាតនេះ បានធ្វើឱ្យយើងបានកាត់បន្ថយថង់ប្លាស្ទិកប្រមាណជាង ៣០លានថង់ក្នុង១ថ្ងៃ និងកាត់បន្ថយការនាំចូលថង់ប្លាស្ទិកប្រមាណជាង ៧០ភាគរយ នៅក្នុងដើមត្រីមាសដំបូង នៃឆ្នាំ២០២៤នេះ។

យោងតាមប្រសាសន៍ដ៏ថ្លៃថ្លារបស់ ឯកឧត្តមរដ្ឋមន្ត្រី អ៊ាង សុផល្លែត លទ្ធផលសម្រេចបាននាពេលនេះ គឺជាការ





















សបញ្ជាក់យ៉ាងច្បាស់ ពីភាពជោគជ័យនៃវិធានការការពារបរិស្ថានកម្ពុជា ហើយលើសពីវិធានការការពារ ក្រសួងបរិស្ថាន និងក្រុមយុវជនអ្នកស្រឡាញ់បរិស្ថាន រួមទាំងអ្នកពាក់ព័ន្ធទាំងអស់ បានបន្តទៅដល់ការព្យាបាល គឺជាការរួមគ្នាក្នុងយុទ្ធនាការ «កម្ពុជាស្អាត ខ្មែរធ្វើបាន!»។ ដែលកំពុងរីកសាយភាយនូវភាពស្អាត ពីភូមិទៅដល់ឃុំ បន្តទៅដល់ស្រុកនិងរហូតទៅដល់ខេត្ត នៅទូទាំងប្រទេសកម្ពុជា ដើម្បីបង្ហាញពីបទពិសោធន៍ស្អាតនេះ ទៅដល់ឆាកអន្តរជាតិថា កម្ពុជាដែលជាផ្ទះរបស់យើងទាំងអស់គ្នាស្អាតណាស់ ហើយយើងក៏មិនអនុញ្ញាតឱ្យអ្នកដទៃណាម្នាក់ មកវាយតម្លៃ ឬទិតៀន ប្រមាថថាកម្ពុជាបែបនេះ ឬបែបនោះទៀតឡើយ។

ឯកឧត្តមបណ្ឌិត បានបញ្ជាក់ដែរថា កម្លាំងសាមគ្គីរបស់យុវជន និងប្រជាពលរដ្ឋខ្មែរ គឺពិតជាចលករស្អាតដ៏សំខាន់ខ្លាំងក្លា ក្នុងការនាំកម្ពុជាឈានឆ្ពោះទៅកាន់ទម្លាប់ស្អាត គឺ«កម្ពុជាស្អាត ខ្មែរធ្វើបាន!»៕

# ផ្នែកទី៣
## កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងការទូត
## ឆ្លើយតបនឹងការងារអាទិភាព គឺភាពស្អាត

# ក្រសួងបរិស្ថាន និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) រួមគ្នាបង្កើតស្ថានីយបណ្តុះកូនឈើ សម្រាប់ចែកជូនប្រជាជនដោយឥតគិតថ្លៃ

ទីស្តីការក្រសួងបរិស្ថាន

នារសៀលថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៤ ឯកឧត្តម បណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង លោកស្រី Alissa Chaker តំណាង UNDP បានចុះកិច្ចព្រមព្រៀងលើការចាប់ផ្តើមអនុវត្តគម្រោង « ពង្រឹងយុទ្ធសាស្ត្របៃតងតាមរយៈស្ថានីយ៍បណ្តុះកូនឈើថ្នាក់តំបន់នៅកម្ពុជា» ដោយផ្តោតលើការកសាងផែនការមេសម្រាប់សាងសង់ស្ថានីយ៍បណ្តុះកូនឈើចំនួន ៥តំបន់ ដែលមានលក្ខណៈ បន្សុាំ ទៅនឹងការប្រែប្រួលអាកាសធាតុ នវានុវត្តន៍ និងទំនើបកម្មនៅខេត្តកោះកុង កំពង់ស្ពឺ សៀមរាប ត្បូងឃ្មុំ និង មណ្ឌលគិរី ដោយចាប់ផ្តើមអនុវត្តសាងសង់ស្ថានីយ៍ចំនួន ១កន្លែងក្នុងក្របខ័ណ្ឌគម្រោងនេះ។

លោកស្រី Alissa បានបញ្ជាក់ថាក្នុងនាម UNDP គឺសាទរចំពោះយុទ្ធនាការកាត់បន្ថយប្លាស្ទិច និងការដាំឈើ ១លានដើម របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលគម្រោងនេះនឹងរួមចំណែកដ៏ធំក្នុងការបង្កើននូវគម្របព្រៃឈើឱ្យបាន៦០% និងសម្រេចការអភិវឌ្ឍប្រកបដោយអព្យាក្រឹត្យកាបូន នៅឆ្នាំ២០៥០ របស់រាជរដ្ឋាភិបាលកម្ពុជា។

ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី បានថ្លែងអំណរគុណដល់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) ដៃគូអភិវឌ្ឍន៍និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានគាំទ្រលើព្រឹត្តិការណ៍ «ពន្លកបៃតង» ដែលរាជរដ្ឋាភិបាល និងក្រសួងបរិស្ថាន បាន និងកំពុងតែប្រឹងប្រែងសម្រេចឱ្យបាននូវឆន្ទៈនយោបាយរបស់កម្ពុជា និងការបង្កើតស្ថានីយបណ្តុះកូនឈើ ការដាំកូនឈើ និងស្តារព្រៃឈើឡើងវិញ ដែលនេះគឺជាយុទ្ធសាស្ត្រ








មួយដ៏សំខាន់ សម្រាប់ធានាដល់ការការពារជីវៈចម្រុះ ការថែរក្សាសេវាកម្ម ប្រព័ន្ធអេកូឡូស៊ី និងការកាត់បន្ថយ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន ដែលរស់នៅក្នុងនិងក្បែរតំបន់ការពារធម្មជាតិ តាមរយៈការលក់ឥណទានកាបូនពីការថែរក្សាការពារព្រៃឈើ និងសកម្មភាពអភិវឌ្ឍន៍ប្រកបដោយចីរភាព៕

# វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល GGGI សរសើរក្រសួងបរិស្ថាន ចំពោះកិច្ចការពារបរិស្ថាន

លោកស្រី ហេឡេណា មក្លូដ (Helena McLeod) អគ្គនាយិការងនៃវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល Global Green Growth Institute (GGGI) បានកោតសរសើរចំពោះសមិទ្ធផលរួម ដែលក្រសួងបរិស្ថានសម្រេចបានក្នុងភាពជាដៃគូជាមួយនឹង GGGI។

ការសម្រេចបាននូវសមិទ្ធផលរួមគ្នានេះ ដោយសារបានរួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងបង្កើតភាពបៃតង និងភាពស្អាតរបស់កម្ពុជា។ លើសពីនេះ លោកស្រីអគ្គនាយិការងនៃវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល(GGGI) ក៏បានអរគុណចំពោះរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលបានយកចិត្តទុកដាក់ និងតាមដានការអនុវត្តគម្រោង ហើយថែមទាំងបានផ្តល់នូវគំនិតយោបល់នានា ដើម្បីពង្រីកការអនុវត្តគម្រោងរហូតទទួលជោគជ័យ។







ស្របនឹងការលើកឡើងរបស់ លោកស្រី ហេឡេណា មក្លូដ (Helena McLeod) ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក៏បានអរគុណចំពោះ GGGI ដែលបានផ្តល់ការគាំទ្របច្ចេកទេសដល់មន្ត្រីគម្រោង ហើយតាមរយៈកិច្ចសហប្រតិបត្តិការនេះ







ទៀតសោត បានជួយទៅដល់គម្រោងអភិវឌ្ឍន៍បៃតង ដូចជា Eu-Switch Garment ដែលជាវិធានប្រតិបត្តិមាត្រា៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពី ការប្រែប្រួលអាកាសធាតុ។ លើសពីនេះ GGGI ក៏បានគាំទ្រសកម្មភាពអភិវឌ្ឍន៍គម្រោងបៃតងរបស់ក្រសួងបរិស្ថាន និងបានចូលរួមគាំទ្រដល់យុទ្ធនាការ «ថ្ងៃនេះខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» យុទ្ធនាការដាំកូនឈើជាង ១លានដើមក្នុង១ឆ្នាំៗ និងចូលរួមអភិវឌ្ឍគម្រោង ស្តារអាងទន្លេសាបនាពេលថ្មីៗនេះផងដែរ។

សូមជម្រាបថា ជំនួបសម្តែងការគួរសម និងពិភាក្សាការងារនៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) បានធ្វើឡើងនៅទីស្តីការក្រសួងបរិស្ថាន នាថ្ងៃពុធ ទី៨ ខែឧសភា ឆ្នាំ២០២៤៕

## ទូតបារាំង និងក្រសួងបរិស្ថានផ្លាស់ប្តូរទស្សនទានស្តីពី សន្និសីទមហាសមុទ្រលើកទីពីររបស់អង្គការសហប្រជាជាតិ (UNOC3)

ទីស្តីការក្រសួងបរិស្ថាន៖ នៅថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានទទួលជួបឯកឧត្តមឯកអគ្គរដ្ឋទូតសាធារណៈ រដ្ឋបារាំង H.E Mr. Jacques Pellet ដើម្បីពិភាក្សាការងារស្តីពី ការផ្លាស់ប្តូរទស្សនទានអំពី សន្និសីទមហាសមុទ្រលើកទី៣ របស់អង្គការសហប្រជាជាតិ (UNOC3) ដែលនឹងប្រព្រឹត្តទៅនៅទីក្រុង Nice ក្នុងខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ។

ជាមួយគ្នានេះ ឯកឧត្តមឯកអគ្គរដ្ឋទូតសាធារណៈរដ្ឋបារាំង H.E Mr. Jacques Pellet ក៏បានស្នើឱ្យមានការចូលរួមពីក្រសួងបរិស្ថានកម្ពុជា ដើម្បីប្រមូលធាតុចូលសំខាន់ៗ សម្រាប់ «កិច្ចពិភាក្សាឆ្ពោះទៅកាន់មហាសមុទ្រប្រកបដោយនិរន្តរភាព និងសុខមាលភាព (Blue Talk)» ព្រមទាំងកំណត់អំពីបញ្ហាប្រឈមនានានិងការបង្កើតផែនទីបង្ហាញផ្លូវរួមគ្នា សម្រាប់ការការពារមហាសមុទ្រ។











## ក្រសួងបរិស្ថានសហការជាមួយប្រទេសអាល្លឺម៉ង់ ពង្រឹងការអនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ឆ្ពោះទៅភាពស្អាតរបស់កម្ពុជា

នៅទីស្តីការក្រសួងបរិស្ថាន រសៀលថ្ងៃពុធ ទី២៨ ខែសីហា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាននិងឯកឧត្តម Stefan Messerer ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំនៅកម្ពុជា បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធី ចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងក្រសួងបរិស្ថាននិង ក្រុមហ៊ុន Everwave GmbH លើការអនុវត្តគម្រោង Blue Cambodia-Everwave´s cleanup Project ដែលរៀបចំនិងអនុវត្តលើគម្រោងសម្អាតអនាម័យបរិស្ថាន រួមបញ្ចូលទាំងការប្រមូលសំណល់ ក្នុងនិងក្បែរប្រភពទឹក និងការញែកសំណល់ផងដែរ។ ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានថ្លែងអំណរគុណចំពោះសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រជាជនអាល្លឺម៉ង់ និង អង្គការដៃគូសហការ ដែលបានយកចិត្តទុកដាក់ខ្ពស់លើ



បញ្ហាបរិស្ថានទាំងក្នុងតំបន់ និងសកល ជាពិសេសការកាត់បន្ថយការបំពុលដោយប្លាស្ទិក។

សូមបញ្ជាក់ថា នៅក្នុងអាណត្តិទី៧ នៃរដ្ឋសភារាជរដ្ឋាភិបាលបានដាក់ចេញ នូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ហើយតាមរយៈយុទ្ធសាស្ត្រនេះ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការណែនាំ និងចង្អុលបង្ហាញ ដល់ក្រសួងបរិស្ថាន ឱ្យរៀបចំឡើងនូវយុទ្ធសាស្ត្រចក្រា ដែលមានសរសរស្តម្ភបី នោះគឺ ភាពស្អាត ភាពបៃតង និងចីរភាព។ សរសរស្តម្ភទីមួយ ភាពស្អាត គឺភាពស្អាតលើដី ភាពស្អាតក្នុងទឹក និងភាពស្អាតក្នុងបរិយាកាស សំដៅធ្វើយ៉ាងណាឱ្យផ្ទះយើង សង្គមយើង ប្រទេសយើងមានភាពស្អាត។

សម្រាប់ភាពស្អាតលើដី ក្រសួងបរិស្ថាន តាមរយៈយុទ្ធសាស្ត្រចក្រាសម្រាប់វិស័យបរិស្ថាន បានដាក់ចេញនូវយុទ្ធនាការ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» សំដៅដល់ការទប់ស្កាត់ការប្រើប្រាស់ថង់ប្លាស្ទិក នៅកម្ពុជា និងឆ្ពោះទៅ















អនាគតកម្ពុជាស្អាត។ ជាលទ្ធផល រហូតមកដល់ពេលនេះ មានការចូលរួមយ៉ាងផុលផុសពីសិស្សានុសិស្សទូទាំងប្រទេស រួមទាំងកម្មករ កម្មការិនី និងប្រជាពលរដ្ឋគ្រប់ស្រទាប់ ព្រមទាំងព្រះសង្ឃ បានចូលរួមប្តេជ្ញាចិត្តមិនប្រើប្រាស់ថង់ប្លាស្ទិក សរុបប្រមាណជាង ៩,៥លានអង្គ/នាក់។

បន្ទាប់ពីបានទទួលជោគជ័យពីយុទ្ធនាការនេះ ដែលជាយុទ្ធនាការប្តេជ្ញាចិត្តហើយ ក្រសួងបរិស្ថានបានដាក់ ចេញនូវយុទ្ធនាការជំហានទី២ ដែលជាយុទ្ធនាការអនុវត្ត នោះគឺយុទ្ធនាការ«កម្ពុជាស្អាត ខ្មែរធ្វើបាន» ដែលតម្រូវឱ្យមានការចូលរួម ចំណាយពេល ដើម្បីសម្អាត ជុំវិញបរិវេណផ្ទះ រោងចក្រសហគ្រាស សាលារៀន និងនៅតាមទីអារាមផងដែរ។ ជាថ្មីម្តងទៀត យុទ្ធនាការនេះ កំពុងទទួលបានជោគជ័យគួរជាទីមោទនៈ ដោយរយៈពេលត្រឹមតែជិត៣ខែតែប៉ុណ្ណោះ បានទទួលការគាំទ្រ និងចូលរួមពីសំណាក់អាជ្ញាធរដែនដី បងប្អូនប្រជាពលរដ្ឋ ព្រះសង្ឃនិងសិស្សានុសិស្ស ចូលរួមសរុប ២ ៣៩៤ ១៩៣ អង្គ/នាក់ នៅតាមឃុំសង្កាត់ ចំនួន៦៣៤ និងក្រុង ស្រុក ខណ្ឌ ១២៤ ក្នុងខេត្តនិងរាជធានីទូទាំងប្រទេស។

អ្នកនាំពាក្យក្រសួងបរិស្ថាន បានលើកឡើងថា ក្រសួងបរិស្ថាននឹងដាក់ចេញនូវយុទ្ធនាការជំហានទីបី នោះគឺការទុកដាក់និងញែកសំរាមឱ្យបានត្រឹមត្រូវ ដើម្បីឱ្យប្រទេសកម្ពុជាយើង ទទួលបានភាពស្អាត៕

## ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត
## «កម្ពុជាត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការថែទាំសុខភាពសមុទ្រ»

កម្ពុជានឹងចូលរួមយ៉ាងសកម្មក្នុងការធានាទាញយកធនធានធម្មជាតិ សមុទ្រប្រកបដោយនិរន្តរភាព។

«យើងកំពុងប្រឈម មុខនឹងការប្រែប្រួលអាកាសធាតុ ហើយយើងក៏មិនចង់ឃើញសមុទ្ររបស់យើងទទួលរងពីវាទេ» ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានថ្លែងបែបនេះ នៅក្នុងឱកាសអញ្ជើញជាអធិបតីបើកវេទិកាពិភាក្សាសមុទ្រខៀវ (Blue Sky) រៀបចំឡើងដោយស្ថានទូតបារាំងប្រចាំកម្ពុជា នៅខេត្តព្រះសីហនុ នាថ្ងៃអង្គារ ទី២៣ ខែកក្កដា ឆ្នាំ២០២៤ ។ ក្នុងឱកាសនេះ ឯកឧត្តមរដ្ឋមន្ត្រី បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការការពារបរិស្ថាន និងជីវចម្រុះសមុទ្រ ដោយបានស្វាគមន៍កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធពីដៃគូពាក់ព័ន្ធ ដើម្បីចែករំលែកចំណេះដឹងនិងកិច្ចសហប្រតិបត្តិការ ក្នុងការថែទាំសុខភាពសមុទ្រ។ វាច្បាស់ណាស់ថា ការបំពុលដោយសំណល់សំរាមប្លាស្ទិក កើតឡើងដោយការមិនទាន់បានទុកដាក់សំរាមបានល្អ ដែលបណ្ដាលឱ្យមានការកើនឡើង និងផលប៉ះពាល់អវិជ្ជមានលើសុខភាពមនុស្ស សង្គម សេដ្ឋកិច្ច បរិស្ថាន រួមទាំងការបំពុលសមុទ្រ និងសត្វព្រៃ។ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានលើកឡើងបន្ថែមថា ដើម្បីអភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃមហាសមុទ្រ និងធនធានសមុទ្រសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព គឺជាកាតព្វកិច្ចរួមរបស់យើងរបស់ប្រទេសទាំងអស់គ្នា។

លើសពីនេះ ឯកឧត្តមរដ្ឋមន្ត្រី បានបញ្ជាក់ថា នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ហើយតាមរយៈយុទ្ធសាស្ត្រនេះ សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការណែនាំ និងចង្អុលបង្ហាញដល់ក្រសួងបរិស្ថាន ឱ្យរៀបចំឡើងនូវ



















យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ដែលមានសសរស្តម្ភបី នោះគឺ ភាពស្អាត ភាពបៃតង និងចីរភាព។

ឯកឧត្តមរដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា ចំពោះភាពស្អាតកម្ពុជា ក្នុងរយៈពេល១១ ខែកន្លងមកនេះ យើងបានចាប់ផ្តើមយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក នោះមិនត្រឹមតែជាជំហានមួយ ហួសពីការពង្រីកការប្តេជ្ញាចិត្ត និងថែមទាំងបានអនុវត្តការងារនានា ដើម្បីធានាថាកម្ពុជាស្អាត។ យើងដឹងហើយថា ការចោលសំរាមក្នុងសមុទ្រជាបញ្ហាមិនមែនតែនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែនៅទូទាំងពិភពលោក។ ប៉ុន្តែយើងធ្វើការឆ្ពោះទៅរកការកាត់បន្ថយ ឬបើអាចលុបបំបាត់ការចោលសំរាមតាមសមុទ្រនៅកម្ពុជា។

ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានសង្កត់ធ្ងន់ថា គិតត្រឹមថ្ងៃនេះ កម្ពុជាបានចាប់ផ្តើមយុទ្ធនាការមួយដែលមានឈ្មោះថា «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» យើងទទួលបានមនុស្សចូលរួមពីមនុស្សជាង ៨លាននាក់ ឱ្យចូលរួមក្នុងយុទ្ធនាការដែលខ្ញុំហៅថាគ្រាន់តែជាយុទ្ធនាការប្តេជ្ញាចិត្ត។ យើងបានចាប់ផ្តើមយុទ្ធនាការទីពីរ ដែលមានឈ្មោះថា






«កម្ពុជាស្អាត ខ្មែរធ្វើបាន» រហូតដល់ពេលនេះ យើងទទួលបានឃុំ សង្កាត់ ចំនួនជាង ៦០០ ក្នុងចំណោមឃុំចំនួន ១ ៦៥២ ដែលបានចូលរួមត្រឹមតែពីរខែប៉ុណ្ណោះ។ ក្រឡេកទៅមើលស្ថិតិ ប្រទេសកម្ពុជាបានកាត់បន្ថយការប្រើប្រាស់ផ្លាស្ទិក បានចំនួន ៧៤,១% ក្នុងរយៈពេល ១១ខែកន្លងមកនេះ បើធៀបនឹងឆ្នាំមុន។ ប្រសិនគ្មានការកាត់បន្ថយទេ ចំនួនប្លាស្ទិកនេះ ប្រមាណពាក់កណ្ដាលអាចនឹងប៉ះពាល់ដល់បរិស្ថានអាចធ្លាក់ចូលទៅសមុទ្រ និងទន្លេ។ ស្ថិតិរបស់អង្គការសហប្រជាជាតិបានចេញផ្សាយកន្លងមកបង្ហាញថានៅឆ្នាំ២០៥០ ចំនួនប្លាស្ទិក នឹងមានច្រើនជាងចំនួនត្រីក្នុងមហាសមុទ្រ៕

## ប្រទេសនៃមហាអនុតំបន់ទន្លេមេគង្គពិនិត្យលើការប្រឈមសម្រាប់រក្សានិរន្តរភាពបរិស្ថាន

«មហាអនុតំបន់ទន្លេមេគង្គ ជាតំបន់ពោលពេញដោយសក្តានុពលធម្មជាតិ ប៉ុន្តែបច្ចុប្បន្នកំពុងប្រឈមនឹងការប្រែប្រួលអាកាសធាតុ តែតាមរយៈកិច្ចប្រជុំលើកទី៦ ថ្នាក់រដ្ឋមន្ត្រីបរិស្ថានមហាអនុតំបន់ទន្លេមេគង្គ ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ នឹងក្លាយជាកម្លាំងចលករដ៏សំខាន់ ដើម្បីលើកកម្ពស់គុណភាពបរិស្ថាន និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ព្រមទាំងគ្រោះមហន្តរាយធម្មជាតិ» ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានថ្លែងនៅក្នុងឱកាសអញ្ជើញជាអធិបតីភាព បើកជាផ្លូវការកិច្ចប្រជុំលើកទី៦ ថ្នាក់រដ្ឋមន្ត្រីបរិស្ថានមហាអនុតំបន់មេគង្គ និងកិច្ចប្រជុំពាក់ព័ន្ធ (The 6th GMS Environment Ministers′ Meeting, EMM-6) នៅព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤នេះ នៅរាជធានីភ្នំពេញ។ កិច្ចប្រជុំនេះមានការរួមពីសំណាក់គណៈប្រតិភូរដ្ឋមន្ត្រីបរិស្ថាននៃបណ្តាប្រទេសជាសមាជិកនៃមហាអនុតំបន់មេគង្គ ចំនួន៦ប្រទេសរួមមានប្រទេសចិន កម្ពុជា ឡាវ ថៃ មីយ៉ាន់ម៉ា និងវៀតណាម។

ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានលើកឡើងថា៖ «ការលើកកម្ពស់គុណភាពបរិស្ថាន មានសារៈសំខាន់ដើម្បីសុខុមាលភាព សុវត្ថិភាពរបស់ប្រជាជននៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។ ដើម្បីលើកកម្ពស់ពីគុណភាពបរិស្ថានល្អ មិនមែនត្រឹមតែសម្រាប់បរិស្ថានតែប៉ុណ្ណោះទេ ប៉ុន្តែ វាបានជួយដល់បញ្ហាសុខភាពសាធារណៈ និងតំបន់ទាំងមូល។

សូមបញ្ជាក់ថា ប្រទេសកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ ដើម្បីរៀបចំប្រកបដោយនិរន្តភាពបរិស្ថាននៅពេលអនាគត គោលនយោបាយដើម្បីការពារបរិស្ថាន លើកកម្ពស់ការអភិវឌ្ឍបៃតង និងធនធានធម្មជាតិ ជាពិសេសយុទ្ធសាស្ត្រចក្រាលើវិស័យបរិស្ថាន ២០២៣ ដល់២០២៨ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។ ដើម្បីកាត់បន្ថយការបំពុល និងភាពកង្វក់ដោយប្លាស្ទិក ក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធនាការ៣សំខាន់ ភាពស្អាតលើដី ភាពស្អាតក្នុងដែនទឹក





ភាពស្អាតដែនអាកាស រួមជាមួយការប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ ដើម្បីអនាគតកម្ពុជា ក៏ដូចជាតំបន់មួយប្រកបដោយនិរន្តរភាព។

«កិច្ចប្រជុំរដ្ឋមន្ត្រី GMS ជាឱកាសដែលដើម្បីធ្វើកិច្ចសហប្រតិបត្តិការ ប្រកបដោយនិរន្តភាព បង្កើតភាពជាដៃគូចែករំលែកចំណេះដឹង ធនធាន និងកសាងភាពធន់នឹងអាកាសធាតុនៅក្នុងតំបន់GMS ដើម្បីធានាថាធនធានធម្មជាតិរបស់យើងត្រូវបានធានា សម្រាប់យុវជនជំនាន់ក្រោយ» នេះជាការគូសបញ្ជាក់របស់ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត។

បើតាមលោកស្រី Fitima Yasmin អនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទទួលស្គាល់ថា មហាអនុតំបន់ទន្លេមេគង្គ (GMS) ពិតជាតំបន់ដែលសម្បូរទៅដោយធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងសក្តានុពលសេដ្ឋកិច្ច។ លោកស្រីបានបន្ថែមថា យ៉ាងណាក៏ដោយ វាក៏ជាតំបន់ដែលងាយរងគ្រោះកាន់តែខ្លាំងឡើងចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ បញ្ហាប្រឈមដែលយើងកំពុងជួបមានការកើនឡើងសីតុណ្ហភាព និងការប្រែប្រួល





















អាកាសធាតុជាដើម។ ADB ទទួលស្គាល់នូវតម្រូវការសំខាន់សម្រាប់សកម្មភាពបន្ទាន់ និងរួមគ្នា។ ការប្តេជ្ញាចិត្តរបស់យើងក្នុងការជួយដល់ប្រទេស GMS ក្នុងដំណើររបស់ពួកគេឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព គឺមិនផ្លាស់ប្តូរទេ។ «ភារកិច្ចនៅចំពោះមុខយើង គឺត្រូវរួមបញ្ចូលភាពធន់នឹងអាកាសធាតុ និង និរន្តរភាពបរិស្ថានទៅក្នុងគ្រប់ផ្នែកនៃផែនការអភិវឌ្ឍន៍ គោលនយោបាយ និងការវិនិយោគរបស់យើង។ អាស្រ័យហេតុ នេះ ADB បានប្តេជ្ញាបែងចែកធនធានផ្ទាល់របស់ខ្លួន ដែលមានទំហំទឹកប្រាក់ចំនួន១០០ពាន់លានដុល្លារ សម្រាប់សកម្មភាពអាកាសធាតុនៅអាស៊ី និងប៉ាស៊ីហ្វិកក្នុងរយៈពេល១២ឆ្នាំ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០» នេះជាការលើកឡើងបន្ថែមរបស់អនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី៕

**សុន្ទរកថា**

**ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ក្នុងវេទិកា ស្តីពី «ការការពារ និងអភិរក្សធនធានធម្មជាតិ»**

**និង «កិច្ចប្រជុំបណ្តាញសហគមន៍អភិរក្សធនធានធម្មជាតិថ្នាក់ជាតិ»**

**ក្រោមប្រធានបទ**

**«ពង្រឹងភាពជាដៃគូឆ្ពោះទៅអព្យាក្រឹតកាបូនសហគមន៍»**

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ក្រសួងបរិស្ថាន ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣

- សូមគោរព ឯកឧត្តមប្រធានគណៈកម្មការទី៣ នៃព្រឹទ្ធសភា និងឯកឧត្តមប្រធានគណៈកម្មការទី៣ នៃរដ្ឋសភា!
- ឯកឧត្តម លោកជំទាវ តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាទីអាប់អាន!
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ និងបងប្អូនសហគមន៍តំបន់ការពារធម្មជាតិ ជាទីមេត្រី!



1. ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនសហគមន៍តំបន់ការពារធម្មជាតិ ក្នុងពិធីបើកវេទិកាលើកទី១៦ ស្តីពី «ការការពារ និងអភិរក្សធនធានធម្មជាតិ» ក្រោមប្រធានបទ «ពង្រឹងភាពជាដៃគូ ឆ្ពោះទៅអព្យាក្រឹតកាបូនសហគមន៍» និង «កិច្ចប្រជុំបណ្តាញសហគមន៍អភិរក្សធនធានធម្មជាតិថ្នាក់ជាតិ» ដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននាពេលនេះ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានអញ្ជើញចូលរួម នាពេលនេះ។ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ដែលបានសម្របសម្រួលរៀបចំវេទិកាដ៏មានសារៈសំខាន់នេះឡើង។
2. ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១» ដើម្បីកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព សំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជនឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ អនុលោមតាមយុទ្ធសាស្ត្រខាងលើ ក្រសួងបរិស្ថាន ក្នុង រយៈពេល១០០ ថ្ងៃដំបូង នៃរាជរដ្ឋាភិបាលអាណត្តិទី៧ សម្រេចបានសមិទ្ធផលធំៗ ជាអាទិ៍៖

ទី(១) បានរៀបចំយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (២០២៣-២០២៨) និងសម្ពោធដាក់ឱ្យប្រើប្រាស់ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅ។ ការរៀបចំយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ដើម្បីតម្រង់ទិស និងចង្អុលបង្ហាញអាទិភាពការងារ ក្នុងការលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការការពារធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងមុំចំនួនបី គឺ ភាពស្អាត ភាពបៃតង និងចីរភាព សំដៅឆ្ពោះទៅសម្រេចការអភិវឌ្ឍប្រកបដោយអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។ យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ក៏នឹងប្រើប្រាស់

ជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តឱ្យចំគោលដៅអាទិភាព ផ្តល់សេវាសាធារណៈឱ្យចំតម្រូវការរបស់សាធារណជន និងប្រែក្លាយសក្តានុពលវិស័យបរិស្ថាន ឱ្យក្លាយទៅជាឧត្តមប្រយោជន៍បម្រើដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់ និងចូលរួមចំណែកឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុសកល។យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន(២០២៣-២០២៨) ត្រូវបានរចនាឡើងជារូបរង្វង់ (កងចក្រ) ដោយមានយុទ្ធសាស្ត្រស្នូលផ្តោតសំខាន់លើ មុំបី គឺការពង្រឹងគោលនយោបាយការកសាងរដ្ឋបាលឌីជីថល និងការពង្រីកការផ្សព្វផ្សាយដែលមុំទាំងបីនេះ ជាកម្លាំងចលកររុញបង្វិលយុទ្ធសាស្ត្រចំនួនបីផ្សេងទៀត ឱ្យមានដំណើរការដោយភាពរលូន និងប្រសិទ្ធភាព។

ទី(២) បានធ្វើយុទ្ធនាការ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» និង «យើងរួមកម្លាំងគ្នា ការពារបរិស្ថានកម្ពុជា» ជាមួយកីឡាករអ៊ុំទូក និងប្រជាពលរដ្ឋដែលមកកម្សាន្តនៅតាមដងទន្លេសាប មុខព្រះបរមរាជវាំង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦-២៨ ខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅ។ ផ្តើមចេញពីក្រសួងបរិស្ថាន យុទ្ធនាការ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» បាននិងកំពុងទទួលបានការគាំទ្រ និងចូលរួមជាបន្តបន្ទាប់តាមរយៈការចុះអនុស្សារណៈយោគយល់ ជាមួយក្រសួងបរិស្ថានរួមមាន រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលខេត្ត) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) អង្គការស្បៀងអាហារពិភពលោក(FAO) សមាគមកាយឫទ្ធិនារីកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា(ស.ស.យ.ក) សមាគមយុវជនស្រឡាញ់បរិស្ថាន សមាគមកសិករដើម្បីអភិវឌ្ឍន៍ជីវភាព និងអង្គការដៃគូអភិវឌ្ឍន៍ផ្សេងទៀត។ ការធ្វើយុទ្ធនាការ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ ប្លាស្ទិកទេ» បានចាប់ផ្តើមនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ បានរៀបចំឡើងនៅតាមសាលារៀន វត្តអារាម រោងចក្រ និងនៅតាមទីសាធារណៈផ្សេងៗ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស គិតរហូតមកដល់ពេលនេះ បាននិងកំពុងទទួលបានការគាំទ្រ និងចូលរួមដោយផ្ទាល់ពីសំណាក់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ កម្មកររោងចក្រ និងសាធារណជន សរុបប្រមាណជាង ៣,៥លាននាក់ ។



ទី(៣) បានធ្វើយុទ្ធនាការ «ប្រកាសផ្តល់កូនឈើ ៣០ម៉ឺនដើមក្នុង១ឆ្នាំ ដើម្បីចូលរួមយុទ្ធនាការដាំកូនឈើយ៉ាងតិច១លានដើមជារៀងរាល់ឆ្នាំ»។ យុទ្ធនាការដាំដើមឈើគ្រប់ប្រភេទយ៉ាងតិច១លានដើមជារៀងរាល់ឆ្នាំ ដើម្បីធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ក្នុងគោលដៅឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់សេដ្ឋកិច្ចបៃតង សំដៅសម្រេចគោលដៅយុទ្ធសាស្ត្របញ្ចកោណ គឺ «ជាប្រទេសអព្យាក្រឹតកាបូន និងមាន គម្របព្រៃឈើ៦០% នៅឆ្នាំ២០៥០»។ ការធ្វើយុទ្ធនាការផ្តល់កូនឈើ ៣០ម៉ឺនដើម បានចាប់ផ្តើមនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ នៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស ពោលគឺ ក្រសួង បរិស្ថានបានជំរុញ និងលើកទឹកចិត្តឱ្យមន្ទីរបរិស្ថានរាជធានី-ខេត្ត កែលម្អថ្នាល និងបណ្តុះកូនឈើ ដើម្បីចែកជូនប្រជាសហគមន៍ ក្រសួង-ស្ថាប័ន មន្ទីរពាក់ព័ន្ធ យ៉ាងហោចបាន ១០ម៉ឺនដើមក្នុងមួយឆ្នាំ ដើម្បីចូលរួមយុទ្ធនាការដាំកូនឈើចាប់ពីឆ្នាំ២០២៤តទៅ។ ក្រសួងបរិស្ថានកន្លងមកបានបណ្តុះកូនឈើច្រើនប្រភេទ ដូចជា ប្រភេទឈើហូបផ្លែ ប្រភេទឈើប្រណិត និងដើមកោងកាង នឹងត្រូវបានយកទៅដាំនៅតាមទីតាំងនានារួមមានៈ នៅព្រៃសហគមន៍តំបន់ការពារ ធម្មជាតិ ព្រៃរេចរឹលក្នុងតំបន់ការពារធម្មជាតិ សាលារៀន វត្តអារាម និងទីសាធារណៈជាដើម។

ទី(៤) បានចុះសំណេះសំណាល សួរសុខទុក្ខ «ប្រជាសហគមន៍តំបន់ការពារធម្មជាតិ និងមន្ត្រីឧទ្យានុរក្សនៅតាមតំបន់ការពារធម្មជាតិ»។ ដោយបានចាប់ផ្តើមនៅថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ បានចំនួន ១៥សហគមន៍ រួមមាន នៅខេត្តកំពង់ស្ពឺចំនួន ១សហគមន៍ ខេត្តកោះកុងចំនួន ៣សហគមន៍ ខេត្តកំពង់ឆ្នាំងចំនួន ៦សហគមន៍ និងខេត្តសៀមរាបចំនួន ៥សហគមន៍ ដើម្បីស្វែងយល់ពីតម្រូវការឆ្លើយតប និងការអភិវឌ្ឍមូលដ្ឋាន។ ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ គឺចាំបាច់ត្រូវបណ្តុះបណ្តាលធនធានមនុស្សនៅមូលដ្ឋាន ដើម្បីពង្រឹងសេវាកម្ម ផលិតផលសហគមន៍ និងជំរុញការនាំចេញនៅនឹងកន្លែង។ ក្រៅពីនេះ ត្រូវគិតគូរពីជម្រក សុវត្ថិភាពម្ហូបអាហារ អាហារូបត្ថម្ភ និងប្រាក់ចំណូលប្រចាំថ្ងៃរបស់សហគមន៍។

ដើម្បីសម្រេចគោលដៅខាងលើបាន ត្រូវមានជម្រើសមុខរបរ ដូចជា ការធ្វើកសិកម្ម ការចិញ្ចឹមសត្វ ការដាំឈើហូបផ្លែ និងជាមួយគ្នានេះដែរ ត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវ ផ្ទះស្នាក់ បង្គន់អនាម័យ ទឹកស្អាត ពង្រឹងសេវាកម្មទេសចរណ៍ អប់រំផ្សព្វផ្សាយ ម្ហូបអាហារត្រូវមានអនាម័យ ជាពិសេសទំនាក់ទំនងទីផ្សារសហគមន៍។

ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីមេត្រី!

3. ការអភិវឌ្ឍ និងការបង្កើតឱ្យមានសកម្មភាពសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន ដែលមានមេត្រីភាពជាមួយនឹងបរិស្ថាន គឺជាកិច្ចការដ៏ចាំបាច់ និងជា «យុទ្ធសាស្ត្រក្រវ៉ាត់បៃតង» ដើម្បីការពារតំបន់ស្នូល និងតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ និងការកែច្នៃសក្តានុពលធនធានធម្មជាតិ ដើម្បីចូលរួមលើកកម្ពស់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាព ជាពិសេសដើម្បីធានាបាននូវតុល្យភាពរវាងការអភិវឌ្ឍ ការអភិរក្ស និងការលើកកម្ពស់ជីវភាពរបស់សហគមន៍មូលដ្ឋាន។ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីរាប់អាន!

4. យើងជួបជុំគ្នាថ្ងៃនេះ ដើម្បីពិភាក្សា ផ្តល់ធាតុចូល និងចែករំលែកបទពិសោធន៍លើប្រធានបទដ៏មានសារៈសំខាន់ គឺ «ពង្រឹងភាពជាដៃគូឆ្ពោះទៅអព្យាក្រឹតកាបូនសហគមន៍» ដែលឆ្លុះបញ្ចាំងទៅនឹង «យុទ្ធសាស្ត្របញ្ចកោណ» និងស្របទៅនឹង «យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន» យុទ្ធសាស្ត្រទី២ «ភាពបៃតង» គឺការពង្រីកចលនាដាំដើមឈើ ការជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន ជាពិសេសទៅទៀតនោះប្រធានបទ (ខាងលើនេះ) គឺ បានឆ្លើយតបទៅនឹងការធ្វើយុទ្ធនាការរបស់ខ្ញុំ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ កន្លងទៅនេះ គឺការចូលរួមដាំកូនឈើគ្រប់ប្រភេទយ៉ាងតិច ១លានដើម ជារៀង រាល់ឆ្នាំ ដើម្បីធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ក្នុងគោលដៅឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់សេដ្ឋកិច្ចបៃតង សំដៅសម្រេចគោលដៅយុទ្ធសាស្ត្របញ្ចកោណ គឺ «ជាប្រទេសអព្យាក្រឹតកាបូន និងមានគម្របព្រៃឈើ៦០% នៅឆ្នាំ២០៥០»។



អង្គពិធីទាំងមូលជាទីរាប់អាន និងជាទីមេត្រី!

5. តាមរយៈរបាយការណ៍វឌ្ឍនភាពរបស់អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន សុន្ទរកថាស្វាគមន៍របស់លោកជំទាវ ម៉ុម ថានី រដ្ឋលេខាធិការក្រសួងបរិស្ថាន ក៏ដូចជាលទ្ធផលវេទិកាលើកទី១៥កន្លងទៅ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន បានដើរតួនាទីស្នូលយ៉ាងសំខាន់ក្នុងការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ការរៀបចំបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ និងការសម្របសម្រួលគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ដើម្បីចូលរួមការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការអភិរក្សបេតិកភណ្ឌធម្មជាតិ វប្បធម៌ សំដៅចូលរួមចំណែកកិច្ចគាំពារបរិស្ថាន ការចូលរួមលើកកម្ពស់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាព។ ការចូលរួមរបស់សហគមន៍មូលដ្ឋាន គឺជាចលករមួយយ៉ាងសំខាន់មិនអាចខ្វះបាន ក្នុងការការពារធនធានធម្មជាតិ និងការអភិវឌ្ឍនៅមូលដ្ឋាន។ ក្នុងន័យនេះ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ គឺចាំបាច់តម្រូវឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន ពីព្រោះថាពួកគាត់បាននឹងកំពុងរស់នៅក្បែរ និងក្នុងតំបន់ការពារ ធម្មជាតិ ព្រមទាំងបាននឹងកំពុងប្រើប្រាស់ធនធានធម្មជាតិសម្រាប់បំពេញតម្រូវការក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ឈរនៅលើទស្សនៈនេះ រាជរដ្ឋាភិបាល កម្ពុជាអាណត្តិកន្លងមក បានដាក់ចេញនូវគោលនយោបាយវិមជ្ឈការ និងវិសហ មជ្ឈការ ដើម្បីគាំទ្រ និងលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន និងសហគមន៍មូលដ្ឋាន ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ តាមរយៈការរៀបចំបង្កើតជាសហគមន៍នេសាទ សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ ដែលជាយុទ្ធសាស្ត្រសមស្របសំដៅធានាបាននូវកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋានប្រកប ដោយកាលានុវត្តភាព បរិយាបន្ន និងចីរភាព។

6. ជាការពិតណាស់ក្នុងរយៈពេលកន្លងមក យើងរួមគ្នាសម្រេចបាននូវសមិទ្ធផលការងារ គួរឱ្យកោតសរសើរនិងមានមោទនភាព ក៏ប៉ុន្តែយើងនៅមានចំណុចខ្វះខាតនិងបញ្ហាប្រឈមមួយចំនួន ដែលខ្ញុំយកឱកាសនេះគូសបញ្ជាក់ឡើងវិញ ដើម្បីឱ្យអង្គវេទិកាពិចារណា គិតគូរដោះស្រាយ និងធ្វើ

អន្តរាគមន៍ សម្រាប់ទិសដៅការងារឆ្នាំ២០២៤ ក៏ដូចជាវេទិកាបន្ទាប់ រួមមានដូចខាងក្រោម៖

ទី(១) បន្តពង្រឹងរចនាសម្ព័ន្ធ និងកសាងសមត្ថភាពបណ្តាញសហគមន៍ថ្នាក់មូលដ្ឋាន សម្រាប់បង្កលក្ខណៈងាយស្រួលក្នុងការពិគ្រោះយោបល់នានា រវាងសហគមន៍មូលដ្ឋាន និងរាជរដ្ឋាភិបាលក្នុងការស្វែងយល់ពីតម្រូវការ បញ្ហា ប្រឈម ដើម្បីរួមសហការគ្នារកដំណោះស្រាយទាក់ទងទៅនឹងកិច្ចការពារធនធានធម្មជាតិ និងការអភិវឌ្ឍនៅមូលដ្ឋាន។

ទី(២) បន្តការរៀបចំសហគមន៍នៅតាមតំបន់ការពារធម្មជាតិដែលបានបង្កើតថ្មី ដើម្បីប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានធម្មជាតិ។

ទី(៣) បន្តធ្វើបច្ចុប្បន្នភាពទីតាំងដីព្រៃសហគមន៍ រៀបចំនីតិវិធី និងបច្ចេកទេស ក្នុងការចុះសិក្សាកំណត់ប្រភេទ និងទំហំផ្ទៃដី និងជ្រើសរើសប្រភេទឈើដែលត្រូវដាំស្តារឱ្យបានសមស្របតាមទីតាំងជាក់ស្តែង និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ ក្នុងគោលដៅសម្រេចបានអព្យាក្រឹតកាបូន។

ទី(៤) បន្តការរៀបចំថ្នាលបណ្តុះកូនឈើព្រៃ និងកូនឈើហូបផ្លែ ដោយសហការជាមួយអង្គការដៃគូ វិស័យឯកជន ជាពិសេសមន្ទីរបរិស្ថានរាជធានី-ខេត្ត ដើម្បីរៀបចំផែនការបណ្តុះកូនឈើឱ្យបានយ៉ាងតិច ១០ម៉ឺនដើម ក្នុង១ខេត្ត ក្នុង១ឆ្នាំ និងរៀបចំផែនការដាំតាមលក្ខណៈបច្ចេកទេស និងការថែទាំឱ្យបានសមស្រប។

ទី(៥) កំណត់ទិសដៅការងារ ក្នុងការគាំទ្រ ជំរុញកសាងសមត្ថភាព និងជម្រើសមុខរបរ ដូចជា ការផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិ វប្បធម៌ ការដកហូត ការកែច្នៃអនុផលព្រៃឈើ និងការចិញ្ចឹមសត្វ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន។

ទី(៦) ជំរុញការប្រើប្រាស់ថាមពលកើតឡើងវិញ ដូចជា ថាមពលពន្លឺព្រះអាទិត្យ និងការប្រើប្រាស់ចង្ក្រានសន្សំសំចៃអុស សន្សំសំចៃការប្រើប្រាស់ទឹក ពង្រឹងការគ្រប់គ្រងសំណល់រឹង-រាវឱ្យបានត្រឹមត្រូវ ជាពិសេសបន្តយុទ្ធនាការ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» នៅតាមសហគមន៍ ជាប្រចាំ។

ទី(៧) ពង្រឹងយន្តការដែលមានស្រាប់ និង ពិនិត្យរៀបចំយន្តការថ្មីសមស្របប្រកបដោយនិរន្តរភាព ដើម្បីការបែងចែកផលប្រយោជន៍ពីឥណទានកាបូន ទេសចរណ៍ធម្មជាតិ ហិរញ្ញប្បទានចម្រុះ និងមូលនិធិបរិស្ថាន និងសង្គម ជាដើម។

ទី(៨) ស្នើឱ្យ ឯកឧត្តម លោកជំទាវ តំណាងក្រសួង-ស្ថាប័ន លោក លោកស្រី តំណាងគម្រោងអង្គការដៃគូ និងវិស័យឯកជន ពិនិត្យលទ្ធភាពក្នុងការផ្តល់អ្នកជំនាញឯកទេសលើផ្នែកកសិកម្ម ចិញ្ចឹមសត្វ កែច្នៃ វេចខ្ចប់ម្ហូបអាហារ សិប្បកម្ម តន្ត្រីសិល្បៈ ជួសជុលគ្រឿងយន្ត ព្រមទាំងជំនាញចាំបាច់ផ្សេងៗទៀត ដើម្បីជួយបណ្តុះបណ្តាលដល់ប្រជាសហគមន៍តំបន់ការពារ ធម្មជាតិ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ។

7. ការចូលរួមផ្តល់មតិយោបល់ និងអនុសាសន៍ របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងអង្គវេទិកានានាថ្ងៃនេះគឺពិតជាមានសារសំខាន់ និងផ្តល់ជាតុចូលដល់អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងអង្គវេទិកាទាំងមូលសម្រាប់យកទៅពិចារណារៀនសូត្រចែករំលែកបទពិសោធន៍ និងក្នុងការកំណត់គោលដៅជាអាទិភាពសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍ ឱ្យទទួលបានជោគជ័យ។

8. ជាថ្មីម្តងទៀត ខ្ញុំសូមយកឱកាសនេះ អរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គវេទិកាដ៏មានសារៈសំខាន់នេះ។

សូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សមាជិក សមាជិកា ទាំងអស់ ប្រកបដោយពុទ្ធពរទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងមានសុភមង្គលគ្រប់ក្រុមគ្រួសារ។

ខ្ញុំសូមប្រកាសបើកអង្គវេទិកាពិភាក្សា ចាប់ពីពេលនេះតទៅ! សូមអរគុណ!

# ផ្នែកទី៤

## ការពូនជ្រំចាក់គ្រឹះសន្តិភាពនៅក្នុងសង្គមកម្ពុជា

## សុន្ទរកថា

## ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តត្បូងឃ្មុំ
## ថ្លែងក្នុងពិធីបុណ្យសម្ពោធឆ្លង និងកាត់ខ្សែបូដាក់ឱ្យប្រើប្រាស់នូវសមិទ្ធិនានាក្នុងវត្តឧត្តម
## រង្សីរស្មីមហាសាមគ្គីសោយរាម ហៅវត្តសោយ
## ភូមិសោយ ឃុំមៀន ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ
## ថ្ងៃអាទិត្យ ៣រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
## ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤

- សូមក្រាបថ្វាយបង្គំ ព្រះអង្គ គន់ ចាន់ធុល ចៅអធិការវត្តឧត្តមរង្សីរស្មីមហាសាមគ្គីសោយរាម ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ
- ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តត្បូងឃ្មុំ
- គណៈធិបតី ភ្ញៀវកិត្តិយស សីលវន្តសីលវតី
- លោកយាយ លោកតា លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស បងប្អូនពុទ្ធបរិស័ទទាំងអស់ជាទីស្រលាញ់រាប់អាន!

ថ្ងៃនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានសេចក្តីសោមនស្សរីករាយ អភិរម ប្រកបដោយសទ្ធាជ្រះថ្លា និងកិត្តិយស ដែលបានមកចូលរួមក្នុងពិធីសម្ពោធឆ្លង និងកាត់ខ្សែបូដាក់ឱ្យប្រើប្រាស់នូវសមិទ្ធិនានារួមមាន កុដិថ្មកម្រាលសាប ឈាបនដ្ឋាន និងសមិទ្ធផលនានាជាច្រើនទៀតក្នុងវត្តឧត្តមរង្សីរស្មីមហាសាមគ្គីសោយរាម ហៅវត្តសោយ។ នេះជាសក្ខីកម្មនៃការរីកចម្រើននៃព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ក្រោមម្លប់នៃសុខសន្តិភាព។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអំណរគុណ ព្រមទាំងសូមកោតសរសើរយ៉ាងក្រៃលែងថ្វាយប្រគេនព្រះចៅអធិការវត្តសោយ លោកអាចារ្យ គណៈកម្មការ និងបងប្អូនពុទ្ធបរិស័ទជិតឆ្ងាយទាំងអស់ ដែលបានខិតខំកសាងសមិទ្ធផលទាំងនេះឡើង។ សូមឱ្យកុសលដែលកើតពីសទ្ធានៃការចូលរួមរបស់សប្បុរសជនទាំងឡាយបាននាំដល់សេចក្តីសុខសេចក្តីចម្រើននៃញាតិទាំងឡាយ។ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមថ្លែងអំណរគុណអាជ្ញាធរមូលដ្ឋាន និងក្រុមការងារចុះមូលដ្ឋានគ្រប់ថ្នាក់ ដែលបានខិតខំសហការ និងជួយជ្រោមជ្រែងក្នុងការបង្កើតសមិទ្ធិនានាក្នុងវត្តសោយ និងក្នុងមូលដ្ឋានឃុំមៀនទាំងមូល។

សមិទ្ធផលក្នុងពុទ្ធចក្រនាថ្ងៃនេះ ពិតណាស់គឺបានឆ្លុះបញ្ចាំងពីសាមគ្គីភាពប្រកបដោយចិត្តសទ្ធាជ្រះថ្លារបស់បងប្អូនប្រជាពលរដ្ឋ ពុទ្ធបរិស័ទគ្រប់រូប ហើយចិត្តជាសទ្ធានេះគឺបានមកពីចិត្តស្អាតគ្មានហ្មងសៅ គ្មានមន្ទិលក្នុងការប្រព្រឹត្តិនូវអំពើល្អ ដែលនេះជាការបង្ហាញថាប្រជាពលរដ្ឋខ្មែរយើងមានបេះដូងស្អាត ស្មោះត្រង់។ នៅក្នុងសិក្ខាបទសីលប្រាំព្រះពុទ្ធក៏បានសម្តែងដែរថា ការប្រព្រឹត្តសីលដែលជាសេចក្តីល្អ នឹងនាំមកនូវសេចក្តីសុខចម្រើន ហើយសុខ

ចម្រើននេះ មិនចំពោះតែបុគ្គលប៉ុណ្ណោះទេ គឺនឹងសាយភាពទៅដល់សង្គមជាតិទាំងមូល បើយើងគ្រប់គ្នាម្នាក់ប្រព្រឹត្តអំពើល្អ១ក្នុង១ថ្ងៃ នោះនឹងមានអំពើជាង១០លានអំពើល្អក្នុង១ថ្ងៃ ឈរលើគោលការណ៍ធម៌របស់នៃឱវាទរបស់ព្រះពុទ្ធនេះ ទើបក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធនាការកាត់បន្ថយប្លាស្ទិក ជាការពិតយុទ្ធនាការបានទទួលជោគជ័យពិតមែនតាម រយៈការចូលរួមធ្វើល្អចំពោះភពផែនដីរបស់យើងពីសំណាក់បងប្អូនប្រជាពលរដ្ឋជាពិសេសក្មួយៗសិស្សានុសិស្ស ដែលបានរួមគ្នាជាធ្លុងមួយប្តេជ្ញាឈប់ប្រើថង់ប្លាស្ទិកឱ្យបានយ៉ាងហោចណាស់៤ថង់ក្នុង១ថ្ងៃ លើសពីនេះ ។

ហើយចំនុចផ្តើមគឺយើងនាំគ្នាកាត់បន្ថយការប្រើថង់ប្លាស្ទិក ដែលនេះជាអំពើល្អកើតចេញពីបេះដូងខ្មែរ ធ្វើហើយទទួលបានតែភាពស្អាត ភាពចម្រើនក្នុងសហគមន៍ ហើយយុតញធនាកាភាពស្មោះត្រង់ បានកំនត់ជាស្រេចនៅក្នុងសីល៥ ដែលពុទ្ធបរិស័ទគ្រប់រូបបានលឺ ដឹងនិងបានប្រតិបត្តិ មិនមែនទើបរបស់ពុទ្ធបរិស័ទ គឺជាគំរូភាពសម្រាប់យុវជនជំនាន់ក្រោយ ទុកសម្រាប់ជាដើមទុនសំខាន់នាំទៅកាន់ភាពជោគជ័យ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានមោទនភាពចំពោះការរីកចម្រើនវិស័យសាសនានៅកម្ពុជា ទាំងពុទ្ធចក្រក៏ដូចជាការគោរពជំនឿសាសនាផ្សេងទៀតរបស់ប្រជាជនកម្ពុជាដែលរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមរមនា។ ដោយមើលឃើញពីចំណងទាក់ទងគ្នាមិនអាចបេះដាច់ចេញពីគ្នារវាងពុទ្ធចក្រ និងអាណាចក្រ នេះឆ្លុះបញ្ចាំងឱ្យឃើញអំពីការរីកចម្រើន ក៏ដូចជាការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះព្រះពុទ្ធសាសនា និងភាពសុដុមរមនាជាមួយនឹងសាសនាដទៃទៀត ។ ចំណងទាក់ទងរវាងពុទ្ធចក្រ និងអាណាចក្រ ជាទំនាក់ទំនងយ៉ាងជ្រាលជ្រៅដែលមិនអាចកាត់បេះដាច់ចេញពីគ្នា

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមលើកឡើងនូវទឡ្ហីករណ៍ ៣ចំណុច ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីការរីកចម្រើន ក៏ដូចជាការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះព្រះពុទ្ធសាសនា និងភាពសុដុមរមនាជាមួយនឹងសាសនាដទៃទៀត

ទី១– យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា បានផ្តោតសំខាន់ទៅលើ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ហើយក្នុងមុំទី៥នៃបញ្ចកោណទី១ គឺការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ដែលផ្តោតសំខាន់លើការធ្វើភាវូបនីយកម្មពលរដ្ឋឱ្យមានសីលធម៌ គុណធម៌ និងសុជីវធម៌ ហើយថែមទាំងមានវិន័យ ព្រមទាំងការទទួលខុសត្រូវខ្ពស់ ប្រកបដោយមនសិការស្នេហាជាតិ និងភក្តីភាពចំពោះអត្តសញ្ញាណនៃភាពជាខ្មែរ។ កិច្ចការដ៏សំខាន់នេះអាចសម្រេចទៅបាន លុះត្រាតែមានការចូលរួមដ៏ចម្បងពីសំណាក់ការអប់រំទូន្មាន តាមបែបសាសនាជាពិសេស ការជំរុញការរស់នៅតាមពុទ្ធោវាទនៃព្រះពុទ្ធសាសនាដែលតែងប្រោសសត្វលោកឱ្យរស់នៅប្រកបដោយភាពថ្លៃថ្នូរនិងសុខដុមរមនារវាងគ្នាទៅវិញទៅមក។ នៅក្នុងបរិបទដែលសង្គមកម្ពុជាកាន់តែអភិវឌ្ឍ និងកាន់តែទំនើប ការលើកកម្ពស់វិធាននៃការរស់នៅស្របតាមដំបូន្មាននៃសាសនា គឺពិតជាសំខាន់។

ទី២– ការចូលរួមយ៉ាងកុះកររបស់ប្រជាជនកម្ពុជា ក្នុងការលើកស្ទួយព្រះពុទ្ធសាសនា និងសាសនាដទៃទៀត ជាតឹកតាងមិនអាចខ្វះបាននៃការបន្តគោរព និងជំនឿសាសនាយ៉ាងមោះមុតរបស់ប្រជាជនកម្ពុជា បើទោះជាសាសនាធ្លាប់ត្រូវបានលុបបំបាត់ ក្នុងរបបប្រល័យពូជសាសន៍ប៉ុលពតក៏ដោយ ។

ទី៣– ទោះបីជាព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ សិទ្ធិសេរីភាពនៃការគោរពជំនឿសាសនាត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ហើយប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិពេញលេញក្នុងការគោរពប្រតិបត្តិសាសនាផ្សេងៗ ដោយគ្មានការរើសអើងឡើយ ។

(ឆ្លើយតប...ក្រសួងបរិស្ថានបានធ្វើអ្វីខ្លះ ? )

មុននឹងបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ អរគុណជាថ្មីម្តងទៀត ថ្វាយ ប្រគេនជូនព្រះចៅអធិការ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវអស់លោក លោកស្រី សីលវន្ត សីលវតី លោកគ្រូ អ្នកគ្រូសិស្សានុសិស្ស ភ្ញៀវកិត្តិយស និងពុទ្ធបរិស័ទទាំងអស់ ចំពោះព្រះវត្តមាន និងវត្តមានដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធឆ្លង និង

កាត់ខ្សែបូដាក់ឱ្យប្រើប្រាស់នូវសមិទ្ធិនានានៅក្នុងវត្តដែលបង្ហាញឱ្យឃើញពីសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ក្រោមដំបូលនៃសុខសន្តិភាព និងការចូលរួមក្នុងការធ្វើស្រែបុណ្យ និងការបំពេញបុណ្យកុសលរួមគ្នា ប្រកបដោយសទ្ធាជ្រះថ្លា។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយប្រគេនពរ និងជូនពរ ចៅអធិការ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សីលវន្ត សីលវតី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ភ្ញៀវកិត្តិយស និងពុទ្ធបរិស័ទទាំងអស់ សូមប្រកបដោយពរ និងពុទ្ធពរទាំង ៥ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

## សុន្ទរកថា
## ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តត្បូងឃ្មុំ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីសម្ពោធឆ្លងព្រះសក្យមុនីចេតិយក្នុងពោធិសាល ហៅវត្តអំពិល ភូមិអំពិល ឃុំប៉ើស២ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
## ថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ | ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤

- សូមក្រាបថ្វាយបង្គំ ព្រះព្រហ្មចរិយញាណ យិត្ត សុខា ព្រះមេគណខេត្ត ត្បូងឃ្មុំ ជាទីគោរពសក្ការៈ!
- សូមក្រាបថ្វាយបង្គំ ព្រះមន្ត្រីសង្ឃ ព្រះចៅអធិការ និងព្រះថេរានុត្ថេរៈគ្រប់ ព្រះអង្គ ជាទីគោរពសក្ការៈ!
- សូមគោរព ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ជាទីគោរព!
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សីលវន្ត សីលវតី លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស យុវជនកាកបាទក្រហម យុវជនកាយរិទ្ធ សហភាពសហព័ន្ធយុវជនកម្ពុជា កងកម្លាំងទាំង៣ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ជាទីរាប់អាន និង ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានសេចក្តីសោមនស្សរីករាយប្រកបដោយសទ្ធាជ្រះថ្លា និងកិត្តិយសជាទីបំផុត ដែល បានធ្វើជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មកចូលរួមក្នុងពិធីសម្ពោធឆ្លង ព្រះសក្យមុនីចេតិយ និងសមិទ្ធផលនានា នៅវត្តពោធិសាល ហៅវត្តអំពិល ស្ថិតនៅភូមិអំពិល ឃុំប៉ើស២ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាខណៈនេះ ដែលនេះជាសក្ខីកម្មនៃការរីកចម្រើននៃព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ក្រោមម្លប់នៃសុខសន្តិភាព។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំព្រះករុណាខ្ញុំ សូមនាំយកនូវការផ្តាំផ្ញើសួរសុខទុក្ខអំពី **មហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះលោកតា លោកយាយ អ៊ំ ពូ មីង បងប្អូន សិស្សានុសិស្សទាំងអស់ ដែលមានវត្តមាននៅទីនេះ។ តាងនាម **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមថ្លែងអំណរព្រះគុណ និងអរគុណ ព្រមទាំងសូមកោតសរសើរយ៉ាងជ្រាលជ្រៅ ថ្វាយប្រគេនជូនចំពោះព្រះចៅអធិការវត្តពោធិសាល ហៅវត្តអំពិល លោកអាចារ្យ គណៈកម្មការ និងបងប្អូនពុទ្ធបរិស័ទជិតឆ្ងាយទាំងអស់ ដែលបានខិតខំ និងចូលរួមកសាងសមិទ្ធផលទាំងនេះឡើង និងសូមឱ្យកុសលដែលកើតពីសទ្ធានៃការចូលរួមរបស់សប្បុរសជនទាំងឡាយ នាំមកនូវសេចក្តីសុខ និងសេចក្តីចម្រើនគ្រប់កាល និងគ្រប់វេលា។ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមអរគុណអាជ្ញាធរមូលដ្ឋាន និងក្រុមការងារចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំសហការ និងជួយជ្រោមជ្រែងក្នុងការបង្កើតសមិទ្ធិនានាក្នុងវត្តអំពិល និងក្នុងមូលដ្ឋានភូមិ ឃុំ និងស្រុកក្រូចឆ្មារទាំងមូល។ ទាំងនេះជាកេរដំណែលសាសនាដ៏មានតម្លៃ ផ្សារភ្ជាប់នឹងព្រលឹងជាតិនៃបុព្វបុរសយើងតាំងពីបុរាណកាល

ក្រោមបាវចនា "ជាតិ សាសនា ព្រះមហាក្សត្រ" និងដើម្បីងាយស្រួលដល់ពុទ្ធបរិស័ទ ក្នុងការបំពេញកុសលផ្សេងៗ តាមទំនៀមទម្លាប់ប្រពៃណីសាសនាផងដែរ។

សមិទ្ធផលក្នុងពុទ្ធចក្រនាថ្ងៃនេះ ជាតឹកតាងឆ្លុះបញ្ចាំងពីសាមគ្គីភាព ប្រកបដោយជំនឿដ៏ជ្រះថ្លារបស់បងប្អូនប្រជាពលរដ្ឋ ពុទ្ធបរិស័ទគ្រប់រូប ដែលកើតចេញពីសទ្ធានៃចិត្តដ៏ស្អាតល្អ ពោរពេញដោយកុសលធម៌ក្នុងការប្រព្រឹត្តិបុណ្យសាងអំពើល្អ ដែលផុសចិត្តពីបេះដូងស្អាត និងចិត្តដ៏ល្អគ្មានហ្មងរបស់បងប្អូនប្រជាពលរដ្ឋ និងពុទ្ធបរិស័ទគ្រប់រូប។ បេះ-ដូងដ៏ស្អាតល្អនេះ នឹងនាំមកនូវចក្តីសុខចម្រើនដល់បុគ្គលអ្នកបដិបត្តិផង និងសាយភាពដល់សង្គមជាតិទាំងមូលផងយ៉ាងប្រាកដ។

ព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកយាយ លោកតា អ៊ំ ពូ មីង បងប្អូនកូនក្មួយជាទីរាប់អាន

នៅក្នុងនីតិកាលទី៧នៃរដ្ឋសភាជាតិកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ ពោរពេញដោយថាមពល ចំណេះដឹង និង សមត្ថភាពប៉ិនប្រសព្វបំផុត សម្តេច មហាបវរធិបតី ហ៊ុន ម៉ាណែត ដែលជានាយករដ្ឋមន្ត្រី និងជាអគ្គមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម បាននិងកំពុងបន្តការងារពីរាជរដ្ឋាភិបាលអាណត្តិទី៦ ដែលដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកំពុងបន្តសកម្មភាពយ៉ាងមោះមុត ខ្លាំងក្លាក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យប្រកបដោយមោទនភាព និងកិត្យានុភាពបំផុត ក្នុងគោលបំណងតម្កល់ខ្ពស់នូវឧត្តមគតិស្នេហាជាតិដ៏ថ្លៃថ្លាបំពេញបេសកកម្មជាប្រវត្តិសាស្ត្រក្នុងការបម្រើជាតិមាតុភូមិ ហើយប្រែក្លាយកម្ពុជាឱ្យទៅជាទឹកដីដ៏ពិសិដ្ឋ ប្រកបដោយសុខដុមរមនា ជីវភាពប្រជាជនកាន់តែប្រសើរឡើង ឆ្ពោះទៅកាន់ចក្ខុវិស័យ ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជា ប្រទេសមានចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ទន្ទឹមគ្នានេះក្រសួងបរិស្ថានឈរលើគោលការណ៍ធម៌នៃពុទ្ធឱវាទ ក៏ដូចជាអនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា



ក្នុងមុំទី៥នៃបញ្ចកោណទី១ គឺការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ដែលផ្តោតសំខាន់លើការធ្វើពលរូបនីយកម្មពលរដ្ឋ ឱ្យមានសីលធម៌ គុណធម៌ និងសុជីវធម៌ បានដាក់ចេញនូវយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ ២០២៣-២០២៨ ដែលផ្តោតលើ ភាពស្អាត ភាពបៃតង និងចីរភាព។ ភាពស្អាត ក្នុងន័យនេះ ព្រះករុណាខ្ញុំបាទ សូមគូសបញ្ជាក់ថាបេះដូងប្រជាពលរដ្ឋកម្ពុជាយើងជាពិសេសសិស្សានុសិស្សគឺមានចិត្តស្អាតបរិសុទ្ធណាស់ ជាក់ស្តែងពួកគាត់បានចូលរួមក្នុងយុទ្ធនាការកាត់បន្ថយប្លាស្ទិក និងបានប្តេជ្ញាចិត្តថា មិនប្រើប្រាស់ថង់ប្លាស្ទិកទៀតទេ ហើយហេតុអ្វីបានជាប្រជាពលរដ្ឋ និងសិស្សានុសិស្សជិត៥លាននាក់ មានការប្តេជ្ញាចិត្តបែបនេះ? ក៏ព្រោះពួកគាត់ចង់បន្សល់ទុកនូវភាពស្អាតដោយមិនមានការបំពុលពីប្លាស្ទិកមកលើសុខភាពអ្នកជំនាន់ក្រោយ ឬកូនចៅរបស់ពួកគាត់ ហើយការចូលរួមនេះទៀតសោតគឺកើតចេញពីចិត្តស្អាតប្រកបដោយធម៌តែម្តង ដោយមិនមានការរំពឹងជាប្រាក់កាក់ត្រឡប់ទៅវិញឡើយ។ ន័យនេះ នៅក្នុងពុទ្ធឱវាទ គឺជាការធ្វើបុណ្យមិនរំពឹងផល តែផលបានកើតឡើងរួចទៅហើយក្នុងសមានចិត្តកុសល្យ នៃអ្នកធ្វើអំពើនោះជារួមមកវិញ ភាពស្អាតដែលកើតចេញពីចិត្តនេះហើយដែលជាភាពល្អបរិសុទ្ធមិនអាចកាត់ថ្លៃបាន ហើយនៅពេលដែលចិត្តស្អាតនេះបានពូនផ្តុំនិងប្រមូលគរគ្នាច្រើនឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ កម្ពុជានឹងមានផ្ទៃដីដ៏ស្រស់ស្អាត មានផ្ទៃទឹកដ៏ថ្លាល្អ មានផ្ទៃមេឃខៀវខ្ចី ដែលជាកិត្យានុភាពដ៏អស្ចារ្យរបស់យើងជំនាន់នេះបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយដូចជាដូនតាដែលបានបន្សល់ទុកអង្គរវត្តដែលជាមរតកវប្បធម៌ល្អប្រពៃនៃយើង។

ផ្នត់គំនិតនៃភាពស្អាត បានកំពុងចាក់ស្រេះពេញបេះដូងប្រជាពលរដ្ឋកម្ពុជា ជាពិសេសសិស្សានុសិស្ស តាមរយៈការបញ្ចេញសកម្មភាពសម្អាតនៅតាមបរិវេណសាលារៀន វត្តអារាម ផ្ទះសម្បែង និងសហគមន៍ ហើយនៅជំហានបន្ទាប់ក្រសួងបរិស្ថាននឹងរៀបចំដាក់ធុងសំរាមជូនតាមសាលារៀន វត្តអារាម និងតាមទីសាធារណៈ ដើម្បីឱ្យសិស្សានុសិស្ស និងប្រជាពលរដ្ឋទុកដាក់សំរាមរបស់យើងឱ្យបានត្រឹមត្រូវ។

លើសពីការសម្អាតនេះ សិស្សានុសិស្ស យុវជន និងប្រជាពលរដ្ឋយើង នឹងបានរួមចំណែកក្នុងការដាំដើមឈើ ដែលសកម្មភាពនេះ បានធ្វើឱ្យកម្ពុជាមានភាពបៃតង ហើយភាពបៃតងនេះ នឹងនាំមកនូវប្រាក់ចំណូលជាច្រើនទៅឱ្យប្រជាសហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋកម្ពុជា តាមរយៈការវិនិយោគកាបូន ដែលជាគោលដៅយុទ្ធសាស្ត្ររបស់កម្ពុជាឈានឆ្ពោះទៅជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។

ការរួមចំណែកផ្សព្វផ្សាយតាមបណ្តាញសង្គមរបស់យុវជនកម្ពុជា អំពីការចូលរួមសម្អាតតាមរយៈរូបភាពវិជ្ជមាននៃភាពស្អាតដែលចេញពីកម្លាំងសាមគ្គីទៅកាន់ពិភពលោកថា កម្ពុជាស្អាត ហើយកម្ពុជាបានខំប្រឹងសម្អាតប្រទេសរបស់ខ្លួនយ៉ាងសស្រាក់សស្រាំ ហើយយើងនឹងមិនអនុញ្ញាតឱ្យជនណាម្នាក់យករូបភាពរបស់កម្ពុជាទៅធ្វើអាជីវកម្ម ឬមូលបង្កាច់កម្ពុជាទៀតឡើយ។

ជ្រកក្រោមម្លប់នៃសុខសន្តិភាព និងក្រោមមគ្គុទ្ទេសក៍ដ៏ឆ្លាតឈ្លាសវៃរបស់រាជរដ្ឋាភិបាលកម្ពុជា ជាតិជាកូនខ្មែរអ្នកសាងអង្គរ មានឈាមជ័រជាអ្នកមានសីល និងគុណធម៌ដ៏ជ្រាលជ្រៅ ជាពិសេសដែលមានពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ដែលតែងតែប្រៀនប្រដៅ អប់រំបរិស័ទ ខ្ញុំមានសុទិដ្ឋិនិយម និងជឿជាក់យ៉ាងមុតមាំថា ខ្មែរអាចធ្វើបាន និងអាចរួមគ្នាកសាងសង្គមដែលស្អាតបាន ដើម្បីកសាងភាពស្អាតមួយទុកឱ្យកូនចៅជំនាន់ក្រោយយើងបន្តរាប់ជំនាន់ទៅមុខទៀត

ព្រះតេជគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ និងអង្គពិធីទាំងមូលជាទីរាប់អាន

ពិតណាស់ថាចំណងទាក់ទងរវាងពុទ្ធចក្រ និងអាណាចក្រជាទំនាក់ទំនងយ៉ាងជ្រាលជ្រៅ ដែលមិនអាចកាត់បេះដាច់ចេញពីគ្នា។ កិច្ចការដ៏សំខាន់នេះ អាចសម្រេចទៅបាន លុះត្រាតែមានការចូលរួមដ៏ចម្បងពីសំណាក់ការអប់រំទូន្មាន តាមបែបសាសនា ជាពិសេស ការជំរុញការរស់នៅតាមពុទ្ធឱវាទនៃព្រះពុទ្ធសាសនា ដែលតែងប្រោសសត្វលោកឱ្យរស់នៅប្រកបដោយភាពថ្លៃថ្នូរ និងសុខដុមរមនារវាងគ្នាទៅវិញទៅមក។ នៅក្នុងបរិបទដែលសង្គមកម្ពុជាកាន់តែ អភិវឌ្ឍន៍ និងកាន់តែទំនើប ការលើកកម្ពស់វិធាននៃការរស់នៅស្របតាមជំបូន្មាននៃសាសនា គឺពិតជាសំខាន់។

ក្នុងសម័យរបបប្រល័យពូជសាសន៍ ប៉ុល ពត ១៩៧៥-១៩៧៩ ប្រជាពលរដ្ឋ ដែលប្រតិបត្តិគ្រប់សាសនាត្រូវបានប៉ះពាល់ដោយសាររបបនេះ។ គ្រប់ការប្រតិបត្តិសាសនាទាំងអស់ត្រូវបានបិទ ហើយសមិទ្ធផលសាសនាជាច្រើនត្រូវបានបំផ្លាញ។ ក្រោយការដួលរលំនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត នយោបាយឈ្នះ-ឈ្នះរបស់ សម្តេចតេជោ បានបញ្ចប់សង្គ្រាមទូទាំងផ្ទៃប្រទេស ធ្វើឱ្យប្រជាពលរដ្ឋខ្មែរគ្រប់សាសនាទាំងអស់បានរួចផុតពីការស្លាប់។ ការបញ្ចប់សង្គ្រាមនេះ បានស្រោចស្រង់ និងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋមានសិទ្ធិសេរីភាពជ្រើសរើសសាសនា ហើយទោះបីថាសាសនាព្រះពុទ្ធត្រូវបានកំណត់ថាជាសាសនារបស់រដ្ឋក៏ដោយ រដ្ឋាភិបាលកម្ពុជាបានជំរុញ និងលើកកម្ពស់គ្រប់សាសនាទាំងអស់ ឱ្យចូលរួមចំណែកក្នុងការអប់រំបរិស័ទឱ្យដើរលើមាគ៌ាល្អត្រឹមត្រូវ។ នេះជាអ្វីដែលបានចូលរួម ក្នុងការថែរក្សានូវភាពសុខសាន្តក្នុងជំនឿសាសនាចំពោះអ្នកកាន់ សាសនាផ្សេងគ្នា ឱ្យចៀសផុតពីការបំផ្លាញ។ រាជរដ្ឋាភិបាលអាណត្តិទី៧ នឹងបន្តនូវប្រពៃណី និងគោលនយោបាយដែលរាជរដ្ឋាភិបាលនៅក្នុង ៤០ឆ្នាំជាងនេះ គោរពប្រតិបត្តិ និងបន្តជំរុញបើកសិទ្ធិសេរីភាព និងធានាសិទ្ធិសេរីភាពដល់គ្រប់សាសនាទាំងអស់ ដើម្បីថែរក្សាការពារសុខដុមរមនីយកម្មសាសនានេះឱ្យល្អស្ថិតស្ថេរជានិច្ចនិរន្តរ៍។

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានមោទនភាពចំពោះការរីកចម្រើនវិស័យសាសនានៅកម្ពុជា ទាំងពុទ្ធចក្រក៏ដូចជាការគោរពជំនឿសាសនាផ្សេងទៀតរបស់ប្រជាជនកម្ពុជា ដែលរស់នៅជាមួយគ្នា ប្រកបដោយភាពសុខដុមរមនា។ នេះឆ្លុះបញ្ចាំងឱ្យឃើញអំពីការរីកចម្រើន ក៏ដូចជាការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះព្រះពុទ្ធសាសនា និងភាពចុះសម្រុងគ្នារវាងសាសនាទាំងអស់ក្នុងគោលដៅដឹកនាំមនុស្សឱ្យល្អ មានសន្តិភាពក្នុងចិត្ត និងក្នុងសង្គមជាតិ។ ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណជាថ្មីម្តងទៀត ថ្វាយប្រគេនព្រះចៅអធិការ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សីលវន្ត សីលវតី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស

ភ្ញៀវកិត្តិយស និងពុទ្ធបរិស័ទទាំងអស់ ចំពោះព្រះវត្តមាន និងវត្តមាន ក្នុងពិធីសម្ពោធឆ្លង និងកាត់ខ្សែបូដាក់ឱ្យប្រើប្រាស់នូវសមិទ្ធិនានា នៅក្នុងវត្ត ដែលបង្ហាញឱ្យឃើញពីសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ក្រោមដំបូលនៃសុខសន្តិភាព និងការចូលរួមក្នុងការធ្វើស្រែបុណ្យ ព្រមទាំងការបំពេញបុណ្យកុសលរួមគ្នាប្រកប ដោយសទ្ធាជ្រះថ្លា។ សូមព្រះតេជគុណ ឯកឧត្តម លោក-ជំទាវ អស់លោក លោកយាយ លោកតា អ៊ុំ ពូ មីង បងប្អូនកូនក្មួយ សូមប្រកបដោយពុទ្ធពរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ៕

សូមអរព្រះគុណ និងសូមអរគុណ!

## ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តត្បូងឃ្មុំ
## ថ្លែងក្នុងពិធីសម្ពោធឆ្លងឧបដ្ឋានសាលា និងសមិទ្ធិផលនានា ក្នុងវត្តធម្មរង្សីទួលអូដ្ឋ ហៅវត្តអូដ្ឋ
## ភូមិមិត្តារ៉ាច ឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ
## ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤

- សូមក្រាបថ្វាយបង្គំព្រះគ្រូមុនីសោភណ ឈិន ប៊ិច ព្រះរាជាគណៈថ្នាក់កិត្តយស និងជាអនុគណស្រុកអូររាំងឪ ព្រះគ្រូព្រះវិន័យធរស្រុក ព្រះគ្រូព្រះធម្មធរស្រុក ព្រះគ្រូចៅអធិការ ជាទីគោរពសក្ការៈ
- សូមក្រាបថ្វាយបង្គំព្រះគ្រូ សៅ ហ៊ិន ព្រះវិន័យធម៌គណស្រុកអូរាំងឪ ជាទីគោរពសក្ការៈ
- សូមក្រាបថ្វាយបង្គំព្រះគ្រូ ឡាវ ប៊ុនធឿន ព្រះចៅអធិការវត្តធម្មរង្សី( ទួលអូដ្ឋ ) ជាទីគោរពសក្ការៈ
- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ
- ឯកឧត្តម លោកជំទាវ អនុប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តត្បូងឃ្មុំ
- ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី  សមាជិក សមាជិកា  ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តត្បូងឃ្មុំ
- គណៈធិបតី ភ្ញៀវកិត្តិយស សីលវន្ត សីលវតី
- លោកយាយ លោកតា លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស បងប្អូន ពុទ្ធបរិស័ទទាំងអស់ជាទីគោរពស្រលាញ់រាប់អាន!

ថ្ងៃនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានសេចក្តីសោមនស្សរីករាយប្រកបដោយសទ្ធាជ្រះថ្លា និងកិត្តិយសជាទីបំផុត ដែលបានមកចូលរួមក្នុងពិធីសម្ពោធឆ្លង និងកាត់ខ្សែបូដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលនានាដូចដែលលោកអភិបាលស្រុក ងួន ប៊ុណ្ណាន បានធ្វើរបាយការណ៍ស្វាគមន៍មុននេះ។ ការរីកចម្រើននៃព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋក្រោមម្លប់នៃសុខសន្តិភាព គឺជាសក្ខីកម្មដ៏អស្ចារ្យ និងជាមោទនភាពរបស់ប្រជាពលរដ្ឋរស់នៅក្នុងខេត្តត្បូងឃ្មុំទាំងមូល។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណ ព្រមទាំងសូមកោតសរសើរយ៉ាងជ្រាលជ្រៅ ថ្វាយប្រគេនចៅអធិការវត្តធម្មរង្សីហៅវត្តទួលអូដ្ឋ លោកអាចារ្យ គណៈកម្មការ និងបងប្អូនពុទ្ធបរិស័ទជិតឆ្ងាយទាំងអស់ ដែលបានខិតខំ និងចូលរួមកសាងសមិទ្ធិផលទាំងនេះឡើង និងសូមឱ្យកុសលដែលកើតពីសទ្ធានៃការចូលរួមរបស់សប្បុរសជនទាំងឡាយបាននាំមក នូវសេចក្តីសុខ និងសេចក្តីចម្រើនគ្រប់កាល និងគ្រប់វេលា ។ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមអរគុណអាជ្ញាធរមូលដ្ឋាន និងក្រុមការងារចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំ សហការ និងជួយជ្រោមជ្រែង ក្នុងការបង្កើតសមិទ្ធិផលនានា ក្នុងវត្តធម្មរង្សី ហៅវត្តទួលអូដ្ឋ និងក្នុងមូលដ្ឋានឃុំអំពិលតាពកទាំងមូល ។ ទាំងនេះ គឺជាកេរ្តិ៍ដំណែលសាសនាដ៏មានតម្លៃ ផ្សារភ្ជាប់នឹងព្រលឹងជាតិនៃបុព្វបុរសយើងតាំងពីបុរាណកាល ក្រោមបាវចនា "ជាតិ សាសនា ព្រះមហាក្សត្រ" និងដើម្បីងាយស្រួលដល់ពុទ្ធបរិស័ទ ក្នុងការបំពេញកុសលផ្សេងៗ តាមទំនៀមទម្លាប់

ប្រពៃណីសាសនាផងដែរ ។ ពីពិធីសម្ពោធឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលនានាក្នុងវត្តធម្មវង្សីទួលអូដ្ឋ ហៅវត្តអូដ្ឋ ដែលស្ថិតនៅក្នុងភូមិ មិត្តារ៉ាច ឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំនេះ ជាសមិទ្ធផលចម្បងទី៥ហើយ ដែលក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តត្បូងឃ្មុំ គណបក្សប្រជាជនកម្ពុជាសម្រេចបាន ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧នៃរដ្ឋសភាជាតិនឹងបានកំពុងបន្ត និងពង្រឹងពីរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៦យ៉ាងសកម្ម និងពោរពេញដោយថាមពលក្រោមការដឹកនាំដ៏ឆ្នើមពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលលោកបានយកចិត្តទុកដាក់ជាសំខាន់ចំពោះសុខទុក្ខប្រជាជនកម្ពុជាគ្រប់រូប ក្នុងនោះសម្តេចបានដាក់ចេញនូវអាទិភាពគន្លឹះចំនួន ៥ ទី១មនុស្ស ទី២ផ្លូវ ទី៣ទឹក ទី៤ភ្លើង និងទី៥បច្ចេកវិទ្យា ។

ជាមួយនឹងអាទិភាពគន្លឹះនេះ ក្រុមការងាររាជរដ្ឋាភិបាល ក្រុមការងារចុះមូលដ្ឋានឃុំ និងគណបក្សប្រជាជនកម្ពុជា សម្រេចបាននូវសមិទ្ធផលស្របតាមអាទិភាពគន្លឹះជាច្រើន តាមរយៈយុទ្ធនាការ ផ្លូវលោង បានសម្រួលដល់ការធ្វើដំណើរ របស់ប្រជាពលរដ្ឋក្នុងឃុំ និងអ្នកដំណើរនានាដោយបានឈូសឆាយកិនពង្រាបផ្លូវ បានសម្រេច ១00% លើផ្លូវក្នុងឃុំទាំងមូលចំនួន ៦ខ្សែ មានប្រវែងសរុប ១៣,៧៥០ ម៉ែត្រ ការកសាង ផ្លូវបេតុង អូររាំងឪដំណាក់ព្រីង ប្រវែង ១១,៧៥០ម៉ែត្រ ផ្លូវបេតុង ភូមិព្រៃស្រឡៅ តភ្ជាប់ ទៅភូមិមាសស្នេហ៍ ប្រវែង ៣,៧៥០ម៉ែត្រ និងផ្លូវបេតុង ភូមិទួលតាលាប់ ប្រវែង៧៥០ម៉ែត្រ ដាក់លូ ជីកប្រឡាយ នៅភូមិស្វាយតាធម្ម ប្រវែង ១,៥០០ ម៉ែត្រ រៀបឥដ្ឋ ដាក់លូថ្មី ជូនសាលាបឋមសិក្សាអំពិលតាពក ១២ កង់ កាយប្រឡាយទឹកដាក់លូ នៅភូមិទំពាំងបង្កង់ ១២កង់ និងការដំឡើងអំពូលសូឡា តាមដងផ្លូវ និងទីប្រជុំជននានាក្នុងឃុំ ចំនួន១១៤ឈុត និងអំពូលហ្វា ចំនួន១៦ឈុត ។ល។ សមិទ្ធផលទាំងអស់នេះ បានជួយសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ឱ្យបានល្អប្រសើរជាងមុនផងដែរ។ លើសពីសមិទ្ធផលដែលសម្រេចបាន យើងក៏ឃើញពីភាពសុខដុមរមនារបស់ប្រជាជនក្រោមដំបូលសន្តិភាព ដែលបានឆ្លុះបញ្ចាំងពីសាមគ្គីភាពប្រកបដោយជំនឿទុកចិត្តឥតងាករេពីគណបក្សប្រជាជនកម្ពុជា និងបានរួមគ្នាជ្រោង និងបន្តការពារសុខសន្តិភាពជាង៤០ឆ្នាំមកនេះឱ្យនៅគង់វង្ស។ សទ្ធាជ្រះថ្លារបស់បងប្អូនប្រជាពលរដ្ឋ ពុទ្ធបរិស័ទគ្រប់រូបនៅថ្ងៃនេះ គឺបានមកពីចិត្តស្អាត គ្មានហ្មងសៅ គ្មានមន្ទិលក្នុងការប្រព្រឹត្តនូវអំពើល្អ ដែលអំពើល្អនៃចិត្តស្អាតជាដើមទុនដ៏សំខាន់ក្នុងការប្រកបរបររកទទួលទានប្រចាំថ្ងៃ ពីព្រោះថា មិនថាយើងប្រកបរបរអ្វីឡើយ ភាពស្មោះត្រង់នៃចិត្តនៅតែសំខាន់ ។ ចិត្តស្អាតនេះទៀតសោត បាននាំយើងទៅកាន់ភាពស្អាតនៅជុំវិញខ្លួន គឺស្អាតនៅលើគោក ក្នុងទឹក និងអាកាស ជាមួយគ្នានេះ ក្រសួងបរិស្ថាន បានដាក់ចេញនូវយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ដែលផ្តោតលើភាពស្អាត ភាពបៃតង និងចីរភាព។ ដាក់ស្តែងនៅក្នុងភាពស្អាតនេះ ក្រសួងបរិស្ថាន បានដាក់ចេញនូវយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ "ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ" ដែលជាទង្វើដ៏ល្អ ចំពោះភពផែនដីរបស់យើងបាន និងកំពុងទទួលការគាំទ្រយ៉ាងផុលផុសពីសំណាក់បងប្អូនប្រជាពលរដ្ឋនៅតាមរោងចក្រ សាលារៀន វត្តអារាម ដៃគូអភិវឌ្ឍន៍ ស្ថាប័នជាតិ និងឯកជនមួយចំនួន ជាពិសេស ក្មួយៗសិស្សានុសិស្ស ដែលបានប្តេជ្ញារួមគ្នាជាធ្លុងមួយ ដើម្បីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច ដាក់ស្តែងចាប់តាំងពីថ្ងៃចាប់ផ្តើមយុទ្ធនាការ រហូតដល់ថ្ងៃនេះ មានការចូលរួមយ៉ាងផុលផុសពីសំណាក់បងប្អូនប្រជាពលរដ្ឋ នៅតាមរោងចក្រ សិស្សា នុសិស្ស នៅតាមសាលារៀន និងព្រះសង្ឃនៅវត្តអារាមក្នុងស្រុកអូររាំងឪទាំងមូល ក៏ដូចជាក្នុងឃុំអំពិលតាពកផ្ទាល់ មានការចូលរួមពីសាលារៀន និងវត្តទាំងអស់ក្នុងឃុំរហូតជិត ១៥ ០០០ នាក់ផងដែរ។ ការចូលរួមដ៏កុះករនេះ សបញ្ជាក់យ៉ាងច្បាស់ឱ្យឃើញពីសេចក្តីស្រលាញ់លើភាពស្អាត អំពើល្អ ដែលកើតចេញពីបេះដូងខ្មែរពិតៗ។ ជាមួយគ្នានេះ ជ្រកក្រោមម្លប់នៃសុខសន្តិភាព និងក្រោមមគ្គុទ្ទេសក៍ ដ៏ឆ្លាតឈ្លាសវៃ របស់រាជរដ្ឋាភិបាលកម្ពុជា ជាតិជាកូនខ្មែរ អ្នកសាងអង្គរ មានឈាមជ័រ ជាអ្នកមានសីល និងគុណធម៌ ដ៏ជ្រាលជ្រៅជាពិសេសដែលមានពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ដែលតែងតែប្រៀនប្រដៅ អប់រំបរិស័ទ ខ្ញុំមានសុទិដ្ឋិនិយម និងជឿជាក់យ៉ាងមុតមាំថា ខ្មែរអាចធ្វើបាន និងអាចរួមគ្នាកសាងសង្គមដែលស្អាតបាន ដើម្បីកសាងភាពស្អាតមួយ ទុកឱ្យកូនចៅជំនាន់ក្រោយយើងបន្តរាប់ជំនាន់ទៅមុខទៀត លើសពីនេះ

ទៀតការបណ្តុះគំនិតស្រលាញ់ភាពស្អាតដល់សិស្សានុសិស្ស ដែលជាទំពាំងស្នងឫស្សីនេះ នឹងជំរុញពួកគាត់ឱ្យក្លាយជាធនធាន ដ៏មានសារៈសំខាន់ចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ និងយុទ្ធនាការផ្សេងៗទៀតដើម្បីឈានទៅសម្រេចបាននូវភាពស្អាត ភាពបៃតង និងចីរភាពសម្រាប់កម្ពុជាផងដែរ ជាក់ស្តែង ដូចជាការចូលរួមដាំកូនឈើកន្លងមកក្នុងយុំ ក្នុងយុទ្ធនាការដាំដើមឈើ ១លានដើមក្នុង១ឆ្នាំ របស់ក្រសួងបរិស្ថាន ដើម្បីបង្កើនគម្របព្រៃឈើឱ្យបាន ៦០% នៃផ្ទៃប្រទេសទាំងមូលផងដែរ។

ព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកយាយ លោកតា អ៊ំ ពូ មីង បងប្អូនកូនក្មួយជាទីរាប់អាន

ពិតណាស់ថាចំណងទាក់ទងរវាងពុទ្ធចក្រ និងអាណាចក្រជាទំនាក់ទំនង យ៉ាងជ្រាលជ្រៅ ដែលមិនអាចកាត់បេះដាច់ចេញពីគ្នា។ កិច្ចការដ៏សំខាន់នេះ អាចសម្រេចទៅបានលុះត្រាតែមានការចូលរួមដ៏ចម្បង ពីសំណាក់ការអប់រំទូន្មានតាមបែបសាសនា ជាពិសេសការជំរុញការរស់នៅតាមពុទ្ធឱវាទនៃព្រះពុទ្ធសាសនា ដែលតែងប្រោសសត្វលោកឱ្យរស់នៅប្រកបដោយភាពថ្លៃថ្នូរ និងសុខដុមរមនារវាងគ្នាទៅវិញទៅមកនៅក្នុងបរិបទដែលសង្គមកម្ពុជាកាន់តែអភិវឌ្ឍន៍ និងកាន់តែទំនើប ការលើកកម្ពស់វិធាននៃការរស់នៅស្របតាមដំបូន្មាន នៃសាសនា គឺពិតជាសំខាន់។

ក្នុងសម័យរបបប្រល័យពូជសាសន៍ប៉ុលពត ១៩៧៥-១៩៧៩ ប្រជាពលរដ្ឋ ដែលប្រតិបត្តិគ្រប់សាសនាត្រូវបានប៉ះពាល់ដោយសាររបបនេះ។ គ្រប់ការប្រតិបត្តិសាសនាទាំងអស់ត្រូវបានបិទ ហើយសមិទ្ធផលសាសនាជាច្រើនត្រូវបានបំផ្លាញ។ ក្រោយការដួលរលំ នៃរបបប្រល័យពូជសាសន៍ប៉ុល ពត នយោបាយ ឈ្នះ-ឈ្នះ របស់ សម្តេចតេជោ បានបញ្ចប់ សង្គ្រាមទូទាំងផ្ទៃប្រទេស ធ្វើឱ្យប្រជាពលរដ្ឋខ្មែរគ្រប់សាសនាទាំងអស់បានរួចផុតពីការស្លាប់។ ការបញ្ចប់សង្គ្រាមនេះបានស្រោចស្រង់ និងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋមានសិទ្ធិសេរីភាពជ្រើសរើសសាសនា ហើយទោះបីថាសាសនាព្រះពុទ្ធ ត្រូវបានកំណត់ថាជាសាសនារបស់រដ្ឋក៏ដោយ រដ្ឋាភិបាលកម្ពុជាបានជំរុញ និងលើកកម្ពស់គ្រប់សាសនាទាំងអស់ឱ្យចូលរួមចំណែក ក្នុងការអប់រំបរិស័ទ ឱ្យដើរលើមាគ៌ាល្អត្រឹមត្រូវ នេះជាអ្វីដែលបានចូលរួមក្នុងការថែរក្សា នូវភាពសុខសាន្ត ក្នុងជំនឿសាសនាចំពោះអ្នក កាន់សាសនាផ្សេងគ្នាឱ្យជៀសផុតពីការបំផ្លាញ ។ រាជរដ្ឋាភិបាលអាណត្តិទី៧ នឹងបន្តនូវ ប្រពៃណី និងគោលនយោបាយដែលរាជរដ្ឋាភិបាលនៅក្នុង ៤០ឆ្នាំ ជាងនេះ គោរពប្រតិបត្តិ និងបន្តជំរុញ បើកសិទ្ធិសេរីភាព និងធានាសិទ្ធិសេរីភាព ដល់គ្រប់សាសនាទាំងអស់ ដើម្បីថែរក្សាការពារ សុខដុមរមនីយកម្មសាសនានេះ ឱ្យល្អស្ថិតស្ថេរជានិច្ចនិរន្តរ៍ ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានមោទនភាពចំពោះការរីកចម្រើនវិស័យសាសនានៅកម្ពុជា ទាំងពុទ្ធចក្រក៏ដូចជាការគោរពជំនឿ សាសនាផ្សេងទៀត របស់ប្រជាជនកម្ពុជា ដែលរស់នៅជាមួយគ្នា ប្រកបដោយភាពសុខដុមរមនា ។ នេះឆ្លុះបញ្ចាំងឱ្យឃើញ អំពីការរីកចម្រើន ក៏ដូចជា ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះព្រះពុទ្ធសាសនា និងភាពចុះសម្រុងគ្នា រវាងសាសនាទាំងអស់ ក្នុងគោលដៅដឹកនាំមនុស្សឱ្យល្អ មានសន្តិភាពក្នុងចិត្ត និងក្នុងសង្គមជាតិ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណជាថ្មីម្តងទៀត ថ្វាយប្រគេនព្រះចៅអធិការ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សីលវន្ត សីលវតី លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស ភ្ញៀវកិត្តិយស និងពុទ្ធបរិស័ទទាំងអស់ចំពោះព្រះវត្តមាន និងវត្តមាន ក្នុងពិធីសម្ពោធឆ្លង និងកាត់ខ្សែបូដាក់ឱ្យប្រើប្រាស់នូវសមិទ្ធិផលនានា នៅក្នុងវត្តទួលអូដ្ឋ ដែលបង្ហាញឱ្យឃើញពីសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ក្រោមដំបូលនៃសុខសន្តិភាព និងការចូលរួមក្នុងការធ្វើស្រែបុណ្យ ព្រមទាំងការបំពេញបុណ្យកុសលរួមគ្នា ប្រកបដោយសទ្ធាជ្រះថ្លា។ សូមព្រះតេជគុណ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី លោកយាយ លោកតា អ៊ំ ពូ មីង បងប្អូន កូនក្មួយ សូមប្រកបដោយពុទ្ធពរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ៕

សូមអរព្រះគុណ និងសូមអរគុណ!

## សុន្ទរកថា

## ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋាន ខេត្តត្បូងឃ្មុំ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងពិធីបុណ្យពុទ្ធាភិសេក និងសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តសន្តិវង្សារាម ហៅវត្តផ្សារថ្មី ភូមិ០៤+០៥ ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ | ម៉ោង ៧:៣០ នាទីព្រឹក

- ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ព្រះសទ្ធាភិញាណ វ៉ាន់ ដាវី ព្រះរាជាគណៈកិត្តិយស និងជាព្រះមធុរធម្មវង្សីព្រះអនុគណស្រុក ជាទី គោរពសក្ការៈ!
- សូមក្រាបថ្វាយបង្គំ ព្រះមន្ត្រីសង្ឃ ព្រះចៅអធិការ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!
- សូមគោរព ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ជាទីគោរព!
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សីលវន្ត សីលវតី លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស យុវជន



កាកបាទក្រហម យុវជនកាយរិទ្ធ យុវជនសហភាពសហព័ន្ធយុវជនកម្ពុជា(ស.ស.យ.ក.) កងកម្លាំងទាំង៣ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ជាទីរាប់ អាន និងជាទីមេត្រី!

1. ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ មានកិត្តិយស និងសេចក្តីសោមនស្សក្រៃលែងដែលបានចូលរួមជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យពុទ្ធាភិសេក និងសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តសន្តិវង្សារាម ហៅវត្តផ្សារថ្មី ស្ថិតនៅ ភូមិ០៤+០៥ ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំនៅថ្ងៃនេះ ជាមួយនឹងសក្ខីកម្មនៃការរីកចម្រើនរបស់ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ក្រោមម្លប់សុខសន្តិភាព។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងសេចក្តីនឹករលឹកពីសំណាក់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជូនអង្គពិធីទាំងមូល។

2. តាងនាម **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមថ្លែងអំណរព្រះគុណ និងអរគុណ ព្រមទាំងសូមកោតសរសើរយ៉ាងជ្រាលជ្រៅ ថ្វាយប្រគេនចៅព្រះចៅអធិការវត្តសន្តិវង្សារាម ហៅវត្តផ្សារថ្មី លោកអាចារ្យ គណៈកម្មការ បងប្អូនពុទ្ធបរិស័ទជិតឆ្ងាយទាំងអស់ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលបានរួមចំណែកកសាងនូវសេនាសនៈ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាច្រើនទៀតបម្រើឱ្យវិស័យពុទ្ធចក្រនិងអាណាចក្រ។

3. ពីធីបុណ្យពុទ្ធាភិសេក និងសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តសន្តិវង្សារាមនេះ គឺជាសមិទ្ធផលដែលបានប្រសូត្រចេញពីសទ្ធាជ្រះថ្លា កម្លាំងសាមគ្គីភាព ក្រោមការដឹកនាំរបស់ព្រះចៅអធិការវត្ត រួមនឹងសប្បុរសជន ដែលជាពុទ្ធ-សាសនិក ព្រមទាំងពុទ្ធបរិស័ទចំណុះជើងវត្តជិតឆ្ងាយទាំងអស់បានបន្សល់ទុកនូវកេរដំណែលសម្រាប់សង្គមជាតិ។

ព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង ក្មួយៗទាំងអស់ ជាទីគោរពស្រឡាញ់!

4. យោងតាមរបាយការណ៍សង្ខេបរបស់ឯកឧត្តម

បណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ មុននេះបានបង្ហាញថា ការយកចិត្តទុកដាក់ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការ វិស-ហមជ្ឈការ និងកម្មវិធីកំណែទម្រង់ស៊ីជម្រៅដទៃទៀត គឺសំដៅដល់ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈ សំណើ និងសំណូមពររបស់ប្រជាពលរដ្ឋ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ពួកគាត់ឱ្យមានប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព សមធម៌ យុត្តិធម៌ និងបរិយាបន្ន។

5. ស្របតាមមាគ៌ាដឹកនាំដ៏ឆ្នើមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងនីតិកាលទី៧នៃរដ្ឋសភាជាតិ ដែល បាននិងកំពុងបន្តការងារពីរាជរដ្ឋាភិបាលអាណត្តិមុនក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបេសកកម្មជាឧត្តមប្រយោជន៍ជូនជាតិ និងដើម្បីសម្រេចឱ្យបាននូវគោលនយោបាយធំៗជាអាទិភាពរួមមាន៖ ១.ការពារសន្តិភាព ស្ថិរភាពនយោបាយ និងរាល់សមិទ្ធផលសង្គមជាតិឱ្យរឹងមាំស្ថិតស្ថេរគង់វង្ស។ ២. លើកកម្ពស់ជីវភាពប្រជាជនគ្រប់រូប ទាំងខាងសម្ភារៈ និងស្មារតីឱ្យបានសមរម្យប្រកបដោយភាពថ្លៃថ្នូរ។ ៣. ការពាររបបរាជានិយម លើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពប្រជាជន និងពង្រឹងនីតិរដ្ឋ។ ៤. ពង្រឹងរដ្ឋបាលសាធារណៈនៅគ្រប់ថ្នាក់ ជារដ្ឋបាលប្រជាជន និងបម្រើផលប្រយោជន៍ប្រជាជន និងទី៥. បន្តជំរុញការកែទម្រង់ដើម្បីអភិបាលកិច្ចល្អ និងក្លាយជាអារ្យប្រទេសជឿនលឿនមួយក្នុងតំបន់ជាមួយនឹងស្នាមញញឹម និងក្តីសង្ឃឹមរបស់ប្រជាជន។

6. ស្របជាមួយគ្នានេះ វិស័យបរិស្ថានត្រូវបានទទួលការគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល ដោយមានកិច្ចសហ-ការយ៉ាងជិតស្និតពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋលើការគ្រប់-គ្រងបរិស្ថាន និងការពារអភិរក្សធនធានធម្មជាតិ។

7. ការបំពេញតួនាទីយ៉ាងយកចិត្តទុកដាក់ ពីថ្នាក់ដឹកនាំនិង មន្ត្រីគ្រប់លំដាប់ថ្នាក់ រួមនឹងប្រជាពលរដ្ឋមូលដ្ឋាន និងប្រជាសហគមន៍ បានធ្វើឱ្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងលិខិតបទដ្ឋានគតិយុត្តទទួលបាននូវលទ្ធផលគួរជាទីពេញចិត្ត។ ជាក់ស្តែងការអនុវត្តច្បាប់១00% ដោយមិនមានការលើកលែងជាដាច់ខាតចំពោះអ្នកប្រព្រឹត្តិបទល្មើសធនធានធម្មជាតិ និងការបញ្ចប់ឱ្យបាននូវវប្បធម៌ចុះកិច្ចសន្យាហើយដោះលែងចំពោះអ្នកប្រព្រឹត្តបទល្មើសធនធានធម្មជាតិ។ ជាមួយគ្នានេះក្រសួងបរិស្ថានក៏បានពង្រឹងកិច្ចសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីខេត្ត នោះគឺអាជ្ញាធរមូលដ្ឋានរាជធានី ខេត្ត ដែលមានតួនាទីភារកិច្ចគ្រប់គ្រងធនធានធម្មជាតិបានស្អិតរម្មួត ដើម្បីទប់ស្កាត់ ការពារ និងអភិរក្សធនធានធម្មជាតិរបស់យើង។ ការបន្តសហការជាមួយបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសនិងអង្គភាពប្រឆាំងអំពើពុករលួយ បន្ថែមលើកិច្ចសហការ ជាមួយអាជ្ញាធរមូលដ្ឋាន ដែលបានអនុវត្តកន្លងមកឥតដាច់នេះ បានធ្វើឱ្យសកម្មភាពបទល្មើសមានការថយចុះ និងវិធានការចម្បងមួយទៀត គឺជំរុញការដាំស្តារព្រៃឈើ សំដៅឱ្យមានការដាំដើមឈើឱ្យច្រើនជាងការកាប់ ដើម្បីបង្កើនគម្របព្រៃឈើឱ្យបាន៦០% នៅឆ្នាំ២០៥០ អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងឈរលើមូលដ្ឋាននៃគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ ដែលមានជាធរមាន ព្រមទាំងក្របខ័ណ្ឌអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ក្រសួងបរិស្ថានបានរៀបចំយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានឆ្នាំ២០២៣-២០២៨ ក្នុងគោលបំណង តម្រង់ទិស និងចង្អុលបង្ហាញការងារអាទិភាព ដើម្បីធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់សេដ្ឋកិច្ចបៃតង សំដៅសម្រេចគោលដៅយុទ្ធសាស្ត្របញ្ចកោណ ក្លាយជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។

8. ព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗទាំងអស់ ជាទីគោរពស្រឡាញ់!

9. យុទ្ធសាស្ត្រទី១ ភាពស្អាត គឺសំដៅដល់ភាពស្អាតចេញពីក្នុងចិត្តនិងភាពស្អាតទាំងបរិស្ថានរស់នៅលើដី ក្នុងទឹក និងក្នុងខ្យល់។ នៅពេលដែលយើងមានភាពស្អាតចេញពីចិត្តហើយ បរិស្ថានជុំវិញយើងនឹងស្អាត ជាលទ្ធផល

យើងនឹងទទួលបានសង្គមជាតិទាំងមូល ដែលស្អាតជាក់ជាមិនខាន។ ជាជំហានដំបូងក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ "ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ" ហើយទទួលបានការគាំទ្រចូលរួមយ៉ាងសកម្ម និងផុលផុសពីប្រជាពលរដ្ឋនៅតាមរោងចក្រ សាលារៀន វត្តអារាម ដៃគូអភិវឌ្ឍន៍ ស្ថាប័នជាតិ និងឯកជនមួយចំនួន ជាពិសេសក្មួយៗសិស្សានុសិស្សជាង ៥លាននាក់ហើយ។

10. តាមរយៈទឡ្ហីករណ៍នេះ ក្រសួងបរិស្ថានបានរៀបចំដាក់ចេញនូវយុទ្ធសាស្ត្រ ជាជំហានបន្តបន្ទាប់ទៀត ដើម្បីភាពស្អាតនៃភពផែនដីរបស់យើង។ ពិតណាស់ថា ចំណងទាក់ទងរវាងពុទ្ធចក្រ និងអាណាចក្រជាទំនាក់ទំនងយ៉ាងជ្រាលជ្រៅដែលមិនអាចកាត់ផ្ដាច់ចេញពីគ្នាបាន។ ដូចនេះក្រសួងបរិស្ថានបាននិងកំពុងពិនិត្យសាងសង់ទីវិបស្សនានៅឧទ្យានជាតិព្រះសុរាម្រិតកុសុមៈគិរីរម្យ ដើម្បីរួមចំណែកសម្អាតចិត្តឱ្យស្អាតផង និងប្រែក្លាយតំបន់រមណីយដ្ឋាននេះ ឱ្យក្លាយជាគោលដៅលម្ហែបៃតងផង ដែលផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រចក្រា ភាពបៃតង របស់ក្រសួងបរិស្ថានផង។

11. យុទ្ធសាស្ត្រទី២ ភាពបៃតង ក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធនាការ "ដាំដើមឈើយ៉ាងតិច១លានដើមក្នុង១ឆ្នាំ" ដើម្បីរួមគ្នាបង្កើនគម្របព្រៃឈើឡើងវិញ ឱ្យបានជាង៦០% នៅឆ្នាំ២០៥០ ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសអព្យាក្រឹតកាបូន។ ជាក់ស្ដែង គិតចាប់តាំងពីថ្ងៃបើកយុទ្ធនាការរហូតមកដល់ថ្ងៃនេះ មន្ត្រីឧទ្យានុរក្សនៃមន្ទីរបរិស្ថានរាជធានី-ខេត្ត បានចូលរួមបណ្ដុះដើមឈើដោយទឹកចិត្តស្រលាញ់បរិស្ថាន និងបានចែកជូនកូនឈើគ្រប់ប្រភេទ រួមមានកូនឈើប្រណីត និងឈើហូបផ្លែបានចំនួនប្រមាណ ២ម៉ឺនដើម រួចជាស្រេច ទៅដល់ប្រជាពលរដ្ឋ ដើម្បីដាំស្ដារព្រៃរេចរឹល ដាំនៅតាមមូល-ដ្ឋាន តាមសហគមន៍ ដាំនៅតាមសាលារៀន និងវត្តអារាមនានា។ ឯខ្ញុំព្រះករុណាផ្ទាល់ ក៏បានបណ្ដុះដើមត្នោតប្រមាណ ៣០ម៉ឺនដើម ដើម្បីត្រៀមចែកជូនបងប្អូនប្រជាពលរដ្ឋផង-ដែរ។ លើសពីនេះ ក្រសួងបរិស្ថានក៏បានរៀបចំ និងបង្កើត គោលដៅលម្ហែបៃតង នៅសហគមន៍តំបន់ការពារធម្មជាតិ ដែលមានសក្ដានុពលទេសចរណ៍ នៅ



ឧទ្យានជាតិ «ភ្នំគូលែន» និងឧទ្យានជាតិ «គីរីរម្យ» ប្រគល់ជូនសហគមន៍ ដើម្បីយកថ្លៃសេវាទេសចរណ៍ ដោយអនុវត្តនូវគោលការណ៍ «ភាពស្អាត» តម្លៃសមរម្យចំពោះភ្ញៀវទេសចរ។ តាមរយៈទឹកចិត្តដ៏ស្អាតល្អ ស្រលាញ់ បរិស្ថាន ធម្មជាតិ របស់ប្រជាពលរដ្ឋខ្មែរ យុវជន យុវនារី ជាពិសេសកូនក្មួយសិស្សានុសិស្ស ក្រសួងបរិស្ថានមាន សុទុដ្ឋិនិយមយ៉ាងមុតមាំថា យើងនឹងអាចធ្វើអោយប្រទេសកម្ពុជា ក្លាយជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០ យ៉ាងប្រាកដ ព្រោះពន្លកបៃតង ដែលដុះចេញពីចិត្តស្អាតរបស់សិស្សានុសិស្ស នឹងធានាបាននូវភាពស្អាត ភាពបៃតង ដោយចីរភាព ដែលជាទិសដៅអាទិភាពនៃយុទ្ធសាស្ត្រចក្រាក្នុងវិស័យបរិស្ថានឆ្នាំ២០២៣-២០២៨។ ការបណ្ដុះនូវវប្បធម៌ស្អាតក្នុងចំណោមសិស្សានុសិស្ស គឺជាភាពជោគជ័យដ៏យូរអង្វែង។ ភាពស្អាត និងភាពបៃតង នេះហើយ ជាកត្តាសារវន្តនាំឆ្ពោះទៅកាន់ចីរភាព។

12. លើសពីនេះក្រសួងបរិស្ថាន បានដាក់ចេញនូវវិធានការ ចំនួន៤ សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព ឱ្យមានប្រសិទ្ធភាព រួមមានការអនុវត្តច្បាប់ ១00% មិនអត់ឱនចំពោះឧក្រិដ្ឋកម្មធនធានធម្មជាតិ និងពង្រឹងការសហការឱ្យកាន់ស្អិតរមួតជាមួយអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ ទប់ស្កាត់បទល្មើស ធនធានធម្មជាតិ ក៏ដូចជាសហការជាមួយអង្គភាពប្រឆាំងអំពើ ពុករលួយ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីពង្រឹងការអនុវត្តច្បាប់បន្ថែមទៀត និងបង្កើតផែនការដាំដើមឈើឡើងវិញនិងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។

ព្រះតេជគុណ និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!

13. ពិតណាស់ថា ចំណងទាក់ទងរវាងពុទ្ធចក្រ និងអាណាចក្រ ជាទំនាក់ទំនងយ៉ាងជ្រាលជ្រៅ ដែលមិនអាចកាត់ផ្ដាច់ចេញពីគ្នា។ កិច្ចការដ៏សំខាន់នេះ អាចសម្រេចទៅបាន លុះត្រាតែមានការចូលរួមដ៏ចម្បងពីសំណាក់ការអប់រំទូន្មាន តាមបែបសាសនា ជាពិសេស ការជំរុញការរស់នៅតាមពុទ្ធឱវាទនៃព្រះពុទ្ធសាសនា ដែលតែងប្រោសសត្វលោកឱ្យរស់នៅប្រកបដោយភាពថ្លៃថ្នូរ និងសុខដុមរមនារវាងគ្នា

ទៅវិញទៅមក។ នៅក្នុងបរិបទដែលសង្គមកម្ពុជាកាន់តែអភិវឌ្ឍ និងកាន់តែទំនើបការលើកកម្ពស់វិធាននៃការរស់នៅស្របតាមដំបូន្មាននៃសាសនាគឺពិតជាសំខាន់។

14. ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានមោទនភាពចំពោះការរីកចម្រើន វិស័យសាសនានៅកម្ពុជា ទាំងពុទ្ធចក្រ ក៏ដូចជាការគោរពជំនឿសាសនាផ្សេងទៀតរបស់ប្រជាជនកម្ពុជាដែលរស់នៅជាមួយគ្នា ប្រកបដោយភាពសុខដុមរមនា។ នេះឆ្លុះបញ្ចាំងឱ្យឃើញអំពីការរីកចម្រើន ក៏ដូចជាការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះព្រះពុទ្ធសាសនា និងភាពចុះសម្រុងគ្នារវាងសាសនាទាំងអស់ ក្នុងគោលដៅដឹកនាំមនុស្សឱ្យល្អ មានសន្តិភាពក្នុងចិត្ត និងក្នុងសង្គមជាតិ។

15. ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណជាថ្មីម្តងទៀត ថ្វាយប្រគេនព្រះចៅអធិការ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សីលវន្ត សីលវតី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ភ្ញៀវកិត្តិយស កងកម្លាំង និងពុទ្ធបរិស័ទទាំងអស់ ចំពោះព្រះវត្តមាន និងវត្តមាន ក្នុងពិធីពុទ្ធាភិសេក និងសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តសន្តិវង្សារាម ហៅវត្តផ្សារថ្មី។ សូមប្រសិទ្ធពរជ័យសូមព្រះតេជគុណ ឯកឧត្តម លោកជំទាវ អស់លោក លោកយាយ លោកតា អ៊ំ ពូ មីង បងប្អូនកូនក្មួយ និងកងកម្លាំងទាំងអស់ សូមទទួលបានជោគជ័យ សិរីវឌ្ឍនាបវរមហាប្រសើរ។

16. ក្នុងនាមខ្លួនខ្ញុំព្រះករុណាខ្ញុំ តំណាងដ៏ខ្ពង់ខ្ពស់សម្តេច មហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវសមិទ្ធផលនានា របស់វត្តសន្តិវង្សារាមហៅវត្តផ្សារថ្មីចាប់ពីពេលនេះតទៅ

សូមអរព្រះគុណ និងសូមអរគុណ!

# ផ្នែកទី៥

## ឯកសារយោង

ជំហរបស់កម្ពុជាចំពោះយុទ្ធនាការ

«ផ្ទៃមេឃពណ៌ខៀវ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ ២០៥០ នៅកម្ពុជា»

**រាជធានី ភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣** — ប្រទេសកម្ពុជា បានបង្ហាញការគាំទ្រ និងចូលរួមយុទ្ធនាការ ផ្ទៃមេឃពណ៌ខៀវ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ ២០៥០។ ឯកឧត្តម បណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានប្រកាសចាប់ផ្តើមយុទ្ធនាការ ផ្ទៃមេឃពណ៌ខៀវ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ ២០៥០ នៅកម្ពុជា ដែលនេះ មានន័យថា កម្ពុជាជាប្រទេសទីមួយពីតំបន់អាស៊ីអាគ្នេយ៍នៃបណ្តាប្រទេសជាសមាជិកវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ដែលគាំទ្រយុទ្ធនាការសកលមួយនេះ។ យុទ្ធនាការដែលជាគំនិតផ្តួចផ្តើមរបស់GGGI មានគោលបំណង ចូលរួមលើកកម្ពស់ការយល់ដឹងអំពី សកម្មភាពអាកាសធាតុរបស់ប្រទេសកម្ពុជា និងប្រមូលផ្តុំនូវការគាំទ្របន្ថែមទៀត ដើម្បីចូលរួមសម្រេចបាននូវគោលដៅនៃការបញ្ចេញឧស្ម័នសូន្យសុទ្ធនៅឆ្នាំ ២០៥០។

ក្នុងពិធីសម្ពោធ ដែលមានការគាំទ្រពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) និងអង្គការអុកស្វាម ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានមានប្រសាសន៍ថា៖ «យុទ្ធនាការនេះ ជាវេទិកាដ៏ពិសេសមួយ ដែលបង្កើតឡើងឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមានទាំងយុវជនផងដែរ ដើម្បីចូលរួមលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការកសាងភាពធន់របស់កម្ពុជា។ ខ្ញុំប្តេជ្ញាលើកកម្ពស់ ការអភិវឌ្ឍស្អាត បៃតង និងប្រកបដោយចីរភាព នៅកម្ពុជា។ លើសពីនេះ យុទ្ធនាការនេះក៏មានទិសដៅស្របទៅនឹងចក្ខុវិស័យរបស់ប្រទេសកម្ពុជាផងដែរ»។

ប្រធានបទសំខាន់ៗជាច្រើន ត្រូវបានលើកយកមកពិភាក្សាក្នុងកិច្ចសន្ទនាជាមួយមន្ត្រីជាន់ខ្ពស់ និងវេទិកានិស្សិតដើម្បីពិភាក្សា ដែលនឹងប្រព្រឹត្តទៅនៅសាលប្រជុំ ម៉ុក ម៉ារ៉េត នៃក្រសួងបរិស្ថាន។ នេះក៏រួមបញ្ចូលផងដែរ អំពីការយល់ដឹងពីតម្រូវការបន្ទាន់នានា ដើម្បីបង្ហាញពីការផ្លាស់ប្តូរចាំបាច់នៅក្នុងវិស័យដឹកជញ្ជូន និងឧស្សាហកម្មរបស់កម្ពុជា ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើគុណភាពខ្យល់ ក៏ដូចជាតម្រូវការសម្រាប់ការវិនិយោគ និងការវិវត្តនៃវិស័យហិរញ្ញវត្ថុបៃតងនៅក្នុងប្រទេស។ កិច្ចពិភាក្សាទាំងនេះ ក៏បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការផ្លាស់ប្តូរដើម្បីឆ្ពោះទៅរកការអនុវត្ត និងបច្ចេកវិទ្យាប្រកបដោយចីរភាព ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

លោកស្រី Sandrine Boucher នាយិកាប្រចាំកម្ពុជានៃទីភ្នាក់ងារបារាំង (AFD) បានលើកឡើងថា៖ «ជាមួយនឹងបទពិសោធន៍ជាច្រើនឆ្នាំក្នុងវិស័យគុណភាពខ្យល់ និងបានមើលឃើញពីផលប៉ះពាល់ជាសកលនៃការបំពុលបរិយាកាស AFD ប្តេជ្ញាចែករំលែកជំនាញបច្ចេកទេសរបស់ខ្លួនជាមួយប្រទេសកម្ពុជា ដើម្បីជួយកម្ពុជាក្នុងការឆ្លើយតបទៅនឹងភាពអវិជ្ជមានកាន់តែខ្លាំងឡើងដែលកើតឡើងមកពីការបំពុលខ្យល់»។ លោកស្រីបានបន្តថា៖ «យើងមានក្តីរំភើបដែលបានឃើញគំនិតផ្តួចផ្តើមនេះត្រូវបានចាប់ផ្តើមនៅប្រទេសកម្ពុជា»។

កញ្ញា Shcm Kim តំណាងGGGIប្រចាំកម្ពុជា បានមានប្រសាសន៍ថា៖ «យើងមានសេចក្តីសោមនស្សរីករាយដែលបានឃើញនូវភាពសាទរពីភាគីពាក់ព័ន្ធរួមមាន រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងយុវជន ដែលបានចូលរួមគ្នានៅកន្លែងតែមួយដើម្បីពិភាក្សា និងជជែកវែកញែកជាមួយគ្នាអំពី ឱកាស និងការលំបាក នៃដំណើររបស់កម្ពុជាឆ្ពោះទៅរកទិសដៅនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ ២០៥០»។

លោកស្រី ភាណ សោភ័ណ នាយិកាអង្គការអុកស្វាម មានប្រសាសន៍ថា "យើងអបអរសាទរចំពោះការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះយុទ្ធនាការ "ផ្ទៃមេឃពណ៌ខៀវ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យត្រឹមឆ្នាំ ២០៥០"។ តាមរយៈការគាំទ្រគំនិតផ្តួចផ្តើមជាសកលនេះ កម្ពុជាកំពុងបោះជំហានដ៏សំខាន់មួយឆ្ពោះទៅរកដំណោះស្រាយការប្រែប្រួលអាកាសធាតុ និងការកសាងអនាគតប្រកបដោយចីរភាព។ ការប្តេជ្ញាចិត្តនេះអាចសម្រេចបាន លុះត្រាតែការខិតខំប្រឹងប្រែងរួមគ្នាពីគ្រប់តួអង្គ និងការចូលរួមរបស់សហគមន៍ដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយការប្រែប្រួលអាកាសធាតុ និងយុវជនក្នុងដំណោះស្រាយ។ យើងមានមោទនភាពដែលបានរួមចំណែកក្នុងយុទ្ធនាការនេះ ហើយយើងនឹងសហការជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់សកម្មភាពអាកាសធាតុប្រកបដោយបរិយាបន្ន និងសមធម៌ ជាពិសេសនៅសហគមន៍ងាយរងគ្រោះ»។

ការពិភាក្សាបន្ថែមបានស្វែងយល់ពីការចូលរួមជាយុទ្ធសាស្ត្ររបស់វិស័យឯកជន ហើយគំនិតផ្តួចផ្តើមដែលដឹកនាំដោយយុវជនផ្តោតលើនិរន្តរភាព។ យុទ្ធនាការ «ផ្ទៃមេឃពណ៌ខៀវ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ ២០៥០ នៅកម្ពុជា» មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសកម្មភាពអាកាសធាតុ ដែលស្របតាមអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលត្រូវបានកំណត់នៅក្នុង ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(NDCs) និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (LTS4CN) និងគោលនយោបាយជាតិ និងគោលដៅផ្សេងទៀត។

យុទ្ធនាការ «ផ្ទៃមេឃពណ៌ខៀវ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ ២០៥០» បានចាប់ផ្តើមឡើងដំបូងនៅឆ្នាំ ២០២១ ក្រោមការផ្តួចផ្តើមរបស់ GGGI និងមជ្ឈមណ្ឌលការប្រែប្រួលអាកាសធាតុ (សាធារណរដ្ឋកូរ៉េ)។ យុទ្ធនាការនេះបាននឹងកំពុងដើរតួជាវេទិកាមួយដែលប្រមូលផ្តុំរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល យុវជន និងវិស័យសាធារណៈ ដើម្បីបង្កើន និងកសាងការយល់ដឹងជាសាធារណៈអំពីការបំពុលខ្យល់ និងលើកកម្ពស់ការប្តេជ្ញាចិត្តរបស់កម្ពុជាអំពី អព្យាក្រឹតកាបូន។

ជាមួយនឹងដៃគូរបស់យើង យើងកំពុងបង្កើតដំណោះស្រាយរួមគ្នាជាមួយ និងសម្រាប់ប្រជាជននៅក្នុងប្រទេសជាង១៥០ ក៏ដូចជានៅតាមតំបន់បារាំងនៅក្រៅប្រទេសចំនួន១១ ផងដែរ។ ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ប្រទេសបារាំង និងប្រជាជនបារាំងក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រុមរបស់យើងកំពុងធ្វើការលើគម្រោងចំនួន ៤,២០០ នៅក្នុងវិស័យនេះ។ គោលបំណងរបស់យើងគឺដើម្បីផ្សះផ្សាការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងការការពារទំនិញរួម ពីសន្តិភាព អាកាសធាតុ និងជីវចម្រុះ រហូតដល់សុខភាព ការអប់រំ និងសមភាពយេនឌ័រ។
ឆ្ពោះទៅរកពិភពលោកដូចគ្នាតែមួយ។

ជាក្រាមនាំចូលថង់ប្លាស្ទិក

អនុលោមទៅតាម អនុក្រឹត្យ ១៦៨ អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក

(កម្រាស់ចាប់ពី ០,០៣មីលីម៉ែត្រ ឡើងទៅ)




ប្រសាសន៍របស់ឯកឧត្តមបណ្ឌិត **អ៊ាង សុផល្លែត**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

(ប្រកាសបើកយុទ្ធនាការ«ថ្ងៃនេះខ្ញុំមិនប្រើថង់ប្លាស្ទិក»ទេ- ១ កញ្ញា ២០២៣)

ធៀបធៀប

ខែមករាឆ្នាំ២០២៣ និងខែមករាឆ្នាំ២០២៤





អនុស្សរណៈយោគយល់

រវាង

ក្រសួងបរិស្ថាន

និង

កាកបាទក្រហមកម្ពុជា

ស្តីពី

យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក

«ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»



អនុស្សរណៈយោគយល់នេះ ត្រូវបានធ្វើឡើងរវាង ក្រសួងបរិស្ថាន តទៅហៅថា « ភាគី ក » និង កាកបាទក្រហមកម្ពុជា តទៅហៅថា « ភាគី ខ »។

ភាគីទាំងពីរ ព្រមព្រៀងធ្វើកិច្ចសហប្រតិបត្តិការលើ យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ « ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ » ក្នុងវិស័យមនុស្សធម៌នៅកម្ពុជា ឈានឆ្ពោះទៅការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកនៅព្រះរាជាណាចក្រកម្ពុជា និងបានចុះអនុស្សរណៈយោគយល់ដូចខាងក្រោម៖

**ប្រការ១**

**គោលបំណង**

អនុស្សរណៈយោគយល់នេះ បង្កើតឡើងដើម្បីអនុវត្តកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងកាកបាទក្រហមកម្ពុជា ក្នុងការអនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ « ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ » ក្នុងវិស័យមនុស្សធម៌នៅកម្ពុជា។

**ប្រការ២**

**ក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការ**

ភាគីទាំងពីរត្រូវអនុវត្តកិច្ចសហប្រតិបត្តិការ ដោយឈរលើគោលការណ៍ស្របតាមបទប្បញ្ញត្តិនីមួយៗដូចតទៅ៖

ភាគី « ក »

១. សម្របសម្រួល និងជំរុញការអនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» ក្នុងវិស័យមនុស្សធម៌នៅកម្ពុជា។

២. ផ្តល់ការគាំទ្របច្ចេកទេសក្នុងការរៀបចំខ្លឹមសារផ្សព្វផ្សាយ អំពីផលប៉ះពាល់នៃការប្រើប្រាស់ប្លាស្ទិក ជាពិសេសថង់ប្លាស្ទិក និងវិធានការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងការគ្រប់គ្រងសំរាម សំណល់ប្លាស្ទិក នៅព្រះរាជាណាចក្រកម្ពុជា។

៣. តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធនាការនេះ ព្រមទាំងផ្តល់ការលើកទឹកចិត្ត ឬ ប័ណ្ណសរសើរបេត្រីបរិស្ថានដល់សាខា-អនុសាខាកាកបាទក្រហមកម្ពុជា និងអង្គភាពដែលអនុវត្តបានល្អ។

ភាគី « ខ »

១. ដឹកនាំសាខា-អនុសាខា មន្ត្រី បុគ្គលិក អ្នកស្ម័គ្រចិត្ត យុវជនកាកបាទក្រហមកម្ពុជា និងមហាជនពាក់ព័ន្ធ អនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ « ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ » ឱ្យមានប្រសិទ្ធភាពក្នុងវិស័យមនុស្សធម៌នៅកម្ពុជា ចាប់ផ្តើមពីការមិនប្រើថង់ប្លាស្ទិកមួយថ្ងៃ ក្នុងមួយសប្តាហ៍ រហូតដល់មិនប្រើប្រាស់ថង់ប្លាស្ទិកទាំងស្រុង។

២. ធ្វើការអប់រំផ្សព្វផ្សាយនូវខ្លឹមសារអំពីផលប៉ះពាល់ពីការប្រើប្រាស់ថង់ប្លាស្ទិក។

៣. ដឹកនាំ សម្របសម្រួល និងសហការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធនាការនេះ និងគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ។

១/២



**ប្រការ៣**

**សុពលភាព**

អនុស្សរណៈយោគយល់នេះ មានសុពលភាពគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ និងត្រូវបានកែប្រែ ឬ បំពេញបន្ថែមទៀតក្រោមការព្រមព្រៀងគ្នាទៅវិញទៅមករវាងភាគីទាំងពីរ។

*អនុស្សរណៈយោគយល់នេះ ធ្វើឡើងជាភាសាខ្មែរ ចំនួន ២ (ពីរ) ច្បាប់ ដែលមានខ្លឹមសារ និងតម្លៃគតិយុត្តដូចគ្នា។*

*ជាសក្ខីភាព ភាគីទាំងពីរសូមចុះហត្ថលេខា ដើម្បីធ្វើឱ្យអនុស្សរណៈយោគយល់នេះត្រូវបានអនុវត្ត និងមានប្រសិទ្ធភាពគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។/.*

ថ្ងៃ សៅរ៍ ១ រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅខេត្តកំពង់ផ្លុង ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២៣

| តំណាងក្រសួងបរិស្ថាន | តំណាងកាកបាទក្រហមកម្ពុជា |
| --- | --- |
| រដ្ឋលេខាធិការ | អគ្គលេខាធិការរងទី១ |
| សាមុ មុហេទ្ធណា | ម៉ែន នារីសោភ័ណ |

២/២



# អនុស្សរណៈយោគយល់

## រវាង

## ក្រសួងបរិស្ថាន

## និង

## រដ្ឋបាលខេត្តកណ្ដាល

## ស្ដីពី

## យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»

អនុស្សរណៈយោគយល់នេះ ត្រូវបានធ្វើឡើងរវាង ក្រសួងបរិស្ថាន តទៅហៅថា « ភាគី ក » និងរដ្ឋបាលខេត្តកណ្ដាល តទៅហៅថា « ភាគី ខ »។

ភាគីទាំងពីរ ព្រមព្រៀងធ្វើកិច្ចសហប្រតិបត្តិការលើ យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» នៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅទាំងអស់ទូទាំងខេត្តកណ្ដាល ឈានឆ្ពោះទៅការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ជាពិសេសថង់ប្លាស្ទិកទាំងស្រុង នាពេលអនាគត និងបានចុះអនុស្សរណៈយោគយល់ ដូចខាងក្រោម៖

### ប្រការ១

### គោលបំណង

អនុស្សរណៈយោគយល់នេះ ធ្វើឡើងដើម្បីអនុវត្តកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» នៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅទូទាំងខេត្តកណ្ដាល។

### ប្រការ២

### គ្របខណ្ឌនៃកិច្ចសហប្រតិបត្តិការ

ភាគីទាំងពីរត្រូវអនុវត្តកិច្ចសហប្រតិបត្តិការ ដោយឈរលើគោលការណ៍ស្របតាមបទប្បញ្ញត្តិនីមួយៗដូចតទៅ៖

ភាគី « ក »

១. សម្របសម្រួល និងជំរុញការអនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក នៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ មន្ទីរ-អង្គភាពជំនាញ និងទីសាធារណៈទូទាំងខេត្តកណ្ដាល។

២. ផ្ដល់ការគាំទ្របច្ចេកទេសក្នុងការរៀបចំខ្លឹមសារផ្សព្វផ្សាយ អំពីផលប៉ះពាល់នៃការប្រើប្រាស់ប្លាស្ទិក និងវិធានការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងការគ្រប់គ្រងសំរាម សំណល់ប្លាស្ទិក នៅតាមសាលារៀន និងទីប្រជុំជន។

៣. តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធនាការនេះ ព្រមទាំងផ្ដល់ការលើកទឹកចិត្ត ឬ ប័ណ្ណសរសើរ មេត្រីបរិស្ថានដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ និងអង្គភាពដែលអនុវត្តបានល្អ។

ភាគី « ខ »

១. ដឹកនាំសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ មន្ត្រីរាជការ និងមហាជនពាក់ព័ន្ធ អនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ « ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ » ឱ្យមានប្រសិទ្ធភាព នៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅទូទាំងខេត្តកណ្ដាល ចាប់ផ្ដើមពីការមិនប្រើថង់ប្លាស្ទិកមួយថ្ងៃក្នុងមួយសប្ដាហ៍ រហូតដល់មិនប្រើប្រាស់ថង់ប្លាស្ទិកទាំងស្រុង។

២. ធ្វើការអប់រំផ្សព្វផ្សាយនូវខ្លឹមសារអំពីផលប៉ះពាល់ពីការប្រើប្រាស់ថង់ប្លាស្ទិក។

៣. ដឹកនាំ សម្របសម្រួលប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធ ស្ដីពីការប្រើប្រាស់ថង់ប្លាស្ទិកនៅតាមបណ្ដាគ្រឹះស្ថានសិក្សាចំណេះទូទៅ ព្រមទាំងសហការត្រួតពិនិត្យ តាមដាន វាយតម្លៃការអនុវត្តយុទ្ធនាការនេះ តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នឬអង្គភាពពាក់ព័ន្ធ។

១/២

### ប្រការ៣

### សុពលភាព

អនុស្សរណៈយោគយល់នេះ មានសុពលភាពគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ និងត្រូវបានកែប្រែ ឬពង្រីកបន្ថែមទៀតក្រោមការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សររវាងភាគីទាំងពីរ។

*អនុស្សរណៈយោគយល់នេះ ធ្វើឡើងជាភាសាខ្មែរ ចំនួន ២(ពីរ) ច្បាប់ ដែលមានខ្លឹមសារ និងតម្លៃគតិយុត្តដូចគ្នា។*

*ជាសក្ខីភាព ភាគីទាំងពីរសូមចុះហត្ថលេខា ដើម្បីធ្វើឱ្យអនុស្សរណៈយោគយល់នេះត្រូវបានអនុវត្ត និងមានប្រសិទ្ធភាពគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។* ៚

ថ្ងៃ សៅរ៍ ១ កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅខេត្តកំពង់ស្ពឺ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២៣

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

សាម៉ុ ម្ជាញា

អភិបាល
នៃគណៈអភិបាលខេត្តកណ្ដាល

គង់ សោភ័ណ្ឌ

២/២



អនុស្សរណៈយោគយល់
រវាង
ក្រសួងបរិស្ថាន
និង
រដ្ឋបាលខេត្តកំពង់ឆ្នាំង
ស្ដីពី
យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក
«ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»

អនុស្សរណៈយោគយល់នេះ ត្រូវបានធ្វើឡើងរវាង **ក្រសួងបរិស្ថាន** តទៅហៅថា « **ភាគី ក** » និង**រដ្ឋបាលខេត្តកំពង់ឆ្នាំង** តទៅហៅថា « **ភាគី ខ** »។

ភាគីទាំងពីរ ព្រមព្រៀងធ្វើកិច្ចសហប្រតិបត្តិការលើ **យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»** នៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅទាំងអស់ទូទាំងខេត្តកំពង់ឆ្នាំង ឈានឆ្ពោះទៅការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ជាពិសេសថង់ប្លាស្ទិកទាំងស្រុង នាពេលអនាគត និងបានចុះអនុស្សរណៈយោគយល់ ដូចខាងក្រោម៖

**ប្រការ១**
**គោលបំណង**

អនុស្សរណៈយោគយល់នេះ បង្កើតឡើងដើម្បីអនុវត្តកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» នៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅទូទាំងខេត្តកំពង់ឆ្នាំង។

**ប្រការ២**
**ក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការ**

ភាគីទាំងពីរត្រូវអនុវត្តកិច្ចសហប្រតិបត្តិការ ដោយឈរលើគោលការណ៍ស្របតាមបទប្បញ្ញត្តិនីមួយៗ ដូចតទៅ៖

**ភាគី « ក »**

១. សម្របសម្រួល និងជំរុញការអនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក នៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅ មន្ទីរ-អង្គភាពចំណុះ និងទីសាធារណៈទូទាំងខេត្តកំពង់ឆ្នាំង។
២. ផ្ដល់ការគាំទ្របច្ចេកទេសក្នុងការរៀបចំខ្លឹមសារអប់រំផ្សព្វផ្សាយ អំពីផលប៉ះពាល់នៃការប្រើប្រាស់ប្លាស្ទិក និងវិធានការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងការគ្រប់គ្រងសំរាម សំណល់ប្លាស្ទិក នៅតាមសាលារៀន និងទីប្រជុំជន។
៣. តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធនាការនេះ ព្រមទាំងផ្ដល់ការលើកទឹកចិត្ត ឬ ប័ណ្ណសរសើរមេត្រីបរិស្ថានដល់គ្រឹះស្ថានសិក្សាចំណោះទូទៅ និងអង្គភាពដែលអនុវត្តបានល្អ។

**ភាគី « ខ »**

១. ដឹកនាំសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ មន្ត្រីរាជការ និងមហាជនពាក់ព័ន្ធ អនុវត្តយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រោមប្រធានបទ « ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ » ឱ្យមានប្រសិទ្ធភាពនៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅទូទាំងខេត្តកំពង់ឆ្នាំង ចាប់ផ្ដើមពីការមិនប្រើថង់ប្លាស្ទិកមួយថ្ងៃក្នុងមួយសប្ដាហ៍ រហូតដល់មិនប្រើប្រាស់ថង់ប្លាស្ទិកទាំងស្រុង។
២. ធ្វើការអប់រំផ្សព្វផ្សាយនូវខ្លឹមសារអំពីផលប៉ះពាល់ពីការប្រើប្រាស់ថង់ប្លាស្ទិក។
៣. ដឹកនាំ សម្របសម្រួលប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធ ស្ដីពីការប្រើប្រាស់ថង់ប្លាស្ទិកនៅតាមបណ្ដាគ្រឹះស្ថានសិក្សាចំណោះទូទៅ ព្រមទាំងសហការត្រួតពិនិត្យ តាមដាន វាយតម្លៃការអនុវត្តយុទ្ធនាការនេះ តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ។

១/២

**ប្រការ៣**
**សុពលភាព**

អនុស្សរណៈយោគយល់នេះ មានសុពលភាពគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ និងត្រូវបានកែប្រែ ឬពង្រីកបន្ថែមទៀតក្រោមការព្រមព្រៀងគ្នាទៅវិញទៅមករវាងភាគីទាំងពីរ។

*អនុស្សរណៈយោគយល់នេះ ធ្វើឡើងជាភាសាខ្មែរ ចំនួន ២ (ពីរ) ច្បាប់ ដែលមានខ្លឹមសារ និងតម្លៃគតិយុត្តដូចគ្នា។*

***ជាសក្ខីភាព ភាគីទាំងពីរសូមចុះហត្ថលេខា ដើម្បីធ្វើឱ្យអនុស្សរណៈយោគយល់នេះត្រូវបានអនុវត្ត និងមានប្រសិទ្ធភាពគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។៚***

ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅខេត្តកំពង់ឆ្នាំង ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០២៣

| | |
|---|---|
| **ជ.រដ្ឋមន្ត្រី** | **អភិបាល** |
| **រដ្ឋលេខាធិការ** | **នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង** |
| **សាបូ សូហ្វាណា** | **ស៊ុន សុវណ្ណារិទ្ធិ** |

២/២





អនុស្សរណៈយោគយល់
រវាង
ក្រសួងបរិស្ថាន
និង
រដ្ឋបាលខេត្តពោធិ៍សាត់
ស្តីពី
យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក
«ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»







អនុស្សរណៈនៃការយោគយល់គ្នា

រវាង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

និង

ក្រសួងបរិស្ថាន

ស្តីពី

យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក

នៅតាមសហគ្រាស គ្រឹះស្ថាន

---

អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក នៅតាមសហគ្រាស គ្រឹះស្ថាន (តទៅនេះហៅថា "អនុស្សរណៈនៃការយោគយល់គ្នា") ត្រូវបានធ្វើឡើងនៅថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០២៤ (តទៅនេះហៅថា "កាលបរិច្ឆេទមានសុពលភាព") ដោយ និងរវាង៖

១- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** មានអាសយដ្ឋានអគារលេខ៣ បហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ (តទៅនេះហៅថា "**ភាគី ក**")

និង

២- **ក្រសួងបរិស្ថាន** មានអាសយដ្ឋាននៅអគារមរតកតេជោ ពិឡុលេខ ៥០៣ ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (តទៅនេះ ហៅថា "**ភាគី ខ**")។

ភាគី ក និងភាគី ខ តទៅនេះត្រូវបានហៅរួមគ្នាថា "**ភាគីទាំងពីរ**" និងហៅដោយឡែកពីគ្នាថា "**ភាគី**"។

**បុព្វកថា**

- **ដោយហេតុថា** ភាគី ក ជាក្រសួងទទួលបន្ទុកវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសគ្រប់គ្រងលើការធានាការកែតម្រូវអនាម័យនិងសន្តិសុខការងារ សុខភាពកម្មករនិយោជិត និងលក្ខខណ្ឌការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន សំដៅសម្រេចឱ្យបាននូវទស្សនវិស័យដែលធានាថាគ្រប់កន្លែងធ្វើការមានប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារត្រឹមត្រូវ ដោយអនុលោមទៅតាមបទដ្ឋាន ស្តីពីសុវត្ថិភាព និងសុខភាពការងារជាតិ និងអន្តរជាតិ ដើម្បីបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ និងស្របតាមអាទិភាពមួយនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដែលបានផ្តោតលើការបន្តលើកកម្ពស់សុវត្ថិភាព និងសុខភាពការងាររបស់កម្មករនិយោជិត។
- **ដោយហេតុថា** ភាគី ខ ជាក្រសួងទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងកិច្ចការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយពិរភាព សម្រាប់ជាឧត្តមប្រយោជន៍សម្រាប់អង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **ដោយហេតុថា** អនាម័យ និងសន្តិសុខនៃកម្មករនិយោជិត គឺជាលក្ខខណ្ឌដែលបានចែងក្នុងច្បាប់ ស្តីពីការងារត្រង់ជំពូកទី៨ មាត្រា២២៩ ដែលតម្រូវឱ្យគ្រប់សហគ្រាស គ្រឹះស្ថាន និងទីកន្លែងធ្វើការត្រូវតែរក្សាឱ្យបានស្អាត ហើយបង្ហាញថាមានលក្ខខណ្ឌអនាម័យ និងភាពសុខសប្បាយជានិច្ច ឬជាមួយហៅត្រូវឱ្យមានលក្ខខណ្ឌការងារចាំបាច់សម្រាប់សុខភាពរបស់កម្មករនិយោជិត។
- **ដោយហេតុថា** ភាគី ខ មានការប៉ះពាល់ក្នុងការចូលរួមគាំទ្រដល់ការធានាអនាម័យនិងសន្តិសុខនៃកម្មករ និយោជិត ដែលជាលក្ខខណ្ឌបានចែងក្នុងច្បាប់ ស្តីពីការងារត្រង់ជំពូកទី៨ ដោយផ្តោតលើការធានានូវបរិយាកាសនៅកន្លែងធ្វើការមានលក្ខណៈសមរម្យ បង្កើនប្រសិទ្ធភាព ផលិតភាពការងារ ការរស់នៅស្អាត បរិស្ថានបៃតង កាត់បន្ថយការប្រើប្រាស់ប្លាស្ទិក និងការអភិវឌ្ឍប្រកបដោយចីរភាពនៅតាមសហគ្រាស គ្រឹះស្ថាន។

១

---

តទៅនេះ ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម៖

**ប្រការ១**

**គោលបំណង**

អនុស្សរណៈនៃការយោគយល់គ្នានេះ មានគោលបំណងបង្កើតនូវក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ ផ្តោតលើការធានានូវបរិយាកាសនៅកន្លែងធ្វើការ មានលក្ខណៈសមរម្យ បង្កើនប្រសិទ្ធភាព ផលិតភាពការងារ ការរស់នៅស្អាត បរិស្ថានបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាពនៅតាមសហគ្រាស គ្រឹះស្ថាន។

**ប្រការ២**

**កាត់បន្ថយការប្រើប្រាស់ប្លាស្ទិក នៅតាមសហគ្រាស គ្រឹះស្ថាន**

ភាគី ក នឹងជំរុញ សហគ្រាស គ្រឹះស្ថាន ឱ្យចូលរួមគាំទ្រ និងលើកកម្ពស់បរិយាកាសនៅកន្លែងធ្វើការមានលក្ខណៈសមរម្យ បង្កើនប្រសិទ្ធភាព ផលិតភាពការងារ ការរស់នៅស្អាត បរិស្ថានបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាពនៅតាមសហគ្រាស គ្រឹះស្ថាន តាមរយៈការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ឆ្ពោះទៅសម្រេចបាននូវគោលដៅ "**កន្លែងធ្វើការ គ្មានថង់ប្លាស្ទិក**"។

**ប្រការ៣**

**ភារកិច្ចរបស់ភាគីទាំងពីរ**

៣.១ **ភាគី ក មានភារកិច្ចដូចខាងក្រោម៖**

- ជំរុញសហគ្រាស គ្រឹះស្ថាន ដើម្បីសម្របសម្រួលលើការរៀបចំផ្សព្វផ្សាយយុទ្ធនាការនៃការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិករៀបចំដោយភាគី ខ ដល់កម្មករនិយោជិតពីការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក
- ផ្តល់វិញ្ញាបនបត្រជូនសហគ្រាស គ្រឹះស្ថាន ដែលរៀបចំរួមគ្នាដោយភាគី ក និងភាគី ខ ដែលចូលរួមអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះ ដើម្បីជាយន្តការលើកទឹកចិត្ត និងការចូលរួមលើកកម្ពស់ បរិយាកាសនៅកន្លែងធ្វើការមានលក្ខណៈសមរម្យ បង្កើនប្រសិទ្ធភាព ផលិតភាពការងារ ការរស់នៅ ស្អាត បរិស្ថានបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាពនៅតាមសហគ្រាស គ្រឹះស្ថាន ដែលជាផ្នែកមួយនៃទំនួលខុសត្រូវសង្គមរបស់សហគ្រាស គ្រឹះស្ថាន និងអាចជាលក្ខណៈវិនិច្ឆ័យមួយនៃការចូលរួមជំរុញចលនា "**សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ**" របស់ភាគី ក។

៣.២ **ភាគី ខ មានភារកិច្ចដូចខាងក្រោម៖**

- រៀបចំយុទ្ធនាការនៃការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក នៅក្រោមប្រធានបទ "**ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ**" នៅតាមសហគ្រាស គ្រឹះស្ថាន
- រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងដល់កម្មករនិយោជិត អំពីកិច្ចការពារបរិស្ថានតាមរយៈការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក

២

---

**ប្រការ៤**

**ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា**

តំណាងភាគីទាំងពីរដែលត្រូវបានចាត់តាំង ដើម្បីជួយសម្របសម្រួលទំនាក់ទំនងរវាងភាគីទាំងពីរក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះមានដូចខាងក្រោម៖

- តំណាងភាគី ក៖ លោក ម៉ាញ់ ណារិទ្ធ
  លេខទូរស័ព្ទ៖ ០៨៧ ៥២៥ ៦៥៦
  អ៊ីម៉ែល៖ manh.narith@mlvt.gov.kh
- តំណាងភាគី ខ៖ លោក ដែក វិមានរស្មី
  លេខទូរស័ព្ទ៖ ០១៧ ២៥២ ៧៣៧
  អ៊ីម៉ែល៖ dek.vimeanreaksmey@moe.gov.kh

**ប្រការ៥**

**ការគ្រប់គ្រង**

ភាគីទាំងពីរត្រូវបង្កើតក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យទៅលើការអនុវត្តនៃអនុស្សរណៈនៃការយោគយល់គ្នា។ ក្រុមការងារបច្ចេកទេសនេះ ត្រូវជួបប្រជុំយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ដើម្បីពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា។

**ប្រការ៦**

**ការចូលជាធរមាន និងការបញ្ចប់**

អនុស្សរណៈនៃការយោគយល់គ្នានេះ មានសុពលភាពសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ហើយនឹងត្រូវបន្តដោយស្វ័យប្រវត្តិនៅពេលផុតកំណត់ លើកលែងតែភាគីណាមួយមានបំណងមិនចង់បន្តការជាថ្មី ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតក្នុងរយៈពេល ៣ (បី) ខែ ជាមុន។

អនុស្សរណៈនៃការយោគយល់គ្នានេះ ធ្វើឡើងជាភាសាខ្មែរ ចំនួន ២ (ពីរ) ច្បាប់ ដោយភាគីនីមួយៗទទួលបាន ១ (មួយ) ច្បាប់។

អនុស្សរណៈនៃការយោគយល់គ្នានេះ មានសុពលភាពចាប់ពីពេលចុះហត្ថលេខានៅកាលបរិច្ឆេទដូចបានបញ្ជាក់ខាងលើនេះតទៅ។

| | |
|---|---|
| **តំណាង** | **តំណាង** |
| **ក្រសួងបរិស្ថាន** | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** |
| **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **អ៊ាង សុផល្លែត** | **ហេង សួរ** |

៣

# ផ្នែកទី៦
## សារថ្លែងអំណរគុណរបស់ឯកឧត្តមរដ្ឋមន្ត្រី



## សារជូនពរពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន

ជាថ្មីម្តងទៀត ខ្ញុំបាទសូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិទាំងអស់ ដែលបានរួមចំណែកជួយឧបត្ថម្ភគាំទ្រជាបច្ចេកទេស ធនធាន ថវិកា និងសម្ភារៈ រហូតសម្រេចបាននូវសមិទ្ធផលផ្លែផ្កាគួរទីមោទនៈ។ ជាមួយគ្នានេះ ខ្ញុំបាទ ក៏សូមថ្លែងអំណរគុណជូនចំពោះមន្ត្រីរាជការក្រសួងបរិស្ថានគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលបានលះបង់និងចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតីចូលរួមចំណែកធ្វើឱ្យកងចក្ររបស់បរិស្ថានយើងវិលទៅមុខយ៉ាងសកម្មជាក់ស្តែង «ពន្លកបៃតង» ដែលជាសារបេះដូងដ៏ស្មោះចេញពីបងប្អូនក្រុមគ្រួសារបរិស្ថានបានជ្រួតជ្រាបដល់បេះដូងរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ហើយពួកគាត់បានយល់យ៉ាងច្បាស់ថា អ្នកបរិស្ថានពិត គឺមានបេះដូងស្អាត និងបៃតងស្រស់បំព្រងជារៀងរហូតទៅ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទ! សូមប្រសិទ្ធពរជ័យ សិរីបវរសួស្តី គោរពជូនពរជ័យដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ សូមទទួលបាននូវជោគជ័យគ្រប់ភារកិច្ច និងសូមប្រកបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។



EANG Sophalleth

# ក្រសួងបរិស្ថាន

MINISTRY OF ENVIRONMENT


អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

(+855) 23 213 908
(+855) 23 220 369